# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ


ឆ្នាំទី៣៤ លេខ ១១ ខែវិច្ឆិកា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

– ធម្មវិចារណកថា ព្រះសាសនមុនី កឹម-ធួរ រៀបរៀង (ត) . . . . . . . . . ១២០៤
– គោលច្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនិងរៀបរៀង (ត) . . . ១២១២
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ូ-ប៉ូ ប្រែរៀបរៀង (ត) . . . . . . . ១២២០
– មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត) . . . ១២២៨
– មហោសថជាតក (ត) . . . . . . . . . . . . . . . ១២៣៦

*ផ្នែកអក្សរសាស្ត្រ*

– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ “ក” (ត) . ១២៥៤
– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . . . ១២៥៨
– រឿងល្បើកឡាហ្វុងតែន (La Fontaine) លោកជេង-ជ្រីវ ប្រែពីភាសាបារាំង(ត) . ១២៦០
– រឿងសាមកុក អ្នកនាងកញ្ញា នូ-កន ប្រែរៀបរៀង (ត) . . . . . . . . ១២៦៨
– រឿងព្រេងចិន លោក រ៉ាយ-ប៊ុក ភូឈួយខែត្រតាកែវ ប្រែរៀបរៀង (ត) . . . . ១២៩៨
– រឿងត្រពាំងលាក់ចង្កូល របស់ក្រុមទំនៀមទម្លាប់ . . . . . . . . . . ១៣០៣

*កំណត់និងប្រវត្តិការណ៍*

– ពិធីសម្ពោធវិមានឯករាជ្យ . . . . . . . . . . . . . . . ១៣០៨
– ពិធីតាំងចៅអធិការ និងគ្រូសូត្រ . . . . . . . . . . . . . ១៣១៤



មួយឆ្នាំមាន ១២ លេខ តម្លៃជា ២៣០៛០០

34è Année — N° 11 — Novembre 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO (suite) . . 1204
—Principes bouddhiques par M. HENG-SAM-AN (suite) . . . . 1212
—Préah Abhidhammapitaka «Kampir Préah Yamaka»
par M. BOU-PO (suite) . . . . . . . . . . . . . . . . 1220
—Madhurasavahini par S.Em LOUIS-EM Haut Conseiller (suite) 1228
—Mahosotha Jataka (suite) . . . . . . . . . . . . . . 1236

### Partie littéraire

—Activités de la Commission Culturelle chapitre «Ka» (suite). . . 1254
—Dictionnaire Sanscrit-Khmer par Vénérable PANG-KHAT (suite). 1258
—Fables de la Fontaine traduites par M. PHÉNG-CHRIV (suite) 1260
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1268
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt
de TAKEO (suite) . . . . . . . . . . . . . . . . . . . . 1298
—Histoire de Trapéang Léak Néangkéal (mœurs et coutumes) . . 1303

### Notes et chroniques

—Cérémonie d'inauguration de monument de l'Indépendence. . . 1308
—Cérémonie de Nomminations des Chau-Athika et leurs adjoints...1314

Prix d'Abonnement annuel (comprenant 12 numéros) : 230$ 00

ផ្នែកសាសនា

# ធម្មវិចារណកថា

ព្រះសាសនមុនី កឹម-គូរ រៀបរៀង

( តមក )

> ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
> ជាការណាមក ឲ្យធ្វើល្អទៅ ។
> ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
> បីនេះលោកហៅ ពុទ្ធសាសនា ។
>
> ប.ព.

ព្រះសម្មាសម្ពុទ្ធ ទ្រង់លើកយកអកុសលមូលគឺ លោភៈ ទោសៈ មោហៈ សម្ដែងចំពោះពុទ្ធបរិស័ទផ្នែកខាងគ្រហស្ថ ទ្រង់លើកយក រាគៈ ទោសៈ មោហៈ សម្ដែងចំពោះពុទ្ធបរិស័ទផ្នែកខាងបព្វជិត ប្លែកគ្នាតែទី ១ ខាងដើមគឺ: លោភៈ ចំពោះគ្រហស្ថ រាគៈ ចំពោះបព្វជិត ក្រៅពីនេះនៅដូចគ្នា ។ គួរឲ្យចង់ដឹងថា ព្រោះហេតុអ្វីបានជាព្រះអង្គទ្រង់សម្ដែងផ្សេងពីគ្នាដូច្នេះ ? ព្រោះហេតុថា គ្រហស្ថជាអ្នកមានសម្បត្តិផ្ទាល់ខ្លួន ឬថាសម្បត្តិជាអាយុជីវិតរបស់គ្រហស្ថ ៗ តែងមានចិត្តផេកផ្ដិតជាប់ជំពាក់ទឹងសម្បត្តិដែលកំពុងមាននៅក្នុងកណ្ដាប់ដៃខ្លួន ទាំងមានចិត្តជាប់ចំពាក់ទឹងសម្បត្តិដែលកំពុងតែស្វែងរកផង ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់សម្ដែង លោភៈ ចំពោះជនកេទគ្រហស្ថ ដើម្បីឲ្យ

ដឹងថា លោភៈ ជាកិលេសធ្វើចិត្តរបស់បុគ្គលឲ្យជាប់ចំពាក់ក្នុងសម្បត្តិ ទាំងជាឫសគល់នៃអកុសល ដែលជាហេតុបណ្តាលឲ្យកើតទុក្ខទោសផ្សេង ៗ ក្នុងលោកនេះ ឬក្នុងលោកខាងមុខ ។ ចំណែកខាងរាគៈព្រះអង្គទ្រង់សម្តែងចំពោះបព្វជិត ដោយហេតុថា បព្វជិតជាមនុស្សមិនមានសម្បត្តិផ្ទាល់ខ្លួនដូចជាគ្រហស្ថទេ គ្រាន់តែមាន រាគៈ គឺសេចក្តីត្រេកត្រ-អាលទៅក្នុងអារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើមតាមផ្លូវចិត្តខ្លះប៉ុណ្ណោះ ពីព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា ធម្មតាបព្វជិត ក្នុងពេលមុននឹងចូលមកបួសក្នុងពុទ្ធសាសនា បានលះបង់ទ្រព្យសម្បត្តិអស់រលីងពីខ្លួនហើយ សូម្បីបើមានចំពាក់បំណុលគេ ក៏បានដែលកដោះស្រាយជ្រះស្រឡះហើយសិនដែរទើបបួស លុះបួសហើយមានត្រឹមតែបរិក្ខារ ៨ សម្រាប់ប្រើប្រាស់ជារបស់បព្វជិតប៉ុណ្ណោះ តែនេះមិនដូច្នោះ មានបព្វជិតខ្លះវង្វេងភ្លេចគំនិតដើមរបស់ខ្លួន ត្រឡប់ជាស្វែងរកគ្រឿងប្រើប្រាស់ដែលជារបស់មិនសមគួរដល់បព្វជិត ឬប្រមូលសន្សំទុកដាក់ទូរលាភសក្ការៈ គឺសម្បត្តិឲ្យមានកាន់តែច្រើនឡើង ៗ កាលបើមានសម្បត្តិច្រើនជារបស់ផ្ទាល់ខ្លួនហើយ បព្វជិតនោះ ក៏រមែងកើតលោភចិត្ត លបទៅស្ទាបអង្អែលទ្រព្យសម្បត្តិ ហួងហែងទ្រព្យសម្បត្តិ ចិត្តជាប់ចំពាក់ក្នុងទ្រព្យសម្បត្តិដែលមាននោះៗ ដូចជាគ្រហស្ថដែរ ។ រឿងនេះបើមានគេយល់ទាស់ថា ទេសម្បត្តិទាំងអស់នោះ ដែលកើតឡើងដល់បព្វជិត អាស្រ័យដោយទាយក

ទាយិកា ប្រគេនទេតើ មានលោកទៅស្វែងរកបានមកដោយកសិកម្ម-ពាណិជ្ជកម្មអ្វីលណា ? ទុកជាគេប្រគេនក៏ដោយ បានមកដោយវិធីណា ក៏ដោយ ធម្មតាមនុស្សដែលនៅជាបុថុជ្ជន ក៏គង់តែកើតលោភៈ គឺធ្វើចិត្តឲ្យជាប់ចំពាក់ ឲ្យមានការរវល់ ហួងហែងថែទាំទុកដាក់ពុំខាន ព្រោះតែរឿងនេះឯង បានជាព្រះពុទ្ធបរមគ្រូ ទ្រង់អនុញ្ញាតថា អាវាសជាទីនៅរបស់បព្វជិតនីមួយ ៗ ត្រូវឲ្យមានកប្បិយកុដិ សម្រាប់ទុកដាក់សម្បត្តិសង្ឃ (សម្បត្តិរួម ឬសម្បត្តិកណ្ដាល) ដើម្បីកុំឲ្យបព្វជិត មានកង្វល់រវល់លំបាកចំពោះលាភគឺសម្បត្តិ ដែលកើតឡើងដល់ខ្លួន ។ បើយើងជាបព្វជិត មិនប្រតិបត្តិតាមពុទ្ធនុញ្ញាតនេះទេ បណ្ដោយចិត្តឲ្យរវើរវល់ជាប់ទៅក្នុងទ្រព្យសម្បត្តិដូចជាគ្រហស្ថដែរ ដែលបាននិយាយមកហើយនោះ ក៏មិនវិសេសប្លែកអំពីគ្រហស្ថប៉ុន្មាន នេះឯងឈ្មោះថាជាការកាន់ប្រទ្យូទី ៥ របស់បព្វជិត ៗ

បព្វជិតខ្លះ កើតទុក្ខតូញត្អែរថា ឱ ! អាត្មាអញតាំងពីបួសមក មិនទាន់ដែលបានធ្វើបុណ្យទានអ្វីនឹងគេសោះ ។ ការតូញត្អែររបស់បព្វជិតនោះ ហាក់ដូចជាពុំសូវសមរម្យ ព្រោះហេតុអ្វី ? ព្រោះហេតុថា បព្វជិតបានលះបង់ទ្រព្យសម្បត្តិរបស់ខ្លួនជ្រះស្រឡះអស់រលីង តាំងពីមុនចូលមកបួសម្ល៉េះ ទៅជាអប្បិច្ឆបុគ្គលគ្មានទ្រព្យសម្បត្តិទៅហើយ នឹងបានទ្រព្យសម្បត្តិពីណាយកមកលះធ្វើទាន មានតែការឃោសនាសូមគេ យកមក

លះធ្វើ ការសូមទ្រព្យគេយកមកធ្វើទាននោះ មិនមែនជាការចាំបាច់របស់បព្វជិតប៉ុន្មានទេ ដូចអនុបុព្វិកថា ៤ យ៉ាងមានទានកថាជាដើម ព្រះសម្ពុទ្ធច្រើនតែសម្តែងប្រារព្ធពួកបរិស័ទជាគ្រហស្ថទេតើ ព្រោះគ្រហស្ថមានភោគសម្បទ គេអាចលះធ្វើទានបាន ជាការជួយសង្គ្រោះឲ្យអ្នកដទៃបានសុខដើម្បីគេបានបុណ្យផង ជាហេតុបន្ថយកម្លាំងកិលេសគឺលោភៈនិងមច្ឆរិយៈផង ។ ខ្ញុំបាននឹករំពឹងរកក្នុងគម្ពីរផ្សេងៗ មិនឃើញមានពុទ្ធដីកាត្រង់ណាដែលសម្តែងសរសើរថា បព្វជិតគួរធ្វើបុណ្យទានដោយទ្រព្យសម្បត្តិសោះ ឃើញមានតែកប្បិយទានក្នុងវិន័យបិដក ដែលព្រះអង្គទ្រង់អនុញ្ញាតឲ្យសហធម្មិកបព្វជិតទាំង ៥ មានភិក្ខុជាដើមអាចធ្វើបាន ប៉ុន្តែការធ្វើកប្បិយទានបាននោះ សូមកុំប្រឡំអំពីពុទ្ធអធ្យាស្រ័យរបស់ព្រះអង្គថា បើលាភសក្ការៈកើតឡើងសម្បូរដល់បព្វជិតអង្គណាមួយ បព្វជិតអង្គនោះគួរចែករំលែកលាភសក្ការៈនោះ ដល់ភិក្ខុសាមណេរទាំងឡាយ ទោះជាសទ្ធិវិហារិក ឬអន្តេវាសិកដែលអាស្រ័យនៅក្នុងវត្តជាមួយឲ្យគ្នាបានប្រើប្រាស់ផង ឬក៏នឹកឃើញវត្តណាមួយ ដែលមានភិក្ខុសាមណេរខ្សត់ខ្សោយមិនសូវសម្បូរលាភ ហើយចង់អនុគ្រោះវត្តនោះ ឲ្យសង្ឃបានលាភខ្លះគ្រាន់នឹងប្រើប្រាស់ បើសម័យនោះជួនជាសម័យកាលចីវរ ក៏គួរចាត់ចែងលាភរបស់ខ្លួនមានស្បង់ចីពរជាដើមតាមមានតាមបាន ជាកប្បិយទាននាំយកទៅវេរប្រគេនសង្ឃវត្តនោះ ដើម្បីឲ្យលោកបានទទួលក្រាលគ្រង

កឋិនទាន តាមពុទ្ធានុញ្ញាតផង ដើម្បីឲ្យលោកបានអានិសង្សខ្លះផង ប៉ុណ្ណោះជាការគួរដែរ ប៉ុន្តែមិនដូច្នោះ មានបព្វជិតខ្លះ គ្មានលាភអ្វីជារបស់ខ្លួនសោះទេ ហើយចង់ធ្វើកឋិនទាន ក៏តាំងផ្ដើមធ្វើដោយប្រើវិធីឃោសនាដោយផ្ទាល់មាត់ ឬដោយលិខិត (ប្រូក្រាម) ដាក់ឈ្មោះខ្លួនឯងជាការអំពាវនាវហៅរកទាយក-ទាយិកា ។ ការឃោសនានេះ ឈ្មោះថាជាការប៉ះពាល់ឬបៀតបៀនទូរគោតៈ និងសទ្ធារបស់ទាយក-ទាយិកាផង ។ កងពេលដែលធ្វើនោះសោតទៀត ក៏មានល្បែងរបាំ ឬភ្លេងភ្ជាត់គគ្រឹកគគ្រេងផ្ដើលយក្ស ផ្ដើលមារ ត្រង់នេះហាក់ដូចជាចង់ហួសព្រំដែនទេដឹង? បើជាគ្រហស្ថវិញ ទោះបីគេផ្ដើមធ្វើដោយវិធីណាមួយ ទោះឃោសនាដោយផ្ទាល់មាត់ក្ដី ដោយលិខិតក្ដី កងពេលដែលធ្វើមានភ្លេងតូរ្យតន្ត្រីគគ្រឹកគគ្រេងយ៉ាងណាក្ដី ក៏បេះតែអាចធ្វើទៅបានទាំងអស់ ។ បើបព្វជិត មិនស្ងប់អើពើនឹងព្រហ្មចរិយធម៌ជានាទីរបស់ខ្លួនប៉ុន្មានទេ បែរជាជួនចិត្តទៅរកការធ្វើទានប្រាថ្នាយកបុណ្យដូចគ្រហស្ថដែរ មិនចាំបាច់មកបួសធ្វើអ្វីទេ នៅធ្វើជាភេទគ្រហស្ថវិញ ជាដំណើរងាយស្រួលកងការធ្វើទានផង ។ បើបព្វជិតណាមួយ មិនយល់ស្របតាមន័យដែលថុនពោលមកនេះទេ ឈ្មោះថាជាការគាន់ប្រឡូទី ៤ របស់បព្វជិត ។

ធុរៈកងពុទ្ធសាសនាមាន ២ យ៉ាងគឺ គន្ថធុរៈ ១ វិបស្សនាធុរៈ ១ ។ គន្ថធុរៈ បានខាងការសិក្សាបរិយត្តិ (ព្រះត្រៃបិដក)

វិបស្សនាធុរៈ បានខានការសិក្សាសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។ ធុរៈទាំងពីរនេះ ជាករណីយកិច្ចរបស់បព្វជិត ។ ត្រូវតែបំពេញធុរៈទាំងពីរនោះ ធុរៈណាមួយ ទៅតាមសមត្ថភាពដែលខ្លួនអាចធ្វើទៅកើត និងខានពុំបានជាដាច់ខាត ។ បើកុលបុត្រដែលបួសជាបព្វជិតហើយ មិនអើពើបំពេញធុរៈទាំងពីរនោះ ធុរៈណាមួយទេ បណ្តោយខ្លួនឲ្យនៅទំនេរ គ្រាន់តែរៀនឲ្យចេះធម៌បាលីទុកសម្រាប់សូត្រមន្ត ជារ បង្សុកូល ហើយនៅរង់ចាំទទួលនិមន្តរបស់ទាយក-ទាយិកា ឬនៅចាំទទួលលាភសក្ការៈអំពីទាយក-ទាយិកា ប៉ុណ្ណោះ ហើយស្មានថាករណីយកិច្ចរបស់បព្វជិតមានតែត្រឹមប៉ុណ្ណោះឯង គ្មានអ្វីក្រៅអំពីនេះទៅទៀតទេ បើបព្វជិត មានគំនិតយល់ដូច្នោះមែន ឈ្មោះថាជាការភាន់ច្រឡំទី ៦ របស់បព្វជិត ។

បព្វជិតខ្លះ បានចេញរួចផុតអំពីអន្ទាក់គឺកាមគុណហើយ ត្រឡប់ជាចូលទៅជាប់ក្នុងអន្ទាក់គឺកាមគុណដដែលវិញ; ន័យនេះបានសេចក្តីថា កុលបុត្រខ្លះ បានលះបង់នូវគំនរភោគទ្រព្យដែលមានវិញ្ញាណ និងឥតវិញ្ញាណទោះបីតិចច្រើនរបស់ខ្លួនផង បានលះបង់នូវក្រុមញាតិមិត្រជាទីស្រឡាញ់ពេញចិត្តផង ហើយចូលមកបួសក្នុងពុទ្ធសាសនា ឈ្មោះថាបានចេញរួចផុតអំពីអន្ទាក់គឺកាមគុណហើយ លុះបួសបានឋានៈជាបព្វជិតហើយ ត្រូវបំពេញត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា ដែលជាទីរបស់ខ្លួនឲ្យបានហ្មត់ចត់ ដើម្បីលះបង់កិលេសតាមលំដាប់ ហើយធ្វើចិត្ត

ឲ្យមានដំណើរឆ្ពោះទៅកាន់បរមសុខ គឺព្រះនិព្វាន ប៉ុន្តែបព្វជិតខ្លះ មិនដូច្នោះទេ ត្រឡប់ជាផ្ទុយទៅវិញ បណ្តោយឲ្យលាភសក្ការៈគ្របសង្កត់ ប្រធ្វើចិត្តឲ្យធ្លាក់លង់លុះក្នុងអំណាចនៃលាភសក្ការៈ រហូតដល់ទៅប្រើវិធីស្វែងរកលាភសក្ការៈក្នុងផ្លូវដ៏ថោកទាបប្រកបដោយអនេសនៈនិងបាបធម៌ ដោយឥតមានសេចក្តីអៀនខ្មាស ។ ជីវភាពរបស់បព្វជិតណា ដែលរស់នៅអាស្រ័យលាភសក្ការៈ កើតឡើងដោយខុសទំនងបែបនេះ ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រិះរិះដៀលថា ជីវភាពរបស់បព្វជិតនោះ ឈ្មោះថាជាជីវភាពដំលាមក ព្រោះហេតុអ្វី? ព្រោះហេតុថា បព្វជិតនោះធ្វើឲ្យទាយក-ទាយិកាមានសេចក្តីជ្រះថ្លានឹងជំនឿប្រព្រឹត្តទៅក្នុងផ្លូវខុសទំនង គឺមិនមែនជាសេចក្តីជ្រះថ្លានាំឲ្យបានបុណ្យកុសលជាហេតុឲ្យរួចចាកទុក្ខបានឡើយ ។ បើបព្វជិតណាមួយ ធ្លាក់ចិត្តទៅត្រេកអរពេញចិត្តលោភក្នុងលាភសក្ការៈ និងការជាប់ចិត្តចំពោះទាយក ទាយិកា ដែលគេមានសេចក្តីស្រឡាញ់រាប់អានខ្លួន បព្វជិតនោះឈ្មោះថា ជាប់នៅក្នុងអន្ទាក់គឺកាមគុណដដែល ដូចកាលខ្លួនដែលនៅជាគ្រហស្ថដែរ នេះឯងឈ្មោះថាជាការកាន់ប្រឡំទី ៧ របស់បព្វជិត ។

កុលបុត្តម្នាក់ៗ ដែលចូលមកបួសក្នុងពុទ្ធសាសនា អាស្រ័យដោយមានគំនិតគិតឃើញពីខាងដើមផ្សេងៗគ្នា មានច្រើនបែប ច្រើនយ៉ាង គឺអ្នកខ្លះ គិតឃើញទោសរបស់ឃរាវាស (ការនៅគ្រប់គ្រងផ្ទះ) ថាសុទ្ធ

តែប្រកបដោយទុក្ខទោសច្រើនស្មានណាស់ មិនអាចធ្វើខ្លួនឲ្យបរិសុទ្ធផុតចាកទុក្ខបាន លុះគិតឃើញហើយ ក៏កើតសេចក្ដីនឿយណាយធុញទ្រាន់នឹងគេហយកក់ស ហើយចេញទៅបួសដោយហេតុនេះក៏មាន ៗ អ្នកខ្លះគិតឃើញទោសនៃខន្ធ ៥ របស់ខ្លួន ដែលត្រូវស្លាប់កើតក្នុងវដ្ដសង្សាររឿយ ៗ លុះគិតឃើញហើយ ក៏ចេញទៅបួសដោយហេតុនេះក៏មាន ៗ អ្នកខ្លះជាមនុស្សទុម្រន់ខ្ជិលច្រអូស គិតឃើញថា ការនៅធ្វើជាគ្រហស្ថនេះ ពិបាកប្រកបការងាររកទ្រព្យសម្បត្តិសម្រាប់ចិញ្ចឹមជីវិតណាស់ បើធ្វើជាអ្នកបួសវិញ ទើបស្រួលងាយនឹងចិញ្ចឹមជីវិត ក៏ចេញទៅបួសដោយហេតុនេះក៏មាន ៗ អ្នកខ្លះ គិតឃើញថាអាត្មាអញ មានវ័យល្មមបួសជាសាមណេរឬជាភិក្ខុហើយ ពីព្រោះអ្នកដទៃគេបួសកល់គ្នា បើឯងមិនបួសទេ ក្រែងអ្នកផងគេនឹងនិន្ទាយ៉ាងនេះ ឬយ៉ាងនោះពុំខាន ហើយក៏ចេញទៅបួសដោយហេតុនេះក៏មាន ៗ អ្នកខ្លះ ពុំបានជាគិតឃើញដល់ទុក្ខទោស ឬ ហេតុណានីមួយទេ តែត្រូវពួកញាតិមាន មាតាបិតាជាដើមនិយាយណែនាំបង្ខំឲ្យបួស ក៏សុខចិត្តព្រមបួសដោយហេតុនេះក៏មាន ៗ អ្នកខ្លះ គិតឃើញថា ក្នុងពុទ្ធសាសនាសម្បូរការសិក្សាណាស់ អាត្មាអញគួរតែរៀនឲ្យចេះដឹងវិជ្ជាខាងផ្លូវពុទ្ធសាសនា លុះគិតឃើញហើយ ក៏ចេញទៅបួសដោយហេតុនេះ ក៏មាន ៗ ល ៗ

(នៅមានត)

# គោលច្បាប់នៃព្រះពុទ្ធសាសនា

## ឋាកធម្មបទ – ខុទ្ទកនិកាយ

លោក ហោង-សមអាន រៀបរៀង

( តមក )

## ឯមិច្ឆាទិដ្ឋិនេះ ឧទាហរណ៍ដូចជា ៖

### រឿងសុនក្ខត្តលិច្ឆវី

សុនក្ខត្តលិច្ឆវី ជាព្រះរាជបុត្ររបស់ព្រះបាទលិច្ឆវី ព្រះចៅក្រុងវេ-សាលី នៃដែនវជ្ជី បានចូលមកបួសក្នុងព្រះពុទ្ធសាសនា បានទិព្វចក្ខុ មើលឃើញរូបទេវតាទាំងឡាយ តែស្ដាប់សំឡេងមិនឮ ក៏ចូលទៅគាល់ព្រះសាស្ដាក្រាបថ្វាយបង្គំ សូមរៀនបរិកម្មក្នុងទិព្វសោតវិជ្ជាតទៅទៀត តែព្រះពុទ្ធជាម្ចាស់មិនបានត្រាស់ពន្យល់ដូចមុនឡើយ ដោយទ្រង់ជ្រាបថា ក្នុងអតីតកាល សុនក្ខត្តភិក្ខុ បានប្រហារត្រចៀកភិក្ខុមានសីល ១ រូបឲ្យថ្លង់ ។ សូម្បីសុនក្ខត្តភិក្ខុព្យាយាមបរិកម្មការទោះដោយខ្លួនឯងអស់ ៣ ឆ្នាំ ក៏មិនបានទិព្វសោតឡើយ ។ កាលបើមិនបានទិព្វសោតដូច្នោះ សុនក្ខត្តភិក្ខុយល់ច្រឡំថា "ព្រះសមណគោតមជាតិក្សត្រ អញក៏ជាតិក្សត្រដូចគ្នា ប្រសិនបើជាអញបានទិព្វសោតវិជ្ជាទៅ ក្រែងលោអញបានត្រាស់ជាព្រះពុទ្ធស្មើនឹងព្រះអង្គ បានជាមិនពន្យល់ប្រាប់វិធីចំរើនឲ្យកើតទិព្វ

សោកដល់អញ   គឺព្រះអង្គប្រាថ្នាពាំងញាណវិស័យនៃអញប្រាកដ " កាលសុនក្ខត្តភិក្ខុយល់ខុសដូច្នោះ ក៏ចង់គំនុំគំព្យាបាទនឹងព្រះបរមគ្រូទៅ ហើយក៏លាចាកសិក្ខាបទទៅជាឃរាវាសវិនាសចាកព្រះពុទ្ធសាសនា ទៅចូលសិក្សាលទ្ធិអន្យតិរ្ថិយនៃពួកនិគ្រន្ថនាដបុត្រ ។

ឯគំនិតរបស់សុនក្ខត្តភិក្ខុថ្កោលទោសព្រះសម្ពុទ្ធដូច្នោះ   ជាគំនិតយល់ខុសទទេ ។ ព្រះពុទ្ធទាំងឡាយមិនមានហឫទ័យញាប់ញ័រដោយលោកធម៌ទេ សមនឹងពុទ្ធភាសិតថា

អាកាសេវ បទំ នត្ថិ   សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ   នត្ថិ ពុទ្ធានមិញ្ជិតំ

" ខាងក្រៅពីពុទ្ធសាសនា មិនមានសមណៈទេ ព្រះពុទ្ធទាំងឡាយមិនមានសេចក្តីញាប់ញ័រទេ   ដូចជាស្នាមជើងដែលមិនមាននៅលើអាកាសដូច្នោះឯង " ។

គំនិតយល់ខុសនៃសុនក្ខត្តភិក្ខុ រាប់ថាជា មិច្ឆាទិដ្ឋិ ពេញទី ព្រោះគំនិតថ្កោលព្រះហឫទ័យព្រះសាស្តាចារ្យ មិនត្រូវតាមទំនងដែលពិតមែនៗ

សុនក្ខត្តភិក្ខុ លុះអស់ជីវិត ទៅកើតក្នុងនរកអស់កាលជាយូរអង្វែងៗ

មិច្ឆាទិដ្ឋិ   គំនិតយល់ខុសមានទោសឃាត់សួគ៌ និង ព្រះនិព្វាន លោកឲ្យឈ្មោះថា បាប ជាអំពើមិនត្រូវធ្វើឡើយ ។

គោលច្បាប់នៃព្រះពុទ្ធសាសនាទី ១ នេះ គឺឲ្យវៀរចាកបាប ដូចន័យដែលសំដែងមកនេះ ពប់ថាជា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

បុរសស្ត្រី អ្នកវៀរចាកអំពើបាបដោយការប្រតិបត្តិតាមវិន័យឈ្មោះថា ជាអ្នកជំរះខ្លួនប្រាណ ជាអ្នកមានកាយវាចាបរិសុទ្ធស្អាត គួរដល់ការនាកម្ម ។ ដំណើរនេះបុរសស្ត្រី អ្នកមានបំណងល្អ គប្បីបំពេញកុសលធម៌ តាមគោលច្បាប់នៃព្រះពុទ្ធសាសនាទី ២ តទៅទៀត ។

២- កុសលស្សូបសម្បទា ការបំពេញកុសលឲ្យបរិបូណ៌ (គោលទី ២ នេះ សង្គ្រោះចូលក្នុងសុត្តន្តបិតក)

ពាក្យថា កុសល នេះ បានដល់សេចក្តីល្អទាំងអស់ ដែលលោកសំដៅយក គឺ សុចរិតនឹងបុញ្ញកម្មផ្សេងៗ ដែលអាចនាំឲ្យបានសេចក្តីសុខកាយសប្បាយចិត្ត ជាហេតុញុំាងសត្វលោកឲ្យទៅកើតក្នុងសុគតិភព ។

ពាក្យថា កុសល នេះប្រែថា អំពើឈ្លាសវៃ អំពើឥតទោស អំពើជាគ្រឿងលះកិលេស ។

ពាក្យថា ការបំពេញកុសលឲ្យបរិបូណ៌ បានដល់ការដែលព្យាយាមធ្វើកុសលឲ្យកើតឡើងក្នុងកាយវាចាចិត្ត គឺបំពេញកុសល.កម្មបថ ១០ ប្រការ ។

កុសលកម្មបថ គឺអំពើល្អជាផ្លូវសម្រាប់អ្នកប្រព្រឹត្តបាននៅកាន់សុគតិគត ឬអំពើល្អដូចជាច្រឡាយសម្រាប់បង្ហូរសេចក្ដីសុខមកឲ្យអ្នកប្រព្រឹត្ត ។ កុសលកម្មបថ ១០ ប្រការនេះគឺ កាយកម្ម អំពើល្អសម្រេចដោយកាយមាន ៣ យ៉ាង១ វចីកម្ម អំពើល្អសម្រេចដោយសំដីមាន ៤ យ៉ាង ១ មនោកម្ម អំពើល្អសម្រេចដោយផ្លូវចិត្តមាន ៣ យ៉ាង ១ ។

## កាយកម្ម

១- បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២- អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬវាចា គឺលួចដណ្ដើមទ្រព្យរបស់គេ ។

៣- កាមេសុមិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## វចីកម្ម

៤- មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥- បិសុណាយ វាចាយ វេរមណី  ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់បំបាក់បំបែកអ្នកដទៃ ។

៦- ផរុសាយ វាចាយ វេរមណី  ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

៧- សម្ផប្បលាបា វេរមណី  ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យពេយពយឥតប្រយោជន៍ ។

មនោកម្ម

៨- អនភិជ្ឈា  មិនមានចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតប្រងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៩- អព្យាបាទោ  មិនមានចិត្តចងគំនុំគុំគួនគិតបង់ឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

១០- សម្មាទិដ្ឋិ  គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែន ។

កុសលកម្មបថទាំង ១០ ប្រការនេះ  បើបុរសស្ត្រីណាបានប្រព្រឹត្តកាន់តាមឲ្យត្រឹមត្រូវដល់កម្រិតហើយ  បុរសស្ត្រីនោះនឹងត្រូវបានអានិ-សង្សច្រើនជាអនេក  ដូចមានពុទ្ធដីកាដែលព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់សំដែងចំពោះព្រាហ្មណ៍និងគហបតីទាំងឡាយ  នៅក្នុងសាល-

ត្រាមថា អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សម្មចារី ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ បើអ្នកប្រព្រឹត្តធម៌ អ្នកប្រព្រឹត្តស្មើ គឺប្រព្រឹត្តតាមកុសលកម្មបថ ១០ ប្រការមានប្រាថ្នាថា លុះខ្ញុំធ្វើមរណកាល ទម្លាយខន្ធទៅកាន់បរលោក ខ្ញុំសូមឲ្យបានកើតជាខត្តិយមហាសាល ជាព្រាហ្មណ៍មហាសាល ជាគហបតីមហាសាល ជាទេវតាក្នុងកាមាវចរសួគ៌ ជាព្រហ្មមានរូប ក្នុងរូបាវចរភូមិ ជាព្រហ្មគ្មានរូប ។

ក្នុងអរូបាវចរភូមិ ឬប្រាថ្នាចង់ឲ្យឲ្យបានសម្រេចអរហត្តផល ក៏គង់សម្រេចដូចសេចក្តីប្រាថ្នារបស់ខ្លួនមិនខាន ។

សួរថា "កុសលកម្មបថ ១០ ប្រការជាកាមាវចរកុសលរមែងឲ្យផលត្រឹមតែទៅកើតក្នុងកាមាវចរភូមិប៉ុណ្ណោះ ចុះហេតុអ្វី បានជាព្រះសាស្តាចារ្យទ្រង់សំដែងថា ឲ្យផលទៅកើតក្នុងកាមាវចរភូមិ និងអរូបាវចរភូមិដែរ ? មិនតែប៉ុណ្ណោះថា និងបានសម្រេចអរហត្តផលក៏មាន ? " ។

ឆ្លើយថា "ពិតដូច្នោះមែនហើយ កុសលកម្មបថនេះ បើបុគ្គលបានប្រព្រឹត្តតាមល្អហើយ អាចនាំឲ្យទៅកើតក្នុងកាមាវចរភូមិមែន តែជាបច្ច័យអាចដំរុលចិត្តឲ្យទៅកាន់ទេវលោកជាន់លើ ដែលហៅថារូបាវចរភូមិ និងអរូបាវចរភូមិ ដែលសម្រេចដោយការចំរើនឈាននោះ ។

## កុសលប្រព្រឹត្តទៅក្នុងកាមាវចរភូមិ

កុសលពួកណាដែលជាវិស័យរបស់អ្នកនៅត្រេកអរដោយកាមគុណ

ទឹងឲ្យផលដល់អ្នកនោះឲ្យកើតជាមនុស្សវិសេស ឬជាទេព្តា អាស្រ័យតាមគុណកុឹងកាមាវចរសួគ៌ កុសលនោះហៅថាកាមាវចរភូមិ ។ កាមា-វចរភូមិ គឺ:

មនុស្សវិសេស

ទេវតាក្នុងចាតុម្មហារាជិកា

- តាវត្តិង្ស
- យាមា
- តុសិត
- និម្មានរតី
- បរនិម្មិតវសតី

## កុសលប្រព្រឹត្តទៅក្នុងរូបាវចរភូមិ

កុសលពួកណាដែលជាវិស័យត្រេកអរដោយរូបឈ្មាន ទឹងឲ្យផលដល់អ្នកនោះឲ្យកើតជាព្រហ្មមានរូប កុសលនោះហៅថា រូបាវចរភូមិ ។ រូបាវចរភូមិគឺ:

| | |
|---|---|
| ព្រហ្មចារិសជ្ជា<br>ព្រហ្មបរោហិតា<br>មហាព្រហ្មា | ទាំង ៣ នេះជាបឋមឈ្មានភូមិ |

| | |
|---|---|
| បរិត្តាភា<br>អប្បមាណាភា<br>អាភស្សរា | ទាំង ៣ នេះជាទុតិយជ្ឈានភូមិ |
| បរិត្តសុភា<br>អប្បមាណសុភា<br>សុភកិណ្ហកា | ទាំង ៣ នេះជាតតិយជ្ឈានភូមិ ។ |
| វេហប្ផលា<br>អសញ្ញី<br>បញ្ចសុទ្ធាវាស | ទាំង ៣ នេះជាចតុត្ថជ្ឈានភូមិ |

## កុសលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ

កុសលពួកណា ដែលជាវិស័យរបស់អ្នកត្រេកអរដោយអរូបជ្ឈាន នឹងឲ្យផលដល់អ្នកនោះ ឲ្យកើតជាព្រហ្មគ្មានរូប កុសលនោះហៅថា អរូបាវចរភូមិ ។ អរូបាវចរភូមិគឺ:

អាកាសានញ្ចាយតនៈ

វិញ្ញាណញ្ចាយតនៈ

អាកិញ្ចញ្ញាយតនៈ

នេវសញ្ញានាសញ្ញាយតនៈ

(នៅមានត)

ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

លោក ប៊ុ – ប៉ុ ប្រែរៀបរៀង

( គមក )

---

កាលព្រះពុទ្ធអង្គបានត្រាស់ដឹងនូវមហាបដ្ឋាន ក្រោមដើមមហាពោធិព្រឹក្សនោះ ទឹកព្រះហឫទ័យរីកធំទូលំទូលាយឥតបង្អៀតបង្អល់សោះ ដូចជាតិមិង្គលមហាមច្ឆជាតិ (ត្រីធំ) ដែលចេញទៅកាន់ផ្ទៃមហាសមុទ្រ មានជម្រៅទឹក ៨ ហ្មឺន ៤ ពាន់យោជន៍ ទីងបត់បែរខ្លួនទៅខាងណាក៏បានឥតទើសទាល់ឡើយ ។ ព្រះពុទ្ធអង្គទ្រង់ពិចារណានូវព្រះមហាបដ្ឋាននេះ សមគួរដល់ព្រះបញ្ញារបស់ព្រះអង្គតាមព្រះពុទ្ធបំណង ។ ទឹកព្រះហឫទ័យរបស់ព្រះអង្គក៏ថ្លាស្អាតរហូតដល់ព្រះឆវិវណ្ណមង្គ ។ ព្រះរស្មីមានពណ៌ ៦ ប្រការគឺ ១ ពណ៌ខៀវ ២ លឿង ៣ ក្រហម ៤ ស ៥ ហង្សបាទ (ជម្ពូដូចជើងហង្ស) ៦ ផ្ទេក (ពន្លឺពេជ្រ) ផ្សាយចេញពេញទាំងសរីរកាយរហូតទៅក្នុងទិសទាំងដប់ ។ ព្រះរស្មីរបស់ព្រះអង្គផ្សាយទៅក្នុងគ្រាត្រាស់ដឹងថ្មី ៗ គង់ក្រោមដើមព្រះមហាពោធិព្រឹក្សនោះដូចម្ដេច កាលព្រះអង្គគង់លើបណ្ឌុកម្ពលសិលាអាសន៍ ក្រោមដើមបារិច្ឆត្តកព្រឹក្សទិព្យក៏មានព្រះរស្មី ៦ ពណ៌ផ្សាយចេញពីព្រះបវរកាយដូច្នោះដែរ ។

សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទេសនា នូវគម្ពីរមហាបដ្ឋានអនន្តន័យនេះ ទ្រង់ចែកចេញនូវបច្ច័យតាំង ២៤ ប្រការ មានហេតុប្បច្ច័យជាដើម មានអវិគតប្បច្ច័យជាបរិយោសាន ។

ឯបច្ច័យតាំង ២៤ ប្រការនោះគឺ ១- ហេតុប្បច្ច័យ ២- អារម្មណប្បច្ច័យ ៣- អធិបតិប្បច្ច័យ ៤- អនន្តរប្បច្ច័យ ៥- សមនន្តរប្បច្ច័យ ៦- សហជាតប្បច្ច័យ ៧- អញ្ញមញ្ញប្បច្ច័យ ៨- និស្សយប្បច្ច័យ ៩- ឧបនិស្សយប្បច្ច័យ ១០- បុរេជាតប្បច្ច័យ ១១- បច្ឆាជាតប្បច្ច័យ ១២- អាសេវនប្បច្ច័យ ១៣- កម្មប្បច្ច័យ ១៤- វិបាកប្បច្ច័យ ១៥- អាហារប្បច្ច័យ ១៦- ឥន្ទ្រិយប្បច្ច័យ ១៧- ឈានប្បច្ច័យ ១៨- មគ្គប្បច្ច័យ ១៩- សម្បយុត្តប្បច្ច័យ ២០- វិប្បយុត្តប្បច្ច័យ ២១- អត្ថិប្បច្ច័យ ២២- នត្ថិប្បច្ច័យ ២៣- វិគតប្បច្ច័យ ២៤- អវិគតប្បច្ច័យ ។

## ១- ហេតុប្បច្ច័យ

កងបទហេតុប្បច្ច័យនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាដោយហេតុជាបច្ច័យមាន ៦ ប្រការ គឺហេតុជាបច្ច័យខាងអកុសល ៣ ប្រការ ហេតុជាបច្ច័យខាងកុសល ៣ ប្រការ ។

ហេតុជាបច្ច័យខាងអកុសល៣ប្រការនោះគឺ លោភោ ១ ទោសោ ១ មោហោ ១ រួមត្នាជា ៣ ប្រការ ។

ហេតុជាបច្ច័យខាងកុសល ៣ ប្រការនោះគឺ អលោភោ ១ អទោសោ ១ អមោហោ ១ រួមគ្នាជា ៣ ប្រការ ។

ឯហេតុជាបច្ច័យខាងអកុសលនឹងកុសលទាំង ៦ ប្រការនោះ ក៏ដូចជាមូលខាងអកុសលនឹងកុសល ដែលសម្តេចព្រះបរមទសពលទ្រង់ត្រាស់ទេសនារួចហើយក្នុងមូលយមកៈ ដូចសំដែងខាងដើមហើយ ប៉ុន្តែគ្រាន់តែក្នុងគម្ពីរយមកនោះថា មូលនៃកុសលនឹងមូលនៃអកុសល ក្នុងគម្ពីរព្រះមហាបដ្ឋាននេះថា ហេតុជាបច្ច័យខាងកុសលនឹងហេតុជាបច្ច័យខាងអកុសលប៉ុណ្ណោះ ឯធម៌ដូចគ្នាឥតខុសគ្នាទេ ។ អ្នកមានប្រាជ្ញាគប្បីជ្រាបថា លោភោ ទោសោ មោហោ នឹង អលោភោ អទោសោ អមោហោ នោះ មានន័យដូចសំដែងហើយក្នុងគម្ពីរព្រះយមកៈ ។

## ២- អារម្មណប្បច្ច័យ

ក្នុងអារម្មណប្បច្ច័យនោះ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាដោយអារម្មណ៍ ៦ ប្រការគឺ រូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ធម្មារម្មណ៍ ១ ។

រូបារម្មណ៍នោះ បាននឹងរូបទាំងពួងដែលជាទីឃើញគោចរ នឹងជាទីត្រេកអរនៃចក្ខុ ។

សទ្ទារម្មណ៍នោះ បាននឹងសម្លេងទាំងពួង ដែលជាទីឃើញគោចរនៃសោត ។

គន្ធារម្មណ៍នោះ បាននឹងក្លិនទាំងពួងដែលជាទីយឹតគោងនៃឃានសិក គឺឃានៈ ។

រសារម្មណ៍នោះ បាននឹងរសទាំងពួងដែលជាទីយឹតគោងនៃជិវ្ហា ។

ផោដ្ឋព្វារម្មណ៍នោះ បាននឹងគ្រឿងសម្ផស្សទាំងពួងដែលជាទីយឹតគោងនៃកាយ ។

ធម្មារម្មណ៍នោះ បាននឹងធម៌ទាំងពួងដែលជាទីយឹតគោងនៃចិត្ត ។

មានពាក្យបុច្ឆាថា គឺ អារម្មណាបច្ចយោ កិរិយាដែលហៅថា "អារម្មណាបច្ច័យ" នោះតើ អាស្រ័យហេតុផលដូចម្តេច ?

មានពាក្យវិសជ្ជនាថា រូបជាឥដ្ឋារម្មណ៍ គឺរូបល្អដ៏ជាទីស្រឡាញ់ពេញចិត្តមានមកប្រាកដដល់ចក្ខុវិញ្ញាណក្នុងកាលណា ក៏ជាបច្ច័យនឹងឲ្យកើតសេចក្តីសោមនស្សត្រេកអរក្នុងកាលនោះ ។ រូបជាអនិដ្ឋារម្មណ៍ គឺរូបអាក្រក់មិនជាទីស្រឡាញ់ពេញចិត្ត មានមកប្រាកដដល់ចក្ខុវិញ្ញាណក្នុងកាលណា ក៏ជាបច្ច័យឲ្យកើតសេចក្តីទោមនស្សអាក់អន់ចិត្តក្នុងកាលនោះ ។ អ្នកប្រាជ្ញគប្បីចូលចិត្តថា រូបជាឥដ្ឋារម្មណ៍មកប៉ះនឹងចក្ខុទ្វារ ក៏ជាបច្ច័យឲ្យកើតសុខសោមនស្ស ។ រូបជាអនិដ្ឋារម្មណ៍មកប៉ះនឹងចក្ខុទ្វារ ក៏ជាបច្ច័យឲ្យកើតទុក្ខទោមនស្ស សូមនាំរឿងមួយដែលមានក្នុងព្រះសូត្រមកបញ្ជាក់ឲ្យឃើញជាឧទាហរណ៍ ដោយសង្ខេបថា ៖

# រឿងស្រីអា

ឯកោ កុលបុត្តោ មានកុលបុត្រម្នាក់នៅលីវពុំទាន់មានប្រពន្ធ ខំធ្វើការបម្រើតាមាក្នុងផ្ទះផងក្រៅផ្ទះផង តែម្នាក់ឯងជានិច្ចកាលពល់ថ្ងៃ ៗ តាមាឃើញកូននឿយហត់លំបាកពេកដូច្នោះ ក៏ប្រាប់កូនថានឹងរកដណ្តឹងប្រពន្ធឲ្យគ្រាន់បានជួយធ្វើការ ៗ ប៉ុន្តែកូននោះចេះតែហាមប្រាមម្តាយកុំឲ្យដណ្តឹងប្រពន្ធ ៗ ម្តាយមិនព្រមស្តាប់ពាក្យកូនហាមប្រាម ក៏ទៅរកត្រកូលមួយប្រុងនឹងដណ្តឹងកូនក្រមុំគេ ៗ កូននោះដឹងរឿងហើយប្រាប់ម្តាយឲ្យទៅដណ្តឹងកូនក្រមុំ ក្នុងត្រកូលដែលខ្លួនស្រឡាញ់ពេញចិត្ត ៗ ម្តាយក៏ទៅដណ្តឹងនាងនោះតាមពាក្យកូនប្រាប់ហើយរៀបមង្គលការយកនាងនោះមកនៅផ្ទះជាមួយ ៗ វញ្ញា ជាតា ឯនាងកុមារិកានោះជាស្រីឥតកូន ៗ ម្តាយប្រាប់កូនប្រុសឲ្យទៅរកស្រីម្នាក់ទៀតមកធ្វើជាប្រពន្ធចុងដើម្បីឲ្យមានកូនគ្រាន់នឹងតពូជ ៗ លុះកុលបុត្រនោះបានប្រពន្ធចុងមកនៅជាមួយហើយ នាងប្រពន្ធដើមខឹងស្អប់មិនចង់ឲ្យឃើញមុខនាងប្រពន្ធចុងសោះ ក៏ចងចិត្តព្យាបាទប្រុងនឹងបំផ្លាញឲ្យវិនាស ៗ ដល់គ្រានាងប្រពន្ធចុងមានផ្ទៃពោះ នាងប្រពន្ធដើមផ្សំថ្នាំលួចដាក់ក្នុងបាយឲ្យនាងប្រពន្ធចុងនោះបរិភោគ ក៏រលូតកូនពីពោះបាត់ទៅ ៗ ដល់នាងប្រពន្ធចុងខម្ទង់ក្នុងលើកទីពី នាងប្រពន្ធដើមលួចដាក់ថ្នាំឲ្យរលូតទៅទៀត ៗ ក្នុងគ្រាទីបី នាងប្រពន្ធចុងដឹងខ្លួនខំបិទបាំងការពារមិនឲ្យ

នាងប្រពន្ធដើមដឹងថាខ្លួនទម្ងន់ ។ ប៉ុន្តែលុះទម្ងន់ជិតគ្រប់ខែ នាងប្រពន្ធដើមដឹងក៏ដាក់ថ្នាំរំលូតកូនទៀត ដោយបន្ទំដាក់ជាមួយបាយ ។ ឯកូនក្នុងផ្ទៃធំពេកដោយចាស់ខែធ្លាក់មិនរួច ក៏ស្លាប់នៅស្ទះទទឹងទ្វារម្ដាយ ។ នោះក៏ស្លាប់ទៅដែរ ។

ប្ដីដឹងរឿងនេះ ក្រោធខឹងខ្លាំងណាស់អត់ទ្រាំពុំបាន ក៏វាយដំទាត់ធាក់ប្រពន្ធដើមជាស្រីអានោះពាល់តែស្លាប់ទៅទៀត ទៅសោយទុក្ខវេទនាក្នុងនរកអស់កាលជាយូរអង្វែង ។ អ្នកមានប្រាជ្ញាគប្បីសន្និដ្ឋានថា រូបដែលជាអនិដ្ឋារម្មណ៍ គឺជាទីស្អប់ខ្ពើមជាបច្ច័យឲ្យកើតទុក្ខវេទនា ដូចស្រីអានោះឯង ។

## រឿងសត្វមៀម

រូបដែលជាឥដ្ឋារម្មណ៍ គឺជាទីស្រឡាញ់ពេញចិត្ត កាលបើមកប៉ះនឹងចក្ខុទ្វារហើយ ក៏ជាបច្ច័យឲ្យកើតសុខសោមនស្សសប្បាយរីករាយក្នុងបច្ចុប្បន្នជាទីសរសើរនៃទេព្ដា លុះរំលាងបញ្ចក្ខន្ធហើយបានទៅកើតក្នុងឋានសួគ៌ ដល់ជាតិជាអវសានបានសម្រេចព្រះនិព្វាន ។ សូមនាំនិទានសត្វមៀមមកបញ្ជាក់ជានិទស្សនន័យ ដំណាលសេចក្ដីថា ៖

ធេរិយគោ វិហារេ ឆ្ដ កាលព្រះមានព្រះភាគស្ដេចគង់នៅក្នុងគុហាទេវិយកគិរី ឯកោ ឧលុកោ គ្រានោះ មានសត្វមៀមមួយនៅក្នុងដើមព្រឹក្សជិតព្រះពុទ្ធអង្គ ។ នាំភិក្ខុសង្ឃស្ដេចទៅទ្រង់ភិក្ខាចារក្នុង

វេលាព្រឹក ៗ សត្វមៀមនោះហើរតាមប្រតិតទៅរហូតដល់ទ្វារស្រុក ៗ លុះព្រះពុទ្ធអង្គព្រមទាំងភិក្ខុសង្ឃត្រឡប់មកអំពីភិក្ខាចារវិញ ស្តេចគង់នៅក្បែរទ្វារគុហា សត្វមៀមនោះក៏នៅចាំមើលរហូតដល់ស្តេចចូលទៅខាងក្នុងគុហា ៗ លុះព្រះពុទ្ធអង្គ ព្រមទាំងភិក្ខុសង្ឃចូលទៅខាងក្នុងគុហាហើយ ទើបសត្វមៀមនោះត្រឡប់ទៅឯសំបុករបស់ខ្លួនវិញ ៗ សត្វមៀមតែងតាមគន់មើលព្រះបរមសាស្តាពល់ថ្ងៃមិនចេះផ្អែតផ្អន់សោះ ៗ

ថ្ងៃមួយ សម្តេចព្រះបរមសាស្តានាំភិក្ខុសង្ឃស្តេចទៅភិក្ខាចារ ៗ បសន្នចិត្តោ សត្វមៀមបានឃើញក៏មានចិត្តជ្រះថ្លាហើរតាមស្តេចទៅដល់ទ្វារស្រុកក៏ឈប់សំកាំងនៅទីនោះ ទើបហើរចុះពីអាកាសកាងស្លាបឡើងងើបក្បាលថ្វាយអភិវាទសម្តេចព្រះពុទ្ធអង្គ ៗ ទ្រង់ត្រាស់នឹងព្រះអានន្ទត្ថេរថា បស្សានន្ទ ម្នាលអានន្ទ ! អ្នកចូរមើលសត្វមៀមនោះ ហេតុតែសម្លឹងមើលពួកភិក្ខុសង្ឃដោយចិត្តសោមនស្សត្រេកអរ ក្នុងអនាគតកាលសត្វមៀមនេះនឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ទ្រង់នាមថា សោមនស្ស ៗ តស្មិ អជ្ឈត្តា ចំណែកទេព្តាដែលអាស្រ័យនៅក្នុងព្រឹក្សពិមាទក្បែរទ្វារគុហានោះ បានឮព្រះពុទ្ធដីកាត្រាស់ដូច្នោះ ក៏ពោលគាថាសរសើរសត្វមៀមដោយអនេកបរិយាយ ៗ

ហេតុនោះ អ្នកប្រាជ្ញទាំងឡាយ គប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា រូបជាឥដ្ឋារម្មណ៍កើតមានប្រាកដដល់ចក្ខុទ្វារ ជាបច្ច័យឲ្យកើត

សោមនស្ស ក្នុងបច្ចុប្បន្នបាននូវសេចក្ដីសរសើរអំពីសំណាក់នៃទេវតា លុះរលត់បញ្ចក្ខន្ធហើយ មានសុគតិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ដូចនិទានសត្វមៀមនេះ ។

## ៣− អធិបតិប្បច្ច័យ

អធិបតិប្បច្ចយោតិ ឯត្ថ ចត្តារោ អធិបតិ ឆន្ទា-ធិបតិ វីរិយាធិបតិ ចិត្តាធិបតិ វិមំសាធិបតិ អធិបតិ វុច្ចតីតិ ឆន្ទោ ច វីរិយំ ច ចិត្តំ វិមំសា ចត្តារោ ធម្មា បច្ចយា កុសលេសុ ធម្មេសូតិ តស្មា ឥមេ អធិប-តិតោ បច្ចយាតិ វេទិតព្វាតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងអធិបតិប្បច្ច័យតទៅ ដំណើរសេចក្ដីថា កាលសម្ដេចព្រះមានព្រះភាគត្រាស់ទេសនាអារម្មណប្បច្ច័យចប់ហើយ ទើបទ្រង់ត្រាស់ទេសនាអធិបតិប្បច្ច័យតទៅទៀត មានព្រះពុទ្ធដីកាត្រាស់ថា ចត្តារោ អធិបតិ អធិបតី មាន ៤ ប្រការ គឺៈ ឆន្ទាធិបតិ ១ វីរិយាធិបតិ ១ ចិត្តាធិបតិ ១ វិមំសាធិបតិ ១ ។

ឆន្ទៈ បាននឹងសេចក្ដីប្រាថ្នា, សេចក្ដីពេញចិត្ត ។

វីរិយៈ បាននឹងសេចក្ដីព្យាយាម ។

( នៅមានត )

មធុរសភាសិណី

សម្តេចព្រះធម្មលិខិត លី-ឃាម ប្រែរៀបរៀង

(តមក)

ព្រះថេរៈបានពោលតបថា ម្នាលអាវុសោទាំងឡាយ កាលពីមុន បើខ្ញុំបានសប្បិចំនួនមួយវែកឆាន់ហើយ ពេលនេះក៏ម្ចាប់ទៅមួយរំពេចពុំឃើតយូរឡើយ ។ ភិក្ខុទាំងឡាយទូលតបថេរដីកាវិញថា បពិត្រលោកដ៏ចំរើន យើងខ្ញុំទាំងឡាយនឹងបាននូវសប្បិទឹកដោះពារមកពីណានោះ លើទឹកសមុទ្រនេះ សូមលោកម្ចាស់អត់ទ្រាំបន្តិចទៅសិនចុះ ។

ព្រះថេរៈបានពោលតបថា ម្នាលអ្នកមានអាយុទាំងឡាយ ឯសប្បិនេះគឺយើងមិនមែនបានដោយក្រទេ ត្រូវអ្នកទាំងឡាយកាន់យកបាត្ររបស់ខ្ញុំទៅដងទឹកសមុទ្រនាំយកមកឲ្យដល់ខ្ញុំឥឡូវនេះចុះ ។

ទើបភិក្ខុទាំងឡាយបានធ្វើតាមបង្គាប់ព្រះថេរៈនោះឯង ។ ឯទឹកសមុទ្រនោះសោត ក៏គួរជាទីអស្ចារ្យពន់ពេក គ្រាន់តែពួកភិក្ខុដងដាក់ក្នុងបាត្រលើកឡើងហើយ ក៏ប្រែក្លាយត្រឡប់កើតជាសប្បិពារប្រាកដមួយរំពេចនោះឯង ។

កាលនោះភិក្ខុទាំងឡាយបានឃើញហើយក៏មានចិត្តស្ញប់ស្ញែងក្រៃលែង ទើបបង្អោននាំចូលទៅប្រគេនចំពោះព្រះថេរៈនោះ ។

កាលបើព្រះថេរៈបាននាំសប្បុរបហើយ អាពាធក៏រម្ងាប់ទៅមួយរំពេច បីដូចជាអណ្តាតប្រទីបដែលត្រូវខ្យល់បក់មកខ្លាំងក៏រលត់សូន្យទៅដូច្នោះឯង ។ ទើបភិក្ខុទាំងឡាយសួរចំពោះព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្តីអស្ចារ្យនេះ តើមានប្រការដូចម្តេច ? តាំងតែពីមុនរៀងមកដល់កាលឥឡូវនេះ យើងខ្ញុំពុំដែលបានឃើញដល់ម្តងសោះឡើយ ។ ព្រះថេរៈបានឆ្លើយតបថា បើដូច្នោះ អ្នកទាំងឡាយចាំមើលនូវពិធីអស្ចារ្យរបស់បុគ្គលអ្នកមានបុណ្យដែលបានធ្វើមកពីមុន ឲ្យជាក់ច្បាស់ឥឡូវនេះចុះ ។ លុះព្រះថេរៈពោលយ៉ាងនេះហើយ ក៏ក្រឡេកមើលទឹកសមុទ្រហើយអធិដ្ឋានថា "ឥទំ សប្បិ ហោតុ" ទឹកសមុទ្រទាំងអស់នេះសូមកើតជាសប្បិចុះ ។ ស្រាប់តែសមុទ្រប្រមាណមួយដូវហ្គូកនៃព្រះថេរៈនោះ ក៏ប្រែត្រឡប់ទៅជាសប្បិដ៏ផ្អែមប្រាកដមួយរំពេចនោះឯង ។

គ្រានោះភិក្ខុទាំងឡាយ សឹងមានចិត្តបង្កើតជាអស្ចារ្យក្រៃលែងហើយសួរតទៅទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន បុណ្យរបស់លោកម្ចាស់ដទៃទៀតប្រាកដដូចនេះមានដែរឬ ។

ព្រះថេរៈពោលថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ បើដូច្នោះ ត្រូវអ្នកទាំងឡាយចាំមើលបុណ្យរបស់យើងឥឡូវនេះចុះ លុះពោលដូចនេះ

ហើយក៏ក្រឡេកមើលទូវភ្នំដោយជុំវិញហើយអធិដ្ឋានថា "ឥមេ គុ-ឡបិណ្ឌា ហោន្តុ" ភ្នំទាំងនេះសូមកើតជាដុំស្ករអំពៅចុះ ។

ភ្នំទាំងនោះក៏កើតជាដុំស្ករអំពៅទាំងអស់ក្នុងកាលនោះឯង ។

ឯភិក្ខុទាំងឡាយ សឹងមានចិត្តបង្កើតជាអស្ចារ្យហើយ សួរព្រះថេរៈតទៅទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន បុណ្យរបស់លោកម្ចាស់ដទៃទៀតប្រាកដដូច្នេះមានដែរឬ ។ លំដាប់នោះព្រះថេរៈតបថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ បើដូចនោះ ត្រូវអ្នកទាំងឡាយចាំមើលបុណ្យរបស់យើងចុះ លុះព្រះថេរៈលោកពោលដូចនោះហើយ ក៏ក្រឡេកមើលទឹកសមុទ្រម្ដងទៀត ហើយអធិដ្ឋាន "ភត្តភាជនានិ សព្យញ្ជនានិ ឧបដ្ឋហន្តុ" ភាជនសំរាប់ដាក់បាយទាំងឡាយ ព្រមទាំងម្ហូបចំណីទាំងពួងចូរឲ្យកើតមានប្រាកដឡើងក្នុងកាលឥឡូវនេះឯង ។

ទឹកសមុទ្រមានប្រមាណមួយជួរក្អេកដោយជុំវិញ ក៏ក្លាយជាភាជនពេញដោយបាយ ព្រមទាំងម្ហូបចំណីទាំងពួងមានប្រការផ្សេង ៗ កើតឡើងប្រាកដក្នុងកាលនោះហោង ។

លំដាប់តពីនោះ ព្រះថេរៈ ក្រឡេកមើលទូវជួរភ្នំហិមពាន្ត ឯភ្នំហិម-ពាន្តក៏សឹងប្រែត្រឡប់កើតជាមាសសុទ្ធប្រាកដក្នុងកាលនោះ គួរជាទីអស្ចារ្យពន់ពេក ៗ មួយវិញទៀត ព្រះថេរៈក្រឡេកមើលទូវដងព្រៃដែលមាននៅក្នុងទីចំពោះមុខ ស្រាប់តែដងព្រៃទាំងនោះ ប្រែត្រឡប់ទៅជា

ដងព្រៃពេញដេរដាស ដោយសំពត់ទិព្វដ៏ស្អាតមុទុលមានពណ៌ផ្សេង ៗ កើតឡើងប្រាកដក្នុងកាលនោះឯង ។

ឯភិក្ខុទាំងឡាយ លុះបានឃើញនូវបាដិហារិយ៍ជាអស្ចារ្យកើតឡើងប្រាកដដោយបុញ្ញារិទ្ធិដូចនោះហើយ ក៏មានសេចក្ដីស្ញប់ស្ញែងក្នុងចិត្តតែពល់គ្នា ទើបសួរទៀតថា: បពិត្រលោកម្ចាស់ដ៏ចំរើន បាដិហារ្យទាំងនេះកើតឡើងប្រាកដដោយបុញ្ញកម្ម តើបុញ្ញកម្មនោះលោកម្ចាស់បានធ្វើអំពើអ្វីខ្លះ ?

ព្រះថេរៈបានសំដែងប្រាប់នូវកុសលកម្ម ដែលខ្លួនបានធ្វើមកហើយក្នុងសាសនាព្រះទសពលទ្រង់ព្រះនាមកស្សបៈ ដោយសេចក្ដីពិស្ដារដូចបានសំដែងមកខាងក្រោយ ហើយលោកសំដែងនូវព្រះគាថាទាំងឡាយដោយសេចក្ដីសោមនស្សដូចនេះថា:

ឥមស្មឹ ភទ្ទកេ កប្បេ កស្សបោ នាម នាយកោ
សព្វលោកហិតត្ថាយ លោកេ ឧប្បជ្ជិ នាយកោ

អធិប្បាយថា: ក្នុងភទ្ទកប្បនេះ មានអង្គព្រះសម្មាសម្ពុទ្ធជានាយកទ្រង់ព្រះនាមកស្សបៈ ទ្រង់បានត្រាស់ដឹងជាអង្គព្រះពុទ្ធក្នុងលោក ដើម្បីប្រយោជន៍ដល់សត្វលោកទាំងអស់ ព្រះអង្គតែងសំដែងធម៌ទេសនាដឹកនាំសត្វឲ្យឆ្លងផុតចាកសំសារវដ្ដឲ្យបានសម្រេចដល់ព្រះនិព្វាន ។

តទាហំ ឧច្ចុយត្តម្ហិ និយុត្តោ កុឡការកោ

តេន កម្មេន ជីវាមិ បោសេមិ បុត្តទារកោ
កិលន្តិន្ទ្រិយមទ្ទក្ខឹ ភិក្ខុំ រោគាតុរំ តទា
ភិក្ខាចារិកវត្តេន សប្បត្ថាយ ឧបាគតំ ។

កាលនោះ ខ្ញុំបានកើតជាអ្នកកំសត់ម្នាក់ បានប្រកបការស៊ីឈ្នួលក្នុងរោងយន្តគាបអំពៅ តែងចិញ្ចឹមគ្រួសារ រស់នៅដោយអំពើស៊ីឈ្នួលនោះឯង វេលាម្តងនោះ ខ្ញុំបានឃើញភិក្ខុមួយអង្គមានឥន្ទ្រិយ៍លំបាក ថមថយខ្លាំងដោយរោគបៀតបៀន បានចូលទៅជិតភូមិអ្នកស្រុកតាមគន្លងភិក្ខាចារិកវត្ត ដើម្បីបិណ្ឌបាត្រសប្បិយកទៅផ្សំធ្វើជាភេសជ្ជរក្សារោគនោះឯង ។

ឧឡុកមត្តំ សប្បិញ្ច អទទំ តស្ស ភិក្ខុនោ
សទ្ទហន្តោ ទានផលំ ឧយ្យាយុត្តមានសោ ។

ខ្ញុំបានជឿជាក់ច្បាស់នូវផលនៃទាន ទាំងមានដួងហឫទ័យទោរទន់ដោយសេចក្តីអាណិត បានយកសប្បិប្រមាណមួយវែកប្រគេនដល់ភិក្ខុដែលមានជម្ងឺនោះ ។

តេន កម្មេន សង្ខារេ សំសរន្តោ ភវាភវេ
យត្ថិច្ឆាមិ យំ យត្ថ ឧប្បជ្ជតិ អនប្បកំ

ដោយផលានិសង្សបុញ្ញកម្មនោះឯង ខ្ញុំបានអន្ទោលទៅកើតក្នុងភពតូច

ភពធំនានា បើខ្ញុំប្រាថ្នានូវរបស់ណា ៗ ទ្រព្យនោះមានប្រមាណច្រើន កើតឡើងប្រាកដក្នុងកាលនោះឯង ។

ឥច្ឆាមហំ សមុទ្ទស្មឹ ជលម្បិ យជមត្តនោ
តំ សព្វម្បិ យជំ ហោតិ យជនានសប្បិំជលំ ។

បើខ្ញុំប្រាថ្នាចង់ឲ្យទឹកក្នុងសមុទ្រ ត្រឡប់កើតជាកាជន៍ពេញដោយសប្បិដើម្បីខ្លួន ទឹកទាំងនោះក៏អាចត្រឡប់កើតទៅដោយកាជន៍ពេញសប្បិប្រាកដដល់ខ្ញុំបាន នេះជាផលដែលខ្ញុំបានឲ្យទានសប្បិដោយពិត ។

សុណាថ មយ្ហំ អញ្ញម្បិ បុញ្ញកម្មំមនោរម្មំ
តទា ទិស្វាហំ ភិក្ខុំ រោគេន បរិបីឡិតំ ។
គុឡបិណ្ឌំ គហេត្វា គហេត្វាន បត្តេ តស្ស
សមោកិរី តេន សោ សុខិតោ អាសិ រោគព្យា-
បគតំ តទា ។

សូមអ្នកទាំងឡាយស្តាប់នូវបុញ្ញកម្ម ដែលជាទីមនោរម្យរបស់ខ្ញុំដទៃទៀត ដូចមានតទៅនេះ គ្រាមួយនោះ ខ្ញុំបានឃើញភិក្ខុមួយអង្គមានរោគបៀតបៀន គ្រចទៅស្វែងរកភេសជ្ជដើម្បីព្យាបាលរោគ ខ្ញុំបានយកស្ករអម្ពៅទៅដាក់ចុះក្នុងបាត្រនៃភិក្ខុនោះ ដោយអំណាចស្ករអម្ពៅជាភេសជ្ជដែលខ្ញុំបានប្រគេននោះ ទើបភិក្ខុអង្គនោះបាននូវសេចក្តីសុខសប្បាយ រោគក្នុងកាយក៏ដល់នូវសេចក្តីរម្ងាប់ស្ងះស្ងៀមទៅក្នុងខណៈនោះឯង ។

តេន មេ ភុញ្ជមានេន សំសរំ ទេវមានុសេ
យត្ថេត្ថាស្មិ ភុញ្ជេយ្យាហំ តត្ថំ សុលភំ មម
សេលោបិ វិបុលោ មយ្ហំ ហោន្តិ បត្តានុវត្តកា
មហន្តាបិ ភុញ្ជបិណ្ឌា ភុញ្ជមានេ ឥទំ ផលំ

ដោយផលទានដែលខ្ញុំបានឲ្យស្ករអម្ពៅនោះ ខ្ញុំបានអន្ទោលទៅកើតក្នុងស្ថានសួគ៌និងស្ថានមនុស្ស បើខ្ញុំត្រូវការដោយស្ករអម្ពៅក្នុងទីណា ខ្ញុំក៏បានស្ករអម្ពៅនោះដោយងាយក្នុងទីនោះឯង ។ ម្យ៉ាងទៀត បើខ្ញុំប្រាថ្នាឲ្យដុំថ្មកើតជាស្ករអម្ពៅ សូម្បីដុំថ្មយ៉ាងធំ ៗ ទាំងឡាយ ក៏គង់អាចប្រព្រឹត្តទៅតាមចិត្តរបស់ខ្ញុំ អាចប្រែត្រឡប់ទៅជាដុំស្ករអម្ពៅកើតប្រាកដដល់ខ្ញុំ នេះជាផលទានដែលខ្ញុំបានឲ្យស្ករអម្ពៅដល់ភិក្ខុមានធម៌ក្នុងកាលនោះដោយពិត ។

អថាបិ មេ កតំ បុញ្ញំ សុណោថ សាធុ កិត្តយោ[១]
ឆាតជ្ឈត្តំ ជន្តុមានំ ទិស្វាន សុចិំ តទា
ភត្តបិណ្ឌេន សន្តប្បិំ តម្បិ ចានំ ជលាវហំ
គតោបន្ថាយ ឆាហោសិ អទ្ធចារេន ខិនតា
សុលភន្នចារេណ សុខិតា អហោសិ ជាតិជាតិយំ
អដ្ឋាបិ យទិ ឥច្ឆាមិ ភោជនេន បយោជនំ ។

១- ឥធ ‹‹សាធុភោតិ›› បាឋោ យុត្តតរោ មេ ។

នៃលោកជាសប្បុរសទាំងឡាយ សូមអ្នកទាំងឡាយស្តាប់នូវបុញ្ញកម្មដែលខ្ញុំបានធ្វើហើយដទៃទៀត ដូចមានតទៅថា កាលនោះខ្ញុំឃើញសត្វឆ្កែមួយ មានខ្លួនដ៏ញាប់ញ័រដោយសេចក្ដីស្រេកឃ្លានបៀតបៀនក្រៃពេក ខ្ញុំបានសង្គ្រោះឆ្កែនោះ ដោយបានឲ្យបាយមួយដុំដល់វា ទានដែលខ្ញុំបានឲ្យហើយនោះ ជាទានមានផលច្រើនអាចនាំមកនូវសេចក្ដីសុខគ្រប់ប្រការ សេចក្ដីដែលខ្វះខាតដោយបាយនិងទឹកពុំដែលមានសោះឡើយ តាំងពីកាលនោះដរាបមក ខ្ញុំតែងដល់នូវសេចក្ដីសុខមានបាយនិងទឹករកបានដោយងាយសព្វជាតិ ៗ សូម្បីក្នុងថ្ងៃនេះ បើខ្ញុំមានប្រាថ្នានូវភោជន គង់ភោជននោះអាចកើតឡើងប្រាកដមួយរំពេចពុំខានឡើយ ៗ

ចក្ខុបថេ សមន្តា មេ ជាយន្តុក្ទលិយោ ពហូ
អជាបិ បរិក្ខុសរណិ អកាសឹ តំ សុណាថ មេ
ឥណាយិកស្ស ចោសស្ស អនាសេកកហាបណំ
តេន មេ បុញ្ញកម្មេន អនន្តំ កវសម្បទំ
បច្ចុំ ជាតរូបញ្ច លភាមិ ជាតិជាតិយំ ៗ

( នៅមានត )

# មហោសថជាតក

ព្រះសាសនមុនី កឹម-ឡូរ ពិនិត្យ

(តមក)

---

បពិត្រមហារាជក្សត្រថ្លៃប្រសើរ រីព្រះបាទចុលនីព្រហ្មទត្តរាជមានអំណាចអានុភាព ប្រកបនូវកំឡាំងរេហ៍ពលសកលយោធាសេនាទាហាននោះច្រើន ហើយគាត់ធ្វើឧបាយកលប្រើអាចារ្យកេវដ្តព្រាហ្មណ៍ឲ្យនាំរាជសារបណ្ណាលមេត្រីស្រដីថា នឹងថ្វាយនាងបញ្ចាលចន្ទីមកជាព្រះអគ្គមហេសីនៃព្រះអង្គ អំពើឧបាយកលនេះ អម្ចាស់ពុំទាន់ជ្រាប ខ្ញុំនឹងឧបមាថ្វាយ រីស្តេចចុលនីនោះ ដូចជាដងសន្ទូច រីអាចារ្យកេវដ្តព្រាហ្មណ៍ជារាជទូតមកនោះ ដូចខ្សែ រីឯនាងបញ្ចាលចន្ទីនោះវិញ ដូចនុយចំណង់នៅផ្លែសន្ទូច រីអម្ចាស់សោត ដូចមច្ឆា កាលណាបើលេបនូវនុយសន្ទូចនោះហើយ នឹងមាននូវសេចក្ដីភ័យដល់ស្លាប់ឯងពុំលែងឡើយ ។ បពិត្រមហារាជអើយ កាលណាបើព្រះអង្គស្ដេចលីលាទៅដល់នគរឯនាយហើយ គេនឹងដោមតាប់សម្លាប់ព្រះអង្គ រីស្ដេចចុលនីនោះ ឧបមាដូចព្រានព្រៃវាយនូវបង្កាត់ ប្រយោជន៍នៅដោមតាប់សម្លាប់ម្រឹគ រីអស់ម្រឹគផង កាលណាបើចូលទៅក្នុងបង្កាត់នោះហើយ មានភ័យស្លាប់ដល់អាត្មា មានប្រការនោះម្ដេចមិញ បើស្ដេចអម្ចាស់ទ្រង់ទៅហើយ សមនឹងមានភ័យដូចម្រឹគចូលក្នុងបង្កាត់ ដូចត្រីលេបនុយសន្ទូចនោះហោង ។

ស្តេចស្តាប់ពាក្យពោធិសត្វទូលដូច្នោះហើយ ស្តេចខ្ញាល់នឹងពោធិ-
សត្វនោះមហិមាក្រៃ ហើយខំអត់សង្កត់ព្រះហឫទ័យ មានព្រះបន្ទូលថា
វ៉ៃកូនគហបតីនេះ វាមិនគោរពអញថាជាស្តេចឡើយ វាមើលងាយអញ
ដូចខ្ញុំអាត្មាវាហោង វ៉ៃព្រះបាទចុលនីព្រហ្មទត្តរាជ ដ៏ជាស្តេចធំប្រសើរ
ប្រើអាចារ្យកេវដ្តព្រាហ្មណ៍ឲ្យនាំពតិមានមកកាន់អញ ថានឹងឲ្យកូនស្រី
នៃស្តេចនោះមកអញ វាដឹងហើយ វាមិនស្រដីនូវពាក្យប្រកបជាមង្គល
ដល់តិចឡើយ វាផ្ទឹមអញដូចត្រីលេបសន្ទូច ដូចម្រឹគចូលក្នុងបង្កាត់
ហើយថានឹងលុះនូវស្លាប់ វាទុកអញជាអ្នកកំឡៅអន្ធពាលស្រាលសេចក្តី
វាស្រដីអព្វមង្គលនូវពាក្យឲ្យបង់លាភ គឺស្រីរតនប្រសើរ វាមិនស្រដីនូវ
ពាក្យជាឧត្តម ពុំដឹងនូវការជាប្រយោជន៍ ជាមង្គលដូចអ្នកប្រាជ្ញទាំង ៤
ហេតុខ្លួនជាអ្នកស្រែជូជាតិ ជាកូនគហបតី កាលណាបើនឹងស្រដី មាន
ទឹកមាត់នោះហូរហៀរសេសៀរអំពាជោយថ្គាល់ទាំងសងខាង មិនដឹង
គាប់គួរ បេះតែក្បួរស្រែ រស់ខ្លួនតែនង្គ័លរនាស់ វាធ្វើឲ្យអន្តរាយនូវក្តី
ប្រយោជន៍នៃអញនេះ ។

ស្តេចតិះដៀលពោធិសត្វដូច្នោះហើយ មានព្រះបន្ទូលទៅនឹងអា-
មាត្យទាំងឡាយ សូត្រនូវបទគាថា ដូច្នេះ :

ឥមំ កាលេ គហេត្វាន នាសេថ វិជិតា មម
យោ មេ រតនលាភស្ស អន្តរាយាយ កាសតិ ។

ម្នាលអ្នកទាំងឡាយអើយ ! រីមហោសថបុត្រគហបតី ក៏ស្រដីឲ្យអន្តរាយលាភអញនឹងបានស្រីរតនប្រសើរមកអញ ចូរអ្នកទាំងឡាយចង់កមហោសថនេះ បំបរបង់ចេញចាកអំពីស្រុកអញនេះហោង ៗ

ពោធិសត្វដឹងសុភាពជាស្តេចខ្ញាល់ដូច្នោះហើយគិតថា បើអញនៅនេះហើយ ម្ល៉េះសមអាមាត្យទាំងឡាយ ក៏កន្ទ្រាក់ជើងដៃអញតាមព្រះបន្ទូលព្រះមហាក្សត្រនោះហើយ យល់ពុំគួរណាស់ ហើយអញខ្មាសគេអស់កាលដ៏លង់ទៅហោង ពោធិសត្វគិតដូច្នោះហើយ ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រចុះអំពីលើប្រាសាទទៅកាន់ផ្ទះអាត្មាហោង ៗ ឯចំណែកព្រះមហាក្សត្រសោត ទ្រង់ខំអត់សង្កត់ព្រះហឫទ័យ ពុំបង្គាប់ឲ្យធ្វើពោធិ-សត្វដោយកំហឹងនោះឡើយ ៗ លំដាប់នោះ ពោធិសត្វគិតថា រីស្តេចនេះជាអ្នកកំឡៅអន្ធពាល មិនយល់នូវការជាប្រយោជន៍នៃអាត្មា ដ៏លុះនូវចំណង់កិលេសតណ្ហា មិនដឹងនូវអនាគតភ័យ សង្ស័យស្មានជានឹងបានព្រះកជបុត្រីព្រះបាទចុលនីនោះ តោះយោបីស្តេចទៅ ក៏នឹងលុះនូវមហា-វិនាសធំ គួរអញនឹងធ្វើគបតាមពាក្យកំហឹងព្រះហឫទ័យស្តេចហើយ ដ្បិតស្តេចនេះជាម្ចាស់មានបច្ច័យទុននោះច្រើន គួរអញប្រើកូនសេកសោមបណ្ឌិតទៅសួរសេចក្តីឲ្យបានដឹងជាក់ច្បាស់ជាមុន ហើយសឹមអញទៅជាក្រោយដោយអាត្មាឯង រីពោធិសត្វគិតដូច្នោះហើយ ឲ្យហៅកូនសេកនោះមកផ្តាំប្រដៅ ដ្បិតនឹងប្រើទៅឰដ៏នគរឧត្តរបញ្ចាលនោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អហ រីអាចិឆមិឯណា ទា-កាលព្រះមហោសថប្រើសេកសោមបណ្ឌិត ទៅដណ្តឹងសេចក្តីកំបាំងអំពីសារិកាពុំពាន់ត្រុកដ ចុះព្រះគាថាពុំពាន់ច្បាស់ លុះព្រះបានត្រាស់ហើយ បន្ទូលនឹងភិក្ខុផងទាំងឡាយជាគាថាដូច្នេះ:

តតោ ច សោ អបក្កម្ម វេទេហស្ស ឧបន្តិកា
អថ អាមន្តយី ទូតំ មាឋរំ សុវបណ្ឌិតំ ៗ

ហៃភិក្ខុផងទាំងឡាយអើយ! ឮចំកាលនោះ រីព្រះមហោសថអ្នកប្រាជ្ញ កាលណាបើអ្នកចុះមកអំពីគាល់ព្រះបាទវិទេហរាជហើយ ព្រះអង្គលីលាយាត្រាទៅកាន់លំនៅព្រះអង្គឯង ហើយទ្រង់គ្រឿងគន្ធពិដោរ សោយភោជនាហារគ្រប់កាលផ្សេង ៗ គឺនាងអមរាប្រដាប់ប្រដាថ្វាយព្រះអង្គស្រេចស្តេចគង់សប្បាយបន្តិចហើយ លំដាប់នោះ ទើបព្រះអង្គបន្ទូលមានព្រះសូរសៀងពិរោះស្មោះហៅទៅកាន់កូនសេកសោមបណ្ឌិត គិតនឹងប្រើដោយអំពើព្រះប្រាជ្ញាឈ្លាសឧបាយកល ហេតុព្រះអង្គអធ្យាស្រ័យយល់ បន្ទូលនូវបទព្រះគាថាដូច្នេះ

ឯហិ សម្ម ហរិតបក្ខ វេយ្យាវច្ចំ ករោហិ មេ
អត្ថិ បញ្ចាលរាជស្ស សាលិកា សយនបាលិកា ៗ

ថា ឯហិ សម្ម ហរិតបក្ខ ហៃកូនសេកសោមបណ្ឌិត គិតដ៏មានរបៀបស្លាបខៀវល្អសំឡាញ់អើយ! នៅចុះកូនក្រង់មាលព្យាយ មិន

អនុស្រុកទេហ៎ះ? ចូរប្រាមកឯអាយ អញនឹងប្រើបាៈទៅធ្វើជាយនូវបំរើអញបន្តិច វសេកសោមបណ្ឌិត ឮព្រះបន្ទូលព្រះឱស្ឋព្រះមហោសថហៅហើយ ហើរកុលចេញមកចំលើចង្កេះ ទើបព្រះមហោសថបន្ទូលថា ហៃសេកសោមបណ្ឌិតសំឡាញ់អើយ! អញនឹងប្រើបាទៅនគរឧត្តរបញ្ចាលនាយ នឹងប្រើមនុស្សទៅ រៀបចំសេចក្តីខេះក្រៃក្រៃ វិស័យចូរបាទៅឯងនៃ ទើបដឹងអាចំសេចក្តីសាច់គ្រេចនោះ បើបាដឹងស្រេចហើយបាក្រឡាប់វិលមកប្រាប់អញឆាប់កុំបីយូរឡើយ សេកសោមបណ្ឌិតគិតហើយ ទូលដណ្តឹងពោធិសត្វវិញថា គាំ គាពោតិ ធេវ បពិត្រអម្ចាស់អើយ! ព្រះអង្គនឹងប្រើទៅឲ្យដឹងអាចំសារពើសេចក្តី អំពីនគរឧត្តរបញ្ចាលនោះម្តេចហ្នឹង? ព្រះមហោសថទូលប្រាប់ថា ហៃសេកសោមបណ្ឌិត អញគិតនឹងប្រើបាទៅនោះ ដ្បិតព្រះបាទចុលនីព្រហ្មទត្តរាជ ឲ្យអាចារ្យកេ-វដ្តព្រាហ្មណ៍ជារាជទូត បន្ទឹងដំកើងព្រះរាជសារ បណ្តាលមេត្រីស្រដីថានឹងយកនាងបញ្ចាលចន្ទីព្រះរាជបុត្រីពិសីឧត្តមនឹងពិធកល្យាណីស្រីវរ-ល័ក្ខណ៍ប្រសើរ ថ្វាយជាព្រះអគ្គមហេសីព្រះបាទវិទេហរាជអម្ចាស់យើងជាមែនពិត ឬមួយលោកធ្វើជាប្រស្នាល្បួងទេហ៎ះ? បទនោះហ្នឹង អញនឹងប្រើបាទៅ ៗ សេកសោមបណ្ឌិត ស្តាប់ហើយទូលពោធិសត្វថាបពិត្រព្រះមហោសថអើយ! បាច់អ្វីព្រួយព្រះទ័យប្រើខ្ញុំទៅហ្នឹង! ព្រះអង្គមិនប្រើមនុស្សម្នាទៅដណ្តឹងឧបនិក្ខិតបុរសយើងនឹងនៅនោះមិញ ពោធិ-

សត្វស្តាប់ហើយ ប្រាប់សេកសោមបណ្ឌិតវិញថា ហៃសេកសោម-
បណ្ឌិតសំឡាញ់អើយ ! វាក្យនោះពីរោះគាប់ហោង គឺនោះអញឲ្យ
ដណ្តឹងទុបនិក្ខិត ហើយផ្តាំមកវិញថា សេចក្តីនេះ យើងខ្ញុំមិនដឹងបទ
លោកមិនគិតនាហានក្រៅឲ្យអ្នកដទៃដឹងបាន មានតែព្រះបាទចុលនីព្រហ្ម-
ទត្តពងឯង នឹងអាចារ្យកេវដ្តព្រាហ្មណ៍ ទៀងទៅនាក្រឡាព្រះបន្ទំបរម-
សុខសួស្តីស្ងាត់ គិតតែនឹងអាចារ្យកេវដ្តព្រាហ្មណ៍ នឹងមហាក្សត្រឯង
ឥតមុខមន្ត្រីសេនាបតីប្រជារាស្ត្រឯណាមួយដឹងបានឡើយ មានតែបក្សី
ស្រីសត្វសារិកាញី ១ តែងនឹងរក្សាក្រឡាព្រះបន្ទំព្រះបាទចុលនីសព្វថ្ងៃ
នោះ ទើបនឹងបានដឹងថា បើព្រះមហោសថអ្នកនឹងចង់ដឹងអាថ៌សារពើ
សេចក្តី សព្វព្រះហឫទ័យពិត សូមតានសេកសោមបណ្ឌិតមកស្នេហ៍
ស្និទ្ធគិតនឹងបក្សីស្រីសត្វសារិកាញីនោះបានឬ ? មនុស្សម្នានោះរកម្រក្រ
ក្រៃពន់ប្រមាណហេតុនោះហោង ឱសេកសោមបណ្ឌិតអើយ ! អញនឹង
ប្រើបាឯងឲ្យទៅជល់យល់សត្វសារិកានោះ ថាបើបាទៅជល់យល់សត្វ
សារិកាញីនោះហើយ កុំបាដណ្តឹងអាថ៌សារពើសេចក្តីកំបាំង បើបាចូល
ទៅនៅនឹងស្រីសត្វសារិកាញី ក្នុងក្រង់រង់ឲ្យស្ងាត់ហើយសន្សឹមដណ្តឹង
សារិកាឯង ៗ សេកទូលវិញថា បពិត្រមហោសថអើយ ! នាប្រាជ្ញ
អធ្យាស្រ័យថ្លៃគាប់ហោង បពិត្រមហោសថអើយ ! ខ្ញុំទៅជល់យល់សត្វ
សារិកានោះបានហោង កុំទម្ងន់សេចក្តីកំបាំង ម្ល៉េះតើសារិកាប្រាប់ខ្ញុំ

ទើបព្រះមហោសថទូលថា ហៃសេកសោមបណ្ឌិត នៅលើគំនិតប្រាជ្ញា បាឯងស្រាប់ បាច់អ៊ុអញទឹងប្រាប់ណែផ្លូវបាឡើយ សេកសោមបណ្ឌិតអើយ! ស្រីសត្វសារិកាញីនោះ មានប្រាជ្ញាឈ្លាសវៃ អធ្យាស្រ័យ យល់កលមារយាទប្រស្នាល្អមលើប្រាជ្ញាបាឯង ហៃសេកសោមបណ្ឌិត បាគិតទឹងដណ្តឹងស្រេចអសារនោះ កំសារិកានោះសង្កាមិនប្រាប់បាឡើយ សេកសោមបណ្ឌិតអើយ! បក្សីស្រីសត្វសារិកាញីនោះ មានប្រាជ្ញាឈ្លាសវៃ អធ្យាស្រ័យ បាទៅស្និទ្ធស្នេហាជាសង្សារ ទើបបក្សីស្រីសត្វសារិកាទឹងប្រាប់បាបាន ។

អមោឃតិ សោ បដិសុត្វា មាឋូរេ សុបណ្ឌិតោ

អគមាសិ ហរិតបក្ខោ សាលិកាយ ឧបន្តិកំ ។

សេកសោមបណ្ឌិត ស្តាប់ព្រះបន្ទូលពោធិសត្វហើយ អរមហិមា ដាក់សិរសានុទចំពុះចុះ ហើយលើកចុងចំអេងសងខាងកាងទទះស្លាប សើចក្អឹក ៗ ទើបទូលពោធិសត្វថា បពិត្រមហោសថអើយ! ខ្ញុំអរណាស់ ស្ពានជាអម្ចាស់ប្រើឲ្យទៅយល់អាថសេចក្តីអំពីស្រីសត្វសារិកាញីម្នោះទេហ៎: ឥឡូវនេះ ព្រះករុណាប្រើថា ឲ្យបានសារិកាញីជាមិត្ត ហើយស្និទ្ធជាសង្សារផងគ្នា ម្នែះហើយខ្ញុំទៅឥឡូវនេះហោង ។ ព្រះម-ហោសថឃាត់ថា អះសេកសោមបណ្ឌិតឈប់សិន: ចាំទុកឃុំប្រឡងទឹង

លាជ ផ្កៃតហើយសន្សឹមបាទៅហោង ៗ សតចាកោង សហស្ស
ចាកោង គោលេ មក្កោត្តា ព្រះមហោសថឃាត់ហើយ ព្រះអង្គ
យកប្រេងគន្ធពិដោរអប់ត្រឡប់មួយរយមួយពាន់ដង ថ្វាជ្រះប្រពៃហើយ
នៃ ទើបលាបអំពីចំពុះចុះទៅដល់ស្មាប ដរាបដល់ក្រចកជើង ហើយ
ទើបសេកសោមបណ្ឌិតកាន់ឱនក្បាលចុះ លើកចុងចំអេងកាន់ដំកើងថ្វាយ
បង្គំ ហើយហើរឡើងប្រទក្សិណ ទើបពាធិសត្វបើកសីហបញ្ជរបវរ
បង្អួចរ័តន៍ ព្រះអង្គលែងសេកហើរទៅកណ្តាលអាកាស សេកសោម
បណ្ឌិតគិតដោយប្រាជ្ញាឧបាយឈ្លាសយល់កលមិថិលានគរ នឹងឧត្តរ
បញ្ចាលជាសត្រូវពុំប្រពៃឡើយ ហើយសេកសោមបណ្ឌិតគិតយល់ទៅ
ដល់អរិដ្ឋបូរីស្រីមហានគរ ពួដ៏សិរីពស្ត្រនោះ ជាមិត្តមេត្រីនឹងព្រះនគរ
ឧត្តរបញ្ចាលគាប់ប្រពៃ សេកសោមបណ្ឌិតយល់ដូច្នោះហើយនៃ ទើប
ហើរផ្ទោះសោះសា ដោយនូវកំឡាំងឆាប់វៃឆៀបឆាប់ស្មើខ្យល់ បន្តិចទៅ
ដល់អរិដ្ឋបូរីសិរីពស្ត្រ សេកសោមបណ្ឌិតគិតកត់សំគាល់អាថិ៍ហារពើ
សេចក្តីអំពីនគរនោះស្រេចហើយ សេកសោមបណ្ឌិតហើរផ្លុកផ្ទោះស្ទោះ
ទៅសំដៅនគរឧត្តរបញ្ចាល ដោយនូវកំឡាំងសោះសាស្មើខ្យល់បន្តិចទៅ
ដល់ ហើយសេករំពឹងនឹងចូលទៅកាន់សារិកា ៗ គាថំ នាសេកនឹង
ចូលទៅកាន់សារិកានោះ តើធ្វើម្តេចនឹងឱ្យបានយល់សារិកា? កាលនោះ
សេកលបចូលទៅក្នុងព្រះរាជមន្ទីរ ហើយហើរទៅទំនាក់ពួលគាងឃ្លាយ

ប្រាសាទមាសប្រសើរ ហើយមើលទៅលំនៅនៃសារិកាពុំឃើញឡើយ ទើបសេកស្រែកនូវស័ព្ទសម្រែកពីពេះ ផ្អែមល្ហែមស្រទន់មុខគួរឲ្យស្រឡាញ់ ៗ គឺ ការ ណា ថានាសេកនឹងបង់ឲ្យស្ងាត់កំបាំង បទគួ មកស្រែកនោះ ? ថាបទលំនៅសារិកានៅក្នុងក្រឡាបន្ទប់រមសុខសួស្តីស្ងាត់ កម្រសត្វបក្សីណាទីនឹងចូលទៅដល់ ហេតុនោះហោង ទើបសេកស្រែកបន្ទឺនូវស័ព្ទឲ្យសារិកាឮហើយនៃ ទើបនឹងឲ្យសារិកាហើរចេញមកឯក្រៅ ទើបសេកនឹងហើរទៅកាន់សារិកាបាន ៗ កាលនោះរីសត្វបក្សីស្រីសារិកា កាលបើបានឮស័ព្ទសំឡេងសេកផ្អែមពីពេះដូច្នោះក្តី សារិកាត្រេកអរ ត្រឹត្រាចក្នុងព្រះហឫទ័យ ហើយឆ្ងាក់ឆ្វៀងផ្អៀងផ្អងរមិលមើលមកសេកពុំឃើញឡើយ ហើយនឹងទំនៅពុំស្រណុក នឹងទប់ពុំបានឡើយ ហើយសារិកានោះ មកស្រែកនូវស័ព្ទសម្រែកកាសាបន្ទឺទៅកាន់សេកវិញ រីសេកសោមបណ្ឌិត ឮមាត់សារិកាស្រែកបន្ទឺស័ព្ទទៅជាក់ហើយ សេកហើរចុះមកអំពីកំពូលប្រាសាទ យល់សារិកាទំនៅបង្អួចមាសជាក់ ជាក់ចំពុះចុះផ្អែកផ្អៀងឆ្វេងឲ្យមកសារិកា ដោយនូវកិច្ចគាថានឹងឲ្យសារិកាប្រាថ្នាចង់ មិនហើរទៅត្រង់សារិកាតែម្ដងឡើយ ហើរត្បាត់ត្មៀលទៅមកនឹងលឲ្យសារិកាហៅ រីសារិកាយល់សេកហើរពុំចុះកាន់ខ្លួនធាប់ លំដាប់នោះ រីសារិកានឹងទប់គាថាពុំបានឡើយ ហើយហៅទៅកាន់សេកថា ឯហ៎ា សម្ម សុវណ្ណបញ្ជរ ឆសីធាហា ហៃ

សេកសោមបណ្ឌិតសំឡាញ់ប្អូនអើយ ! ហៅតែងទឹងហើរ តើទឹងទៅកាន់ឋានឯណាឲ្យព្រួយពេកទាំងចំរេងស្ងាត់អសារជា  ទឹងហើរលេងឥតការអញ្ជើញមកទំលេងទឹងប្អូនឯបង្អួចមាសនេះ  សេកសោមបណ្ឌិតគិតថាមេ-គាយ ! ហៅហើយហ៎ះ អញហើរទៅបាន ក្បិណនោះសេកសោមបណ្ឌិតហើរទៅទំទន្ទឹមទឹងនាងសារិកានាបង្អួចមាស  ទើបសួរទទួលសំណេះសំណាលត្រេកអរត្រេអាលទឹងគ្នា សេកជណ្តឹងសារិកានូវបទគាថាដូច្នេះ :

កាច្ចិ តេ សុឃរេ ខមនីយំ  កាច្ចិ វេសេ អនាមយំ
កាច្ចិ តេ មធុនា លាជំ  លព្ភតិ សុឃរេ តុវំ ។

សុឃរេ នោះ សុវណ្ណបញ្ជរេ និសីទាហិ ថាហៃនាងស្រីសត្វសារិកា មានលំនៅក្នុងក្រង់ប្រដាប់ផ្ទង់ប្រពៃប្រសើរអើយ ! នា-នាងនៅក្នុងក្រឡាបន្ទំបរមសុខសួស្តីសាត់ រឺក៏សុភាពអំណត់អត់ក្រញាំងមានឬទេហ៎ះ ? រីបក្សីសត្វសារិកាញីឆ្លើយវិញថាដូច្នេះ:

កុសលញ្ចេវ មេ សម្ម អថោ សម្ម អនាមយំ
អថោ មេ មធុនា លាជំ លព្ភតិ សុវបណ្ឌិត ។

ហៃសេកសោមបបណ្ឌិតសំឡាញ់ប្អូនអើយ ! នាប្អូននៅជាខ្ញុំក្រុមព្រះបាទអ្នកជាអម្ចាស់ ក្នុងក្រឡាបន្ទំបរមសុខសួស្តីសព្វថ្ងៃនេះ ស្រណុកសប្បាយឥតទុក្ខឡើយ មានតែសុខស្រណុកសប្បាយជាទេហ៎ះ រីទឹកឃ្មុំ

ប្រទុំទឹងលាដផ្ទែមពីសា ព្រះអង្គទ្រង់ព្រះករុណាព្រះរាជទានសព្វថ្ងៃ
ហោង ។

កុតោ នុ សម្ម អាគម្ម កស្ស វា បហិតោ តុវំ
ន ច មេសិ ឥតោ បុព្វេ ទិដ្ឋោ វា យទិ វា សុតោតិ ។

ហៃសេកសោមបណ្ឌិតមិត្តសំឡាញ់ប្អូនអើយ ! អញគិតប្រការមួយ សោក ប្អូនចង់ដឹងពៅ ៗ មកអំពីឋានប្រទេសឯណា នៅក្រៅខេត្រខេម ព្រះហិមពាន្តឆ្ងាយនាយ ឬដំជាសេកមានអម្ចាស់ទ្រង់ព្រះករុណាដូចប្អូន នេះ ថាបើពៅមានអម្ចាស់ ៗ ពៅនោះឈ្មោះអ្វី ? ព្រះបាទអ្នកជាអម្ចាស់ ប្រើពៅមក ឬមួយពៅមកឯង ? ត័ស្តុអ្វីត្រកាល ក៏ពៅត្រកាល ព្រួយតែ ចំអេងហើរមក ពៅប្រាប់ប្អូនឲ្យឆាប់ ប្អូនទឹងប្រដាប់ដោយនូវចំណង់ពៅ ចង់ ចំណាច់ពៅមកបង់ស្រុករុកព្រៃ មកដល់យល់ប្អូនអំពីប្អូននៅជាក្រមុំ រក្សាក្រឡាចន្ទ ប្អូនពុំដែលយល់បក្សីសេកសោមបណ្ឌិតឲ្យប្រាកដពីមុន មកដូចពៅចេះ កុំថាតែយល់ឡើយ តែឈ្មោះមិត្តក៏មិនដែលឮផង ។

សោ តស្សា វចនំ សុត្វា ... សេកសោមបណ្ឌិត ស្តាប់ ពាក្យនាងសារិកានោះហើយ គិតពិចារណាដោយនូវប្រាជ្ញាឈ្លាសទុំថ្លាយ កលថា នាងសារិកានេះហើយ រាជណ្ដឹងអញច្រើនប្រការអ្វីមាល្បាយអេះ បើអញប្រាប់សារិកានេះដោយពិតថា ព្រះមហេសីអ្នកប្រើអញមកពី មិថិលានគរមោយ អញមិនរស់ឡើយ សមនឹងស្លាប់ហោង រីអញនឹង

សារិកានេះ ក៏នឹងមិនបានសុខស្នេហាជាសង្សារសំណេះសំណាលសាក សួរតាថិសារតើ សេចក្តីអំពីសារិកា ហើយក៏នឹងទៅប្រាប់ព្រះមហោសថ អម្ចាស់អញមិនបានឡើយ បើដូច្នោះ អញនឹងរិះរកប្រស្នាមុសាវាទកូត ប្រាប់ថា មកអំពីអវិជ្ជបុរីស្រីព្រះមហានគរនោះវិញ រីសេកសោមបណ្ឌិត កាលណាបើគិតពិចារណានូវប្រការអម្បាលនោះហើយ ក៏ឆ្លើយទៅកាន់សារិកាវិញថា :

ហៃនាងសារិកាប្អូនពុំងាសំឡាញ់បងអើយ ! រីអម្ចាស់បងនោះសោត ទ្រង់ព្រះនាមហៅព្រះបាទសិរិពជ ព្រះអង្គទ្រង់ព្រះករុណាឲ្យរក្សាក្រឡាបន្ទំបរមសុខសួស្តិក្នុងប្រាសាទ ព្រះអង្គទ្រង់ព្រះករុណាពិសេសសឹងដោះស្រាយសត្វទាំងឡាយអំពីចំណង រីអញបងនាងសោត ព្រះអង្គបើកសីហបញ្ជរបន្ទុំមាសជានិច្ចជាកាលប្រសើរ ទើបលែងបងចេញទៅអស់ចិត្តហើយ អញបងមកទំនៅបន្ទុំមាសវិញ នានាងប្អូនពៅទំនៅបន្ទុំមាសជានិច្ចជាកាលម្តេចម៉ិញ អញបងក៏ដូច្នោះហោង ។

កាលនោះ ឯបក្សីស្រីសត្វសារិកា ស្តាប់ពាក្យសេកសោមបណ្ឌិតស្រេចហើយ នឹងឲ្យសេកសោមបណ្ឌិតសុខស្នេហាជាសង្សារផងគ្នា ហើយយកទឹកឃ្មុំ ប្រឡូនឹងលាជប្រពៃ ដាក់ក្នុងរលាមាស ឲ្យអកកាសបរិភោគ ហើយថា ហៃសេកសោមបណ្ឌិតមិត្តសំឡាញ់ប្អូនអើយ ! ចៅមកនេះពីបានចម្ងាយ ក្រែងទៅឃ្លានអាហារ ចៅនឹងពារញញើតប្អូន

នោះ ចូរទៅបរិភោគទឹកឃ្មុំប្រឡូំនឹងលាជឲ្យសប្បាយ ហៃសេកសោមបណ្ឌិត ប្អូនគិតដល់អំពីដំណើរទៅមកបានអាយនេះ ប្អូនរិះគិតមិនយល់ឡើយ ទៅមកដោយទូវហេតុម្ដេច? ចូរទៅប្រាប់ប្អូនឲ្យដឹងតិចក៏ ក័ស្តុអ្វីត្រកាល គំទៅត្រអាលមករកប្អូន ៗ នឹងរកដោយចំណង់ទៅចង់ ៗ

សេកសោមបណ្ឌិតនោះ ស្ដាប់ពាក្យនាងសារិកានោះហើយ ក៏រិះរកឧបាយកលប្រស្នាមុសាវាទ កូតប្រាប់ទៅនាងសារិកា នូវបទព្រះគាថាដូច្នេះ :

តស្ស មេ តា ទុតិយាសិ សាលិកា មញ្ជុភាណិកា
តំ តត្ថ អវធិ សេណោ បេត្វាតោ សុឃរេ មមត្តិ ៗ

សាលិកេ ហៃនាងសារិកាអើយ! នាងស្ដាប់បងនឹងថ្លែងដោយដំណើរបងមកនោះប្រាប់នាង បងឥតបើប្រាថ្នាក៏ស្តុការអ្វីដទៃក្រៅនាងប្រពន្ធនោះឡើយ ហៃសារិកានាងអើយ! នាងយល់ជាសេក នាងស្មានបងប្រាថ្នាប្រពន្ធសេកដូចគ្នាហ៎: ទេនាង! បងប្រាថ្នាប្រពន្ធសារិកាវិញ ប្រពន្ធបងមួយហើយ ជាសារិកាដូចនាងឯង បងគន់មើលមើលនាងអំពីចំពុះចុះទៅដល់ចំអេងស្លាប ដកបដល់ក្រចក បងរកត្រង់ណាជាប្លែកនឹងសារិកាប្រពន្ធបងនោះគ្មានឡើយ បងគន់មើលមើលនាងទំនៅទ្រនំហើយ បងយល់នាងកាងចំអេងស្លាបទទាបទទះទទេរហើរចេញទៅនោះ យល់ល្អាក់ល្អមផ្សារស្រីជាបក្សីក្នុងក្រង់នោះ បងស្ដាប់ភាសាសំដីស្រដីមូល-

មនុស្សក្រអៅស្រទន់ផ្កាស្រីនោះ ពុំប៉ូកទឹងសារិកាប្រពន្ធបងឡើយ ។

អជ និ សា ចុច្ចិ លំដាប់នោះ រីសារិកាស្ដាប់ពាក្យសេក-សោមបណ្ឌិតហើយ ទើបសារិកាជណ្ដឹងវិញថា សម្ម សុរិបណ្ឌិត ហៃសេកសោមបណ្ឌិតសំឡាញ់ប្អូនអើយ! ប្អូនស្ដាប់ពាក្យនោះហើយ ប្អូនឆ្ងល់អ្វីម្ល៉េះទេ? អ្នកប្រាប់ប្អូនថា អ្នកមានករិយាដូចប្អូនហើយហ្ន៎: អ្នកថាប្រពន្ធនោះកលម្ដេចហ្ន៎? ប្រពន្ធទៅនៅឯណា ទៅប្រាប់ប្អូនមើល? ។ សេកសោមបណ្ឌិត ស្ដាប់ហើយឆ្លើយវិញថា ខស្រីសារិកាប្អូនពុំងាបងអើយ! បងនឹងថ្លែងអំពីដើមប្រពន្ធបងនោះមិនបានឡើយ នាងនាងក៏ដូចគេយកឈើមកប្រហកអំពីចំពុះ ចុះទៅដល់បំពង់ក បងនឹងរិះរកស្រដីពុំបានឡើយ ក៏ចង្អៀតអស់ជាម្ដងណានាង សារិកាជណ្ដឹងថា ហៃសេកសោមបណ្ឌិតសំឡាញ់ប្អូនអើយ! ម្ដេចដល់ម៉្លោះ អម្បាលអម្ចាស់ប្អូនប្រាប់ប្អូនបន្ដិចភា សេកសោមបណ្ឌិតថា ហៃសារិកាប្អូនពុំងាបងអើយ! ទ្រុងបងក៏ចង្អៀត បងខំឆ្លៀតប្រាប់នាង សារិកាអើយ! ប្រពន្ធបងនោះខ្ញុំក៏ឆាបយកបាត់ទៅហើយ នាងអើយ! បើគេដោយដំណើរនោះហើយ បងរៃរងស្រណោះអាលោះអាល័យក្រៃពន់ប្រមាណ ចូរនាងស្ដាប់បងនឹងខំប្រាប់ សារិកាអើយ មានកាលសម័យថ្ងៃមួយ ព្រះបាទអ្នកជាអម្ចាស់ ស្ដេចទៅប្រពាតលេងដោយនូវល្បែងទឹក មួយអន្លើនឹងអស់ស្រីព្រះស្នំក្រមការបរិវារច្រើន ព្រះអង្គបន្ទូលហៅបងថា សេក-

សោមបណ្ឌិតអើយ ! មកឯកាយ ទៅលេងនឹងអញ សារិកានាងអើយ! វីក្រិតវៀបងទៅលេងឯណា ។ មួយក្តី នឹងទៅហៃព្រះបាទអ្នកជាអម្ចាស់ក្តី បងតែងនឹងយកប្រពន្ធបងនោះទៅផង មិនដែលឃ្លាតឡើយ កាលទៅងូតទឹកហៃព្រះអង្គនោះ បងយកសារិកាប្រពន្ធបងនោះទៅផង នេះហោង ព្រះអង្គស្រង់ទ្រង់ក្រសាលនឹងព្រះរាជទេពីស្រីព្រះស្នំ អញនឹងគាត់នេះយើងចុះទៅងូតទឹកហៃព្រះអង្គនោះទៅលេងលុះល្ងាចទន់ ។ ទើបព្រះអង្គឡើង ស្តេចមកគង់លើប្រាសាទហើយ យើងលាព្រះអង្គចេញអំពីបន្ទប់ទៅទំហាលស្លាប នាផ្ទៃផងក្តារប្រាសាទតែពីរនាក់ឯង កាលនោះ សារិកាញីគាត់មានគភ៌ណាស់ហើយ ហៀបនឹងប្រសូតហើយ យើងទាំង ២ ហាលស្លាបនឹងនាងសារិកា ឲ សារិកានាងអើយ ! នោះខ្លែងហោះទ្រើសឃ្នងក៏ហើរមកពីទិសឯណាមិនដឹងឡើយ ឮតែសព្ទសន្ធឹកធ្លូវគ្រជូរមកដល់ហើយ សារិកានាងអើយ! វីអញជាប្រុសមានកំឡាំងហើយហើររួច ឯគាត់ឯណាជាស្រីកំឡាំងតិច ហើយក៏ធ្ងន់នឹងគភ៌សោត នឹងហើរចេញពុំរួចឡើយ ក៏ឆាបគាត់បានទៅហោង សារិកានាងអើយ ! នាអញមើលទៅយល់ក៏ហើយ ដូចនឹងជាច់ខ្យល់អញស្លាប់ផង បំផ្លើសលេងឯក្រៅ នៅតែនឹងទុក្ខសម្រក់ទឹកភ្នែក ដូចនឹងបែកទ្រូងជាពីរ វីអាហារពោះបីលាជមួយដុំ ឬទឹកឃ្មុំមួយដំណក់ សូម្បីនឹងជិតនាប់ពុះនោះគ្មានឡើយណា នាងអើយ ! ក៏ឥតទំនេរល្ហៃល្ហើយ ឥតស្បើយនឹង

រក្សាក្រឡាបន្ទំក្រមព្រះបាទចុលនីសត្វថៃឯង ឥតបក្សីដទៃក្រៅជាគំរប់ពីរ ទុក្ខនោះដល់តិចឡើយ គ្រន់ណាហៅសុខប៉ុនល្អងបង់ពុំដែលមាន លុះ លង់ទៅតិច ព្រះបាទអ្នកជាអម្ចាស់ត្រាស់រកថា សេកទៅឯណាមិនមក គាល់អញហ៎ះ? នេះហោង ទើបបង់ទៅគាល់ ក៏ធ្លាប់រេងតែអញនឹង សារិកាទំទន្ទឹមផងគ្នាគាល់ស្តេច នេះម្តេចឡើយ សារិកាញីបាត់ស្ងាត់នៅ តែអញម្នាក់ឯង គិតរៀងពីដើមមកនោះវាស្រណោះពេកណាទានអើយ ! នឹងទប់សំណោកពុំបាន មានទឹកភ្នែកហូរស្រោកអំភ្លាង ព្រះអង្គដណ្តឹង ថា សេកសោមបណ្ឌិតអើយ ! មកគាល់អញម្តេចទាំងទឹកភ្នែកដូច្នេះហឹង? នេះហោងបង់ទូលព្រះអង្គថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃម្រសើរអើយ! ខ្ញុំសោកស្តាយសារិកាប្រពន្ធខ្ញុំស្លាប់ ព្រះអង្គទ្រង់ព្រះករុណាថាដូច្នោះហ៎ះ អាសូរសេកសោមបណ្ឌិត ក៏យំកណ្តាលដំទំពេងសាលា ខ្មាសគេមិនគួរ សមសន្សឹមដើរហើរទៅរកប្រពន្ធទៀតអេះ ទើបអញទូលថា បពិត្រព្រះ សម្មតិទេពក្សត្រថ្លៃប្រសើរអើយ ! ព្រះអង្គទ្រង់ព្រះករុណាពិសេសហោង ខ្ញុំនឹងទៅរកប្រពន្ធទៀត ធ្វើម្តេចនឹងបានដូចសារិកាប្រពន្ធខ្ញុំនោះ ក្រខឹង បានចិត្តទូលាយ ចរបាពុំគន់សីលមារយាទដោយច្បាប់ស្រី ពុំប្រណិប័តន៍ ប្តីស្វាមីទុកស្មើអម្ចាស់នោះឡើយ មិនយូរឡើយ ព្រះអង្គបន្ទូលប្រាប់ មួយរំពេចនោះឯងថា ហៃសេកសោមបណ្ឌិត អញគិតទើបយល់ហ៎ះ គេ ប្រាប់អញថា មានសត្វបក្សីស្រីសារិកាញីមួយ ប្រកបដោយមារយាទ

បានឮគេច្បាប់បក្សីស្រីសត្វសារិកាញីនោះឯងថា  សារិកានោះឯង  តែងបាទៅមើលថា  បើសារិកានោះឯង  ក្រែងគេអភិកាសមូលចូលចិត្តនឹងបាជាសង្សារហើយ  បាក្រឡាប់មកប្រាប់អញ ។ នឹងប្រដាប់នូវគ្រឿងបណ្ណាការ  នឹងបរិពារឲ្យអធិកមហិមា  ប្រកបនូវបុក្សពារទិដ្ឋស្មស្តីអំពីអរិដ្ឋបុរីស្រីមហានគរយើងនេះ  ទៅកាន់នគរឧត្តរបញ្ចាល  ជាមិត្តមេត្រីនឹងព្រះបាទចុលនីព្រហ្មទត្ត  គិតមូលផងគ្នា  ហើយក៏ធ្វើអាពាហ៍ពិពាហ៍បានឹងសារិកាជាប្តីប្រពន្ធហោង  ហៃស្រីសារិកាមាសថ្លៃបងអើយ !  នាបងសង្វាតឧហាតមក  បទនេះហោង  សេកប្រាប់ហើយ  សូត្រជាបទគាថាដូច្នេះ :

តស្ស  កាមា  ហិ  សម្មតោ  អាគតោ  តវន្តិកោ
សចេ  ករេយ្យាសិ  ឧកាសំ  ឧកយោវ វសេម្ហ សេតិ ។

សាលិកេ  ហៃស្រីសត្វសារិកាពុំងាបងអើយ !  នាបងឧហាតសង្វាតមកនេះ  ឲ្យបានដល់យល់នាង  បទតែឲ្យបាននាងជាសាច់សង្សារក៏ឯចិត្តនាង  តើញុំាងគិតស្នេហ៍វិញមកបង  ជាសាច់សង្សារឬទេ ? ហៃស្រីសត្វសារិកាប្អូនកុំថា  បើបានអភិកាសបងនៅ  ក៏យើងទាំងពីរនឹងបានស្នេហ៍ស្និទ្ធជាមិត្តសង្សារនៅនេះនឹងគ្នាហោង ។

រីសារិកាស្តាប់ពាក្យសេកសោមបណ្ឌិតហើយ  មានចិត្តត្រេកអរស្មោះសរនឹងសេកក្រៃពេក  គឺមោះកាយមារយាទអាត្មាជាស្រីស្រដីតែមាត់

ទេ ថាជាពុំប្រាថ្នាមិនឲ្យសេកដឹង វែសារិកាចិត្តកន្ទេនគិតទៅសេកមហា·
មា ឯមាត់តែស្រដីថាពុំប្រាថ្នា ធ្វើយទៅកាន់សេកជាបទគាថា ដូច្នេះ :

សុភេវ សុរី កាមេយ្យ សាលិកោ បន សាលិកំ
សុវស្ស សាលិកា យេវ សំភសោ ហោតិ តាទិសោតិ ។

សន្ធ សុវបណ្ឌិត វៃហទៅសេកសោមបណ្ឌិតមិត្តសំឡាញ់
ប្អូនអើយ ! នាងដោយពាក្យទៅចរចាស្រដីថា ទៅនឹងមកនៅនឹងអញ នេះ
ជាការគាប់ហោង តែយល់សើវើថា សត្វពូជពង្សពុំស្មើដូចគ្នា គឺសេក
នឹងសេកនោះជាគូនឹងគ្នា សារិកានឹងសារិកានោះជាគូនឹងគ្នា កំឡូវនេះ
ទៅជាសេកប្អូនជាសារិកា មកជាគូនឹងគ្នានោះ នឹងមានជំនៀលលោក
ជៀលថា ៖ ! សារិកាអើយ ខ្លួនជាសារិកាគួរជាគូនឹងសារិកាដូចគ្នាអេះ
ម្ដេចឡើយក៏ស្រើបស្រាលសើវើតក្អើលលើ មកដោយឯសេកវិញហ្ន៎
ប្អូនថប់ណាស់ហោង ៗមួយនោះលែងពោះយោបីលោកនឹងជៀលថា ស្រី
សើវើស្រើបស្រាលធ្លោយដោយចៅទៅហោង សេកសោមបណ្ឌិតទៅ
អើយ ប្អូនថប់មួយទៅឥឡូវនេះ ទៅជាសេក អញជាសារិកា បើនឹង
បង្កើតបុត្រផងគ្នា កើតនឹងជាម្ដេចទៅអើយ ពនឹងជាសេកឬពនឹងជាសា·
រិកាហើយប្អូនថប់នោះក្រៃ ។

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គង់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

## ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ "ក"

(តមក)

— R —

| | | |
|---|---|---|
| Rapporter (v. t) | លើកចោល : លើកចោលអត្ថបទមួយ គឺបដិសេធអត្ថបទនេះ ដែលឲ្យមានផល ចាប់តាំងពីថ្ងៃចុះហត្ថលេខាដំបូងមក បានសេចក្ដីថា អត្ថបទនេះ ទុកដូចជាមិនដែលមាន ។ | |
| Biens actifs | ទ្រព្យសកម្ម ។ | |
| Biens passifs | ទ្រព្យអកម្ម ។ | |
| Biens (n m) | ទ្រព្យ ។ | |
| Biens mobiliers | ចលនទ្រព្យ | (ពប្ល) ។ |
| Biens immobiliers | អចលនទ្រព្យ | (ពប្ល) ។ |
| Biens meubles | សង្ហារិមទ្រព្យ | (ពប្ល) ។ |
| Biens immeubles | អសង្ហារិមទ្រព្យ | (ពប្ល) ។ |
| Fortune (n.f.) | សម្បត្តិ | (ពប្ល) ។ |
| Héritage (n.m.) | មត៌ក ។ | |

| | |
|---|---|
| Interdire (v.s.pr.) | ហាមឃាត់ : ហាមជនណាម្នាក់មិនឲ្យធ្វើអ្វីមួយ ។<br>ឧ. គ្រូពេទ្យហាមឃាត់អ្នកជម្ងឺ មិនឲ្យសេពសុរា ។ |
| Ivre | ស្រវឹង ។ |
| Ivresse (n.f.) | ភាពស្រវឹង ។ |
| Ivrogne (n.m.) | មនុស្សស្រវឹង ។ |
| Ivrognerie (n f.) | ភាពប្រមឹក ។ |
| Ivrogne invétéré | មនុស្សស្រវឹងដោក ។ |
| Opiomane (n.m.) | មនុស្សជក់អាភៀន ។ |
| Opiomane invétéré | មនុស្សជក់អាភៀនដោក ។ |
| Opiomanie (n.f.) | ការជក់អាភៀន ។ |
| Opiomanie invétéré | ការជក់អាភៀនដោក ។ |
| Patrimoine (n. m.) | បេតិកភណ្ឌ (ត្រូវអានថា : បេតិកៈភណ្ឌ) ។ |
| Sénilité (n. f.) | ភាពចាស់ជរា ។ |
| Sénile (adj.) | ចាស់ជរា ។ |
| Vieux (n.m.) | មនុស្សចាស់ ។ |
| Vieillesse | ភាពចាស់ ។ |
| Rectifier un texte | កែសម្រួលអត្ថបទ (ពប្ប) : កែសម្រួលអត្ថបទ<br>គឺផ្លាស់ពាក្យនៃអត្ថបទនោះ ប៉ុន្តែគតិនៃអត្ថបទ<br>នោះនៅដដែល ។ |
| Rectification d'un texte | ការកែសម្រួលអត្ថបទ (ពប្ប) ។ |
| Règles communes | វិធានសាទីស (ពប្ប) ។ |
| Relations incestueuses | ការទាក់ទងខាងស្នូទ (ពប្ប) ។ |

| | |
|---|---|
| Réintégrer le domicile conjugal | ត្រឡប់មកលំនៅសង្វាសវិញ (ពប្ប) ។ |
| Réintégration du domicile conjugal | ការត្រឡប់មកលំនៅសង្វាសវិញ (ពប្ប)។ |
| Respect du foyer conjugal | គារវៈចំពោះក្រានសង្វាស (ពប្ប) ។ |

— S —

| | |
|---|---|
| Siège ( n.m. ) | ទីសំណាក់ការ (ពប្ប) ។ |
| Situation de la femme mariée | ស្ថានភាពនៃស្ត្រីមានប្តី (ពប្ប) ។ |
| Sommer de faire | ដាក់កំហិតឲ្យធ្វើ ។ |
| Sommation de faire | ការដាក់កំហិតឲ្យធ្វើ ។ |
| Sommer de réintégrer le domicile conjugal | ដាក់កំហិតឲ្យត្រឡប់មក លំនៅសង្វាសវិញ (ពប្ប) ។ |
| Sommation de réintégrer le domicile conjugal | ការដាក់កំហិតឲ្យត្រឡប់មកលំនៅ សង្វាសវិញ (ពប្ប) ។ |
| Sourd ( n.m. ) | មនុស្សថ្លង់ ។ |
| Sourd ( adj ) | ថ្លង់ ។ |
| Surdité ( n.f. ) | ភាពថ្លង់ ។ |
| Subdiviser l'étude du droit | ចែកបន្តការសិក្សា នៃនីតិសាស្ត្រ ( ពប្ប )។ |
| Subdivision de l'étude du droit | ការចែកបន្តការសិក្សា នៃនីតិសាស្ត្រ( ពប្ប)។ |

— A —

| | |
|---|---|
| Actes judiciaires . . . . | លិខិតតុលាការ ។ |
| Actes extrajudiciaires . . | លិខិតក្រៅតុលាការ ។ |

Avances (n.f.pl.) . . . . ប្រាក់ផ្តល់មុន ។

— B —

Blessures ( n.f.pl ) . . . របួស ។

— C —

Caisse d'avances . . . បេឡាផ្តល់មុន ។

Connaissance relative . . . ការចេះដឹងជាសាបេក្ខ ។

Convoler en secondes noces . រៀបអាពាហ៍ពិពាហ៍លើកទី ២ ។

Coups ( n.m.pl. ) . . . ការវាយដំ ។

Curatelle (n.f. ) . . . ហិតូបត្ថម្ភ : មុខងារនៃហិតូបត្ថម្ភក៍ ។

Curateur (n.m.) . . . ហិតូបត្ថម្ភក៍ : បុគ្គលដែលច្បាប់តាំងឲ្យគាំ-
ពារអនីតិជនអត្តាធីន ឬមនុស្សកញ្ជះកញ្ជាយ
អ្នកសតិទន់ខ្សោយ អ្នកពិការ មនុស្សប្រមឹក
ជោក មនុស្សជក់អាភៀនជោក ក្នុងការគ្រប់
គ្រងទ្រព្យនៃជនទាំងនេះ ។

— D —

Dément ( n.m. ) . . . មនុស្សវិកលចរិត ។

Démence ( n.f. ) . . . ភាពវិកលចរិត ។

Dispensaire municipal . . . . ឱសថាល័យក្រុមមឿង ។

Divorcer d'avec . . . . . . លែងលះ ( ពប្ញ ) ។

Docteur en médecine . . . . វេជ្ជបណ្ឌិត ។

Donation entre vifs . . . . . អំណោយកាលនៅរស់ ។

( នៅមានត )

# វចនានុក្រមសំស្រ្កឹត-ខ្មែរ

*ព្រះមហា ចាំង-ចាត់ រៀបរៀង*

(តមក)

---

អតិសិតាង្គវិហង្គ បុ. ហង្ស ។

អតិសិទ្ធិ ស្ត្រី. សិទ្ធិក្រៃលែង សេចក្ដីសម្រេចក្រៃលែង ។

អតិសុកុមារ គុ. ដែលខ្ចីក្រៃពេក ដែលក្មេងក្រៃពេក ដែលទន់ភ្លន់ក្រៃពេក ។

អតិសុខ គុ. ដែលសុខក្នុង ដែលស្រួលក្រៃលែង ។

អតិសុគម គុ. ដែលចូលទៅជិតបានក្រៃលែង ។

អតិសុភគ គុ ដែលល្អក្នុង ដែលប្រពៃក្រៃលែង ។

អតិសុរភិ គុ. ដែលក្រអូបក្រៃលែង ។

អតិសុលភ គុ. ដែលបានងាយក្រៃពេក ។

អតិសុវ្ឫត្ត គុ. ដែលប្រព្រឹត្តល្អក្រៃលែង ដែលមូលក្នុង ។

អតិសុក្ឫ្ម គុ. ដែលល្អិតក្រៃលែង ដែលឆ្មារក្នុង ។

អតិសឫជ ធាតុ. លះបង់ បង្សតបង់ ឲ្យ យល់ព្រម ។

អតិសឫ្ដិ ស្ត្រី. ការកសាងក្រៃលែង ការកសាងប្រសើរ ។

អតិសោកុមារ៍ ឧបុំ. ភរិយា.. ក្មេងក្រៃពេក ។

អតិសោជន្យ ឧបុំ. ភរិយា.. ជាជនក្រៃលែង ភរិយា...ជាជនប្រសើរ។

អភិជនក្រៃលែង អភិជនប្រសើរ ។

អតិសោបណ៌ គុ. ដែលជាក្រុមក្រៃលែង ដែលជាក្រុមប្រសើរ ។

អតិសោភិត្យ ឧបុំ ភរិយាជនបរិភោគក្រៃលែង ។

អតិសុល គុ. ដែលថ្លោះក្រៃលែង ដែលក្រាស់ក្រៃលែង ។

អតិស្ថិធ គុ. ដែលទន់ភ្លន់ក្រៃលែង ដែលទងវែងកន្លង ។

អតិស្នេហ គុ. សេចក្ដីស្នេហាក្រៃលែង ធំក្រៃលែង ។

អតិស្បធិធ គុ. ដែលប្រណាំងប្រជែងក្រៃលែង ។

អតិស្ពុជ គុ. ដែលប្រាកដក្រៃលែង ដែលជាក់ច្បាស់ក្រៃលែង ។

អតិស្វរ ធាតុ. ស្វះក្រៃលែង ស្រែកក្រៃលែង ។

អតិស្វល្ប គុ. ដែលតូចក្រៃលែង ។

អតិហាស៍ បុំ សេចក្ដីកភាយក្រៃលែង ។ អតិហប៉ុល គុ. ដែល

សប្បាយក្រៃលែង ។

(នៅមានត)

# រឿងល្បើកឡាហ្វុងតែន (La Fontaine)

លោក ដេង-ជ្រីវ ប្រែរៀបរៀង

---

តាមអំពើចិត្ត ។

រឿងនេះបានជាគតិថា: ការយល់ឃើញរបស់អ្នកមានអានុភាព តែងត្រូវនិយមទុកជាប្រសើរទាំងអស់ ។

## ១៣– ក្តាន់នឹងទំពាំងបាយជូរ

ក្តាន់មួយត្រូវពួកអ្នកដាក់បង្កាត់ដេញតេទៅជ្រកពួន នឹងដើមទំពាំង-បាយជូរ ។ ដោយអំណាចទំពាំងបាយជូរមានស្លឹកលូតលាស់វែងបិទបាំង ក្តាន់បានរួចរស់ជីវិតដោយសារ ។ ពួកព្រានស្មានថា ឆ្កែគេដានមិនឃើញ ក៏ហៅឆ្កែឲ្យត្រឡប់មកវិញ ។ លុះបានរួចពីគ្រោះថ្នាក់ ក្តាន់ស៊ីទំពាំងបាយជូរ ដែលជាអ្នកធ្វើសេចក្តីល្អដល់ខ្លួនពីលើកមុន ទាល់តែអស់រលីង នេះគឺជាសេចក្តីអកតញ្ញូពេញទី មិនយូរប៉ុន្មាន គេមើលឃើញ គេត្រឡប់មកវិញ ហើយដេញម្តងទៀត សត្វនោះគ្មានទីជម្រក ក៏ដល់នូវសេចក្តីវិនាស ។

រឿងនេះ ជាគតិដល់អ្នកដែលបំផ្លិចបំផ្លាញទីកន្លែងដែលខ្លួនបានជ្រកហើយ ។

# ១៤- ចចកតែងខ្លួនជាអ្នកគង្វាលចៀម

ចចកមួយអាស្រ័យនៅជិតពួកចៀម តែវាមិនដឹងធ្វើយ៉ាងណាទើងអាចចាប់ចៀមបាន ព្រោះឆ្កែប្រសប់ពេក ។ វាយកគំនិតកញ្ច្រោងមកជាជំនួយ ហើយតែងខ្លួនជាគេថ្មី គឺស្លៀកខោអ្នកគង្វាល ពាក់អាវដៃធំមានទាំងដំបងព្រមទាំងខ្លុយផង ។ ដើម្បីបញ្ចប់ការបន្លំឲ្យអស់ដើងវាថែមទាំងសរសេរដាក់នៅមួកថា " ខ្ញុំហ្នឹងហើយឈ្មោះហ្គីយោជាអ្នកគង្វាលនៅហ្នឹងនេះ" ។ រៀបចំស្រេចហើយ ដើងមុខទាំងពីរកាន់ដំបងហ្គីយោថ្មីដើរចូលទៅសឹម ៗ ។ ចំណែកហ្គីយោអ្នកគង្វាលមែនទែនដេកស្ពូកស្ពឹងលើស្មៅខ្ចី ស្រមុកខ្លាំងៗ ។ ដើម្បីកៀងចៀមឲ្យបានទៅដល់ទីកន្លែងខ្លួន ចចកបង់ចន្ទែមសំដីទៅជួយខោអាវទៀត ដោយគិតស្មានថាសំដីជាការចាំបាច់ ។ តែវាតែហ្នឹងនាំឲ្យខូចការសោះ ។ ចចកមិនអាចធ្វើសំឡេងឲ្យដូចជាសំឡេងអ្នកគង្វាលបាន វាស្រែកឡើងឮអស់ទាំងព្រៃដូចជាបើកកកាយការសម្ងាត់អាត្មាឲ្យគេឮអស់ ។ គេភ្ញាក់ពល់គ្នា: អ្នកគង្វាល ឆ្កែ ចៀម ។ អាខ្លះស្រែក អាខ្លះទះដៃ ចចកស្ទន់រករត់ទៅណាប្តូទីងការពារក៏ពុំកើត ព្រោះទើសទីងខោអាវប្រវែងប្រវ៉ាង ។

អ្នកណាជាចចក គប្បីប្រព្រឹត្តតាមភាពជាចចក នោះជាការគាប់ប្រសើរច្រើន ។

(សុភាសិតខ្មែរ: ការមិនសន្ទ្រឹមវាចា រមែងនាំឲ្យខាតបង់) ។

## ១៥– សិង្ហចាស់

សិង្ហចាស់មួយ ពីដើមធ្លាប់ជាទីគោរពខ្លាចនៃសត្វទាំងអស់ក្នុងព្រៃ ។ កាលខ្លួនជរាខ្លាំង នឹកស្តាយកម្លាំងពីដើម ព្រោះត្រូវពួកសត្វឯទៀតធ្វើបាបវិញ ដោយហេតុខ្លួនមានកម្លាំងទន់ខ្សោយ ។

សេះមួយចូលទៅព្រាយមួយជើង ចចកខាំមួយចង្កូម គោឈែមួយស្នែង ។ សិង្ហរងទុក្ខវេទនា មុខស្លុត មានចិត្តស្រងូតស្រងាត់ ស្រែកស្ទើរមិនរួច ព្រោះចាស់ពេក ។ សិង្ហទទួលទុក្ខតាមកម្ម គ្មានស្រែកថ្ងូរបន្តិច តែដល់ឃើញសត្វលារត់មកបំរុងទំនាត់មួយជើងដូចគេដែរ សិង្ហលោបញ្ចេញសំដីថា: ណ្ហើយ ! កុំអី ! ដូចជាជ្រុលពេកណាស់ ខ្ញុំស៊ូស្លាប់ជាជាង មិនឲ្យជើងអ្នកឯងមកប៉ះសាច់ខ្ញុំឡើយ ។

## ១៦– ទន្សាយនិងកង្កែប

មានទន្សាយមួយនៅក្នុងរូង ចេះតែដេកជញ្ជឹង ( នៅក្នុងរូងមិនដឹងធ្វើអ្វីប្រសិនមិនគិត ) ទន្សាយនេះអផ្សុកពេកតាំងតែនឹក: ព្រោះសត្វនេះព្រួយ ហើយការភ័យខ្លាចចេះតែគកូរក្នុងខ្លួនផង ។ វានឹកថា: ជាតិអ្នកខ្លាចច្រើន សុទ្ធតែអ្នករងទុក្ខវេទនា មិនដែលស៊ីអ្វីឲ្យឆ្ងាញ់ដូចគេ គ្មានសេចក្តីរីករាយសប្បាយឡើយ មានតែសេចក្តីបារម្ភជានិច្ច អញយល់ដូច្នេះថា ការភ័យខ្លាចចង្រៃនេះ ធ្វើមិនឲ្យអញដេកលក់បាន ឲ្យនៅតែ

បើកក្អែកហូត អ្នកមានប្រាជ្ញាល្អនិយាយថា: ត្រូវឲ្យរៀនលះបង់ចេញដោយខ្លួនឯង តើគេអាចលះការខ្លាចចោលបាន ? បើតាមអញ ៗ យល់ថា: មនុស្សទាំងអស់សុទ្ធតែមានការភ័យខ្លាចដូចអញអ៊ីចឹងដែរ ។

សត្វទន្សាយនឹកជញ្ជឹងដូចអធិប្បាយខាងលើ ហើយខណៈនោះ វាប្រុងចាំទៅមាត់ទន្លេ ចេះតែសង្ស័យរសាប់រសល់ ខ្យល់បក់ស្រមោលអ្វីបន្តិចក៏ដោយ តែងធ្វើឲ្យវាភ្ញាក់ភ័យ ៗ សត្វក្រៀមក្រំនេះ កំពុងតែគិត ៗ ស្រាប់តែឮសូរអ្វីស្រឹប វានឹកថា ផលហើយ បើដូច្នេះ ត្រូវស្ទុះចេញពីរូងទៅក្រៅខាងនោះសិន ។ ទន្សាយស្ទុះរត់ទៅលើមាត់ត្រពាំង ស្រាប់តែកង្កែបភ្ញាក់ភ័យ លោតបុះក្នុងទឹកក្ដុង ៗ ពួនអស់ ។ ទន្សាយនឹកថា ឱ! អញក៏ធ្វើឲ្យគេខ្លាចដូចជាគេធ្វើឲ្យអញខ្លាចដែរ! អញមកក៏គង់មានគេខ្លាចដែរ! បើដូច្នេះ មិនគឺអញយកការភ្ញាក់ផ្អើលមកក្នុងទីនេះ តើអញបានអំណាចបារមីពីណាមក? ឱ! មានសត្វខ្លះ ឃើញអញមកគិតភ័យញាប់ញ័រដែរ! បើអ៊ីចឹងអញជាមេចម្បាំងមួយទេតើ! អញយល់ច្បាស់ថាគ្មាននរណាផ្អើលចោលមៀតជាងអ្នកណាទេ ៗ នៅលើផែនដីនេះ អ្នកណាអាចរកបាននរណាដែលមិនភ្ញាក់ផ្អើលជាងខ្លួន ។

## ១៣- សត្វលានិងផ្លែតឿ

ចូរយើងកុំបន្ទំចំណេះរបស់យើងឲ្យហួសព្រំដែន យើងមុខជានឹងធ្វើមិនបានប្រសើរ ឬមិនបានសម្រេចដូចបំណង ។

មានសត្វលាមួយ ចង់ឲ្យម្ចាស់រាប់អានកំនឹកក្នុងចិត្តថា "ហេតុអ្វី ឆ្កែតូចនេះ ក៏ម្ចាស់ប្រុស-ស្រីស្រឡាញ់ដូចជាមិត្តរបស់គាត់ ចំណែកអញនេះតែត្រូវដំបង ពីព្រោះឆ្កែនេះតូច ហើយគួរឲ្យស្រឡាញ់ តើវាធ្វើអ្វីដល់ម្ចាស់! មើលទៅឃើញតែវាលើកជើងគំនាប់ ហើយស្រាប់តែម្ចាស់បបោសអង្អែលស្រឡាញ់វា ប្រសិនបើជាធ្វើឲ្យគេស្រឡាញ់ដូចជាការណ៍នេះ មិនមែនជាក្រ គឺងាយសោះ ។

កំពុងតែគិតដូច្នោះ ស្រាប់តែឃើញម្ចាស់ដើរមកទឹកមុខញញឹម លាដើរសំដៅទៅរក លើកជើងមួយ ក្របកគគ្រាត ថ្ពមអស់ពីចិត្ត ហើយដូតចង្កាម្ចាស់ មិនតែប៉ុណ្ណោះ ដើម្បីសំដែងសេចក្ដីសប្បាយនឹងការរាប់អាន វាស្រែកសម្លេងយ៉ាងពីរោះបន្ទរថែមទៀត ។

ម្ចាស់ស្រែកថា "យី! យី! ការបបោសអង្អែលឬ? ព្រៀងបន្ទរឬ? ចុះដំបងនៅឯណា! លុះដំបងមកដល់ លាទើបដឹងខ្លួនថា ការធ្វើដូច្នេះ មិនគាប់ប្រសើរឡើយ ។

## ១៨- សិង្ហនិងលាបរបាញ់រកចាប់សត្វ

ថ្ងៃមួយ សិង្ហជាស្ដេចសត្វទៅបរបាញ់ ពីព្រោះជាថ្ងៃបុណ្យរបស់គេ ។ ពួកសត្វដែលសិង្ហបំរុងរកចាប់មិនមែនសត្វតូចទេ សុទ្ធតែជ្រូកព្រៃ ក្ដាន់ រមាំង ប្រើស យ៉ាងធាត់ៗ ហើយស្អាតៗផង ។ ដើម្បីញ៉ាំងកិច្ចនេះ

ឲ្យសម្រេច សិង្ហប្រើទុកញាំលាដែលសម្រែកព្រួខ្វរខ្វារពេញព្រៃ ទុកញាំលាធ្វើជាស្នែង សិង្ហយកទៅឲ្យនៅមួយកន្លែង យកស្លឹកឈើគ្របជិត ហើយប្រាប់ឲ្យស្រែក ពាល់តែសត្វដែលមិនសូវភ្ញាក់ផ្អើលដូចម្តេច ក៏អត់ទ្រាំមិនរត់ចេញពីទីលំនៅមិនកើត ដ្បិតពួកសត្វទាំងនោះ មិនធ្លាប់ស្តាប់ឮសម្រែកលាសោះ ។

សម្រែកលាលាន់ឮ គួរជាទីស្ញប់ស្ញែងពេកណាស់ សេចក្តីភិត-ភ័យទៅគ្រប់សង្កត់សត្វក្នុងព្រៃគ្មានសល់ ម្រឹគទាំងឡាយផ្អើលភ្ញាក់ស្មុះរត់ទៅជាប់អន្ទាក់ធ្លាក់លើដៃសិង្ហចាប់បានទាំងអស់ គ្រង់កន្លែងដែលវាឃ្លាំចាំ ។

លាសប្បាយហើយពេញចិត្តនឹងចាប់សត្វបានច្រើន ទើបចេញសំដីថា: ម៉េចព្រះតេជព្រះគុណ ពេលនេះ ខ្ញុំធ្វើការល្អឬទេ ?

សិង្ហឆ្លើយថា មែន! ប្រសប់ស្រែកលេខ ១ ប្រសិនបើខ្ញុំមិនបានស្គាល់លោកឯង នឹងពូជលោកផង ខ្ញុំក៏គង់ភ័យរត់ដែរ ។

## ១៩- កញ្ជ្រោងនឹងរូបបដិមា

ពួកអ្នកធំ ច្រើនដូចជារូបបដិមា ឬជាមុខសម្រាប់ពាក់ ការឃើញមុខពួកនេះ តែងញុំាងអ្នកជម្នាគាឲ្យគោរពកោតក្រែង ដូចជាទេព្តា ។ សត្វលាចេះគោរពកោតតែរបស់អ្វីដែលឃើញនឹងភ្នែក ចំណែកកញ្ជ្រោងមិនដូច្នោះឡើយ គិតជ្រៅណាស់ ហើយពិចារណាឲ្យគ្រប់ទិសទើបថា បើ

កាលណាគេយល់ថា ការណ៍អស់ហ្នឹងគ្រាន់តែជារបស់ក្រៅទេ គួរយ៉ាងដូចជារូបបដិមាអ្នកខ្លាំងពូកែម្នាក់ ៗ មានរូបបដិមាមួយប្រហោងក្នុង តែធំជាងរូបធម្មតា ៗ សត្វកញ្ជ្រោងមានសេចក្តីសរសើរដល់កម្លាំងប្រាជ្ញានិងការបញ្ជាក់ថា៖ រូបក្បាលនេះល្អមែន ប៉ុន្តែ ពាស់គ្មានខួរ ៗ

## ២០- កូនត្រីនិងព្រានសំណាញ់

នាយនេសាទម្នាក់ បង់បានកូនត្រីប្រកែងមួយក្នុងស្ទឹង ៗ អ្នកនេសាទពោលថា "បានមួយនេះ ទុកជាម្ហូបដើមដំបូង បើដូច្នេះដាក់ក្នុងត្រកទៅ" ៗ

កូនត្រីព្រួយចិត្ត ទើបនិយាយអង្វរថា "លោកយកខ្ញុំទៅធ្វើអ្វី ប្រសិនបើស៊ីក៏មិនបានកន្ទះមាត់ផង សូមលោកមេត្តាលែងខ្ញុំ ទុកខ្ញុំឲ្យធំសិន ហើយលោកត្រឡប់មកបង់យកខ្ញុំវិញ មិនលែងមានគេទិញបានថ្លៃច្រើនជាងនេះ បើលោកខំប្រឹងរកត្រីប៉ុនខ្ញុំប្រហែលមួយរយយកមកធ្វើសម្ល មិនដឹងជាសម្លនោះដូចម្តេចផង សូមលោកជឿខ្ញុំចុះ សម្លបែបហ្នឹងគ្មានដំឡៃឡើយ" ៗ

នាយនេសាទឆ្លើយថា: "អើ! គ្មានដំឡៃក៏ហ៊ឺចុះ នែអាសំឡាញ់! ឯងទៅនិយាយអធិប្បាយប្រាប់គេ ក្នុងឆ្នាំងខ្ទះដែលគេកំពុងចៀនឯនោះចុះ ឯងទេសន៍ជាមួយអញឥតផលទេ ៗ

(មានសុភាសិតមួយសំដែងថា : "ចាបមួយនៅដៃ ប្រសើរជាង ដប់នៅដើមឈើ") ។

## ២១- ឆ្មាចាស់និងកូនកណ្ដុរ

កូនកណ្ដុរនៅក្មេងពេក មិនទាន់យល់ដឹងការណ៍សព្វគ្រប់ ស្មានថាខ្លួនអាចបន្ទន់ចិត្តឆ្មាចាស់បាន ទើបសុំឲ្យឆ្មាមេត្តា ហើយខំប្រឹងពន្យល់ឆ្មាដូច្នេះថា: "សូមលោកអាណិតទុកឲ្យខ្ញុំរស់នៅផង កណ្ដុរតូចមួយប៉ុនរូបខ្ញុំនឹងបំផ្លាញអ្វីអស់ប៉ុន្មានក្នុងផ្ទះនេះ ។ តើលោកយល់ថាខ្ញុំមើលងាយចៅហ្វាយប្រុស-ស្រីនឹងមនុស្សក្នុងផ្ទះហ្នឹងឬ ? ស្រូវតែមួយគ្រាប់ក៏ខ្ញុំអាចចិញ្ចឹមជីវិតបាន ស្វាមួយគ្រាប់ ខ្ញុំកកេរដល់គោងខ្លួនមិនទាំងបានសម្រេចផង ។ ពេលនេះ ខ្ញុំស្គមណាស់ សូមលោកចាំពេលក្រោយ សូមទុកខ្ញុំឲ្យជាចំណីកូនលោកជាន់ក្រោយទៅ ។ ឆ្មាឆ្លើយថា: អាឯងកាន់ប្រឡូរទេ យ៉ាងមុខអញ ឯងស្មានថាជាអ្នកទទួលអង្វរឬ? អាឯងទៅនិយាយឲ្យមនុស្សថ្លង់ស្ដាប់ល្អជាជាង ។ ជាតិជាឆ្មាហើយចាស់ផងឯងស្មានថាអញអត់ទោសឲ្យឬ ? មិនដែលមាន ! មិនដែលព្ទ ! ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៥០

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកកាងវៃឆ្លាតបើបានអាន
នឹងចេះទាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ
យូរ-អ៊ុន

ចូឆូជឹងកុងស៊ុនបុត្រនោះហើយក៏សួរទៀវស៊ុងថា ឡៅជៀងជានាយអ្នកឯងនោះ ច្រើនឆ្នាំហើយមិនដែលជូនគ្រឿងបណ្ណាការមកគំនាប់តាមទំនៀមទម្លាប់ប្រវេណីសោះ ព្រោះហេតុអ្វីបានជាធ្វើដូច្នេះ ទៀវស៊ុងជំរាបថា ស្រុកសែឈួននោះ ជាស្រុកដាច់ស្រយាលឆ្ងាយអាល័យកម្រដែលនឹងទៅមកពេកណាស់ មួយយ៉ាងទៀត អាណាខេត្រទាំងពួងក៏សុទ្ធតែកើតចំរូងចំរះមិនទាន់រាបទាបជាប្រក្រតី មានសេចក្តីខ្វាចបារម្ភក្រែងចោរកំណាច នឹងលើកគ្នាប្លន់ដណ្តើមយកគ្រឿងបណ្ណាការកណ្តាលផ្លូវបានជាមិនអាចនឹងនាំមកបាន ចូឆូក៏ស្រែកគំហកថា អញដើរប្រាប

ព្រាមសាណាខេត្រពាំងពួងកបពាបជាសុខក្សេមក្សាន្តអស់ហើយ ចោរឯណាដែលនៅមានទៀតសោត ។

ទៀវស៊ុនឆ្លើយថា ទិសឯត្បូងនោះស៊ុនគួនជាសត្រូវរបស់លោកក៏នៅមាន ទិសខាងលិចក៏គឺឡៅតៃ ទិសខាងជើងក៏គឺទៀវឡូ បើសត្រូវរបស់លោកនៅមានជុំខ្លួនដូច្នេះ ទីឯណាដែលលោកថាប្រាបប្រាមពបពាបហើយនោះ ចូច្នេះបានឮដូច្នោះក៏ខឹងណាស់ ពិនិត្យមើលរូបរាងទៀវស៊ុនឃើញលក្ខណៈពាបថោកមិនគាប់អធ្យាស្រ័យសោះ ក៏ក្រោកចូលទៅក្នុងបាត់ ទីប្រឹក្សាពាំងពួងក៏នាំគ្នានិយាយនឹងទៀវស៊ុនថា អ្នកនេះគ្មានអធ្យាស្រ័យសោះ ហ៊ានមកនិយាយផ្ទុញផ្តាល់មហាឧបរាជដូច្នេះគួរហើយឬ នេះបាក់តែអ្នកឯងបាននាំបណ្ណការមកថ្វាយពីចម្ងាយ បានជាមហាឧបរាជមិនយកទោស ត្រូវអ្នកឯងចេញទៅឲ្យឆាប់ ៗ ចុះកុំបីនៅឲ្យយូរឡើយ ។

ទៀវស៊ុនឆ្លើយថា ខ្លួនខ្ញុំនេះជាអ្នកស្រុកសែឈួនមិននិយាយអ្វី ៗ ក៏ទៅតាមត្រង់ មិនបានយកសេចក្តីវៀចមកបរបាប្រចុចប្រចៃងដូចមនុស្សឯទៀតទេ អៀវស៊ុះឮដូច្នោះក៏ស្រែកគំហកថា ខ្លួនជាអ្នកស្រុកសែឈួនចរចាសុទ្ធតែត្រឹមត្រង់ យើងពួកស្រុកក្រុងនេះ អ្នកឯងឃើញនរណាជាអ្នកនិយាយប្រចុចប្រចៃងសោត ទៀវស៊ុនងាកមុខមកមើលអៀវស៊ុះឃើញរូបរាងស្អាតបាត ដែលជាអ្នកមានវោហារពេះពរោះ ក៏ភ្ជួយសួរទៅ

ថា អ្នកនេះឈ្មោះអ្វី មហាចុបកជតាំងឲ្យធ្វើនាម៉ឺននិយាយការខាងអ្វី អៀវស៊ីវឆ្លើយតបថា យើងឈ្មោះអៀវស៊ីវជាពួករក្សាឃ្លាំងមហាចុបកជ ។

ទៀវសុងជឹងថា អៀវស៊ីវជាមនុស្សមានសតិបញ្ញាក៏សន្ទនាប្រាស្រ័យដោយសុភាព អៀវស៊ីវឃើញទៀវសុងប្រកបដោយអធ្យាស្រ័យស្រួលបួលហើយ ក៏នាំទៅឯផ្ទះហើយចាត់ចែងឲ្យអង្គុយទីសមគួរហើយសួរថា ស្រុកសៃឈួននោះផ្លូវឆ្ងាយដាច់អាល័យណាស់ អ្នកខស្វាហ៍មកដល់ស្រុកក្រុងនេះបាន ទៀវសុងថាខ្ញុំបាបព្រាវគេ ហើយបើនាយចៅហ្វាយប្រើក៏ត្រូវតែទៅ ទោះបីផ្លូវដែលទៅនោះ លុយទឹកកក់ល្បាប់ ឬលុយភ្លើងក៏ត្រូវតែទៅឲ្យបាន អៀវស៊ីវថា ស្រុកសៃឈួននោះ ភូមិឋានជាបែបយ៉ាងម្តេច ។

ទៀវសុងថា ឯស្រុកសៃឈួននោះ មានភូមិឋានធំទូលាយស្រណុកសប្បាយណាស់ ពីដើមគេហៅថាស្រុកអេកជីវ ទិសឯត្បូងនោះមានស្ទឹងគិមកាំងខាំងម្នាង ទិសឯជើងមានគយកៀមកុក ផ្លូវដែលនឹងទៅមកក៏ចង្អៀតពិបាកណាស់ ហើយស្រុកនោះមានបរិមណ្ឌលចំនួន ៣០០០ សិន (១.២០០ គ.ម ) មានរយៈភូមិល្មមមាន់រងាវឮដល់គ្នា ទាំងត្រីអង្ករចំណីត្រីសាច់ក៏បរិបូណ៌ជាទីស្រួលសប្បាយជាជាងស្រុកដទៃ អៀវស៊ីវសួរថា បណ្តាភ្នាក់ងារខ្ញុំរាជការក្នុងស្រុកសៃឈួននោះ មានអ្នកណាមានសតិបញ្ញាដែលនឹងគិតការពារទំនុកបំរុងអស់អាណាប្រជានុរាស្ត្រ ដោយ

ការផ្លាស់ប្តូរឲ្យកើតសុខសំរានមានខុះដែរឬទេ ទៀវស៊ុនថា មនុស្សដែលមានសតិបញ្ញាទីនសេនាទាហាន ដែលមានថ្វីដៃខ្លាំងពូកែនោះមានច្រើន មិនដឹងដែលទីនពណ៌នាជូនអ្នកស្តាប់បានទេ ។

គៀវស៊ីសួរថា នាហ្មឺនដែលមានសតិបញ្ញាដូចពាក្យអ្នកថានេះ មានប្រហែលប៉ុន្មាននាក់ ទៀវស៊ុនឆ្លើយថា នាម៉ឺនដែលមានសតិបញ្ញាពិស្តារជ្រៅទូលាយ ទីនប្រកបទៅដោយសេចក្តីស័ត្យសុចរិតប្រាកដនោះ ប្រហែល ១ ០០០ នាក់ តែដែលមានប្រាជ្ញាជាប្រមាណដូចយ៉ាងខ្លួនខ្ញុំនេះ សូម្បីទីនយករទេះទៅផ្ទុកក៏មិនអស់ ។ គៀវស៊ីថា ឥឡូវនេះខ្លួនអ្នកជានាហ្មឺនក្នុងក្រសួងអ្វី ? ។ ទៀវស៊ុនឆ្លើយថា ខ្ញុំបាទជាភ្នាក់ងារគ្រាន់តែទីប្រឹក្សាយ៉ាងតូចទេ មិនសមគួរដែលទីនជានាហ្មឺនដូចគេតាំងពូនឡើយ ចុះខ្លួនអ្នកតើជាទីអ្វី ? ។ ទៀវស៊ីថា យើងជានាហ្មឺនសម្រាប់កាន់បញ្ជីរបស់ទ្រព្យមហាទបពជ ត្រូវត្រួតត្រាឲ្យដឹងរបស់ខុះខាតចូលចេញតាំងពូន ។ ទៀវស៊ុនថា ខ្ញុំបាទបានឮគេនិយាយថា ខ្លួនអ្នកនេះជាមនុស្សមានសតិបញ្ញាណាស់ ហេតុម្តេចមកធ្វើត្រឹមភ្នាក់ងារក្រៅដំណែងដូច្នេះ បើទីនឧស្សាហ៍ធ្វើកផការក្នុងព្រះចៅហៀនតេផ្តល់ឲ្យជាមន្ត្រីធំ ទីនបានជួយទំនុកបំរុងផែនដី ដើម្បីឲ្យព្រះចៅហៀនតេសប្បាយព្រះទ័យផង មិនបានឬ ? ។

អៀវស៊ីឮដូច្នោះ ក៏ខំអត់សង្កត់ទុកក្នុងចិត្តហើយថា ដែលខ្លួនខ្ញុំមកនៅធ្វើការក្នុងបន្ទាយមហាឧបរាជ គ្រាន់តែជាភ្នាក់ងារក្រៅដំណែងនោះក៏មែន តែថាបណ្ដាជនានុជន ក៏បានកោតក្រែងអែងខ្លាចនឹងរាប់អានស្រឡាញ់ច្រើន ព្រោះមហាឧបរាជបានជឿទុកចិត្តជាប្រាកដប្រគល់របស់ទ្រព្យទាំងពួងឲ្យខ្ញុំទុកដាក់ថែរក្សា ហើយក៏មានសេចក្ដីអាសូរករុណាជាច្រើន បានរំលឹកប្រដៅឲ្យដឹងកិច្ចការទាំងពួងជានិច្ច គុណឧបការៈរបស់មហាឧបរាជនោះនឹងរកទីប្រមាណជាទីបំផុតមិនបានឡើយ បានជាខ្ញុំជាប់ចិត្តគិតគក្កិត្រាំនៅបំរើ ។ ទៀវសុងអស់សំណើចហើយថា ខ្ញុំបាទក៏ដឹងអស់ហើយ គឺមហាឧបរាជនេះនឹងបានដឹងស្គាល់របស់អ្វីឲ្យជាប្រាកដនោះគ្មាន ទោះបីនឹងបេះសំបុត្រឬវិជ្ជាការសិល្បសាស្ត្រក្នុងបែបទាហានក៏គ្រាន់តែជាប្រមាណ នឹងយកវិជ្ជាអ្វីមករំលឹកប្រដៅអ្នក ៗ ទើបមករាប់បុណ្យលើកយកគុណឧបការៈនៃមហាឧបរាជនោះ ព្រោះសព្វថ្ងៃនេះហាក់តែមានវាសនាពីអតីតជាតិជួយឧបត្ថម្ភគាំទ្រ ទើបបានតាំងខ្លួនជាធំប៉ុណ្ណោះបាន ។

អៀវស៊ីថា ខ្លួនអ្នកនៅស្រុកក្រៅឆ្ងាយណាស់ មិនបានដឹងច្បាស់ថា មហាឧបរាជនេះមានវិជ្ជាការនឹងកលឧបាយប្រាយប្រាជ្ញាជ្រៅទូលាយនោះ ហេតុអ្វីក៏អាចហានថាដូច្នោះ ឯមហាឧបរាជនេះ គឺជាមនុស្សចេះដឹងណាស់ បើអ្នកចង់ដឹងច្បាស់ជាមែនឬមិនមែនយើងនឹងយកសំបុត្រ

ដែលមហាឧបាសកតែងទុកថ្វី ឈ្មោះថាប៉ាំងគេយកមកឲ្យមើល ហើយ ចាប់យកសំបុត្រនោះហុចមកឲ្យទៀវស៊ុន ។ ក៏យកមកមើលឃើញមាន សេចក្តី ១៣ ខ ពណ៌នាពីការណរង្គសង្គ្រាម ឲ្យតាំងបន្ទាយទីងតាក់ តែងរៀបពលទាហានទ័ពទឹក ទ័ពគោកតាមរបៀបក្បួន លុះមើលចប់ក៏ សួរថា សំបុត្រនេះមហាឧបាសកយកយ៉ាងទំនៀមពីណាមកសរសេរទុកទេ ឬ? ។ អៀវស៊ុវថា មហាឧបាសកតែងបញ្ចេញពាក្យបុរាណជាទំនៀម ទុក ប្រាថ្នានឹងឲ្យជាប់ជាច្បាប់តទៅខាងមុខ ហេតុម្តេចបានជាអ្នកមកថា ជាពាក្យមើលងាយប្រមាថ ថាមហាឧបាសកមានសតិបញ្ញាតិច បើប្រាជ្ញ មិនមាននឹងតែងសេចក្តីសំបុត្រនេះទុកបានឬ? ។

ទៀវស៊ុនអស់សំណើចហើយថា សំបុត្រថែបយ៉ាងនេះកូនក្មេងតូចៗ នៅក្នុងស្រុកសែឈ្មួនក៏សូត្រលេងទូទៅពេញក្នុងស្រុក គឺជាពាក្យបុរាណ មានអ្នកប្រាជ្ញគេរចនាទុកពីដើមទេ ហេតុម្តេចអ្នកមកថា មហាឧបាសក តែងខ្លួនឯងសោត គឺរើសយកពាក្យចាស់មកថាកុហកគេ ដែលនឹងជឿ នោះ ក៏យ៉ាងថែបអ្នកឯងវង្វេងស្តាប់ពប់ថាល្អ ។ អៀវស៊ុវថា សំបុត្រនេះ មហាឧបាសកតែងទុកដើម្បីនឹងឲ្យឃើញប្រាកដរហូតទៅគ្រាតែអស់ផែនដី មនុស្សទាំងប្រុសទាំងស្រីក៏បានដឹងគ្រប់គ្នា ហេតុម្តេចអ្នកមកថាពាក្យនេះ ជាពាក្យសម្រាប់សូត្រលេងទៅវិញ មិនសមគួរនឹងយកពាក្យនេះមកក្លែង ប្រមាថមើលងាយមហាឧបាសកដូច្នេះសោះ ។ ទៀវស៊ុនថា បើអ្នកមិន

ជឿពាក្យខ្ញុំថា អ្នកបិទសំបុត្រនេះទុកទៅចុះ ខ្ញុំនឹងសូត្រឲ្យស្តាប់តែមាត់ទទេ ហើយទៀវសុងក៏ស្វាធ្យាយដោយបញ្ញាកងវៃដែលចាំបាន ត្រូវឃ្លាគ្រប់អក្សរដែលតែងក្នុងសំបុត្រនោះ គ្មានវិបល្លាសក្នុងឯណាទីមួយឡើយ ។

អៀវស៊ីវឮដូច្នោះក៏ជឿថា ទៀវសុងឆ្លាតចាំមែន ទើបថាអ្នកនេះមានប្រាជ្ញាឈ្លៀវឆ្លាតមែន បានមើលសំបុត្ររបស់យើងតែ ១ ចប់ក៏ចាំបានគ្មានភ្លេចសោះ ទីងរកអ្នកឯណាឲ្យស្មើនឹងអ្នកកម្រណាស់ ទៀវសុងគំនាប់អៀវស៊ីវហើយថា អ្នកចូលនៅឲ្យសុខសម្រាន្តចុះ យើងសុំលាវិលទៅស្រុកសិនហើយ អៀវស៊ីវថា អ្នកកុំអាលរួសរាន់ប្រញាប់វិលទៅស្រុក ចូរបង្អង់នៅសិន យើងនឹងចូលទៅជំរាបមហាចបកជឲ្យនាំអ្នកចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេឲ្យបានជ្រាប ទៀវសុងមានសេចក្ដីត្រេកអរទទួលពាក្យហើយ ក៏គំនាប់លាទៅទីសំណាក់ ។

អៀវស៊ីវក៏ចូលទៅជំរាបចូឆូជាមហាចបកជថា ហេតុអ្វីអំបាញ់មិញនេះ បានជាមហាចបកជខឹងនឹងទៀវសុងជាខ្លាំង ។ ចូឆូថា វាចរចាព្រហើនមើលងាយមិនមានគោរពក្រែងយើង បានជាយើងខឹង ។ អៀវស៊ីវថា កាលគ្រាយីអេងហេតុម្ដេចលោកចេះអត់បាន តែត្រឹមទៀវសុងប៉ុណ្ណោះគួរឬលោកអត់មិនបាន ? ។ ចូឆូថា ឯយីអេងនោះជាមនុស្សមានសតិបញ្ញាប្រាកដណាស់ បានជាយើងទ្រាំអត់សង្កត់ចិត្តព្រោះខ្លាចសេចក្ដីគរហានិន្ទា ឯទៀវសុងនេះ វាជាមនុស្សរូបអាក្រក់គ្មានសតិបញ្ញាសោះ ទីង

អត់ឲ្យវាបានប្រយោជន៍អ្វី ។ គៀវស៊ុវថា មហាឧបរាជកុំអាលប្រមាថ ទៀវស៊ុននេះ ខ្ញុំបាទឃើញថាជាមនុស្សមានសតិបញ្ញាឆ្លាតណាស់ អំបាញ់មិញនេះ ខ្ញុំបាទបានយកសំបុត្រដែលលោកតែងទុកនោះ ឲ្យទៀវស៊ុនមើលតែ ១ ចប់ក៏ចាំបានទាំងអស់ ជាមនុស្សឆ្លៀវឆ្លាតណាស់ ហើយថា សំបុត្រនោះជាពាក្យបុរាណ កូនក្មេងក្នុងស្រុកសៃឈួនសូត្រលេងគ្រប់ផ្ទះ ។ ចូឆូឮដូច្នោះក៏ខឹងណាស់ថា ពាក្យនេះអង្គឹមនុស្សពីដើមនឹងមកប្រាប់យើងក៏ទេ បើយើងតែងសំបុត្រនេះ ក៏ត្រូវគ្នានឹងពាក្យបុរាណ ហើយក៏នឹងយកទុកប្រយោជន៍អ្វី ទើបឲ្យយកសំបុត្រនោះមកហែកចោលដាក់ក្នុងភ្លើងឆេះអស់ទៅ ។

គៀវស៊ុវថា ឯទៀវស៊ុននោះជាមនុស្សស្រុកក្រៅ សូមឲ្យមហាឧបរាជនាំចូលទៅគាល់ព្រះចៅហៀនតេ ឲ្យបានឃើញក្នុងរាជហានដ៏ប្រកបទៅដោយរបៀបដ៏រុងរឿង ដើម្បីកុំឲ្យសត្រូវមើលងាយ មានតែសេចក្តីកោតក្រែងអានុភាពរបស់លោក ។ ចូឆូថា ទៀវស៊ុនជាពួកស្រុកក្រៅ នឹងត្រូវការអ្វីនាំចូលទៅគាល់នោះ បើដូច្នោះពេលព្រឹកស្អែក យើងនឹងនាំទាហានចូលទៅហាត់នៅទីស្នាក់កណ្តាលវាល ឲ្យអ្នកនាំទៀវស៊ុនទៅមើលឲ្យឃើញរបៀបថ្វីដៃរបស់យើងចុះ ដើម្បីវានឹងបាននាំយកទៅផ្សាយក្នុងស្រុកសៃឈួនឲ្យបានប្រាកដល្បីឮតទៅ ហើយយើងនឹងលើកទាហានទៅវាយយកស្រុកកាំងតាំង បើបានសមប្រកបតាមគំនិតដែលគិតទុក

ហើយ ក៏ទៅកាយយកស្រុកសៃឈូនទៀត ។

អៀវស៊ីវ ទទួលពាក្យចូចូហើយ ក៏គំនាប់លាចេញទៅលំនៅវិញ លុះព្រឹកឡើង អៀវស៊ីវក៏នាំទៀវស៊ុងចេញទៅមើល ពួកទាហានហាត់ក្បួនអាវុធ ។ ខណៈនោះ ចូចូក៏ជ្រើសរើសយកទាហានដែលមានថ្វីដៃ ហៅថាទាហានខ្លា ឲ្យចេញទៅចំនួន ៥ ម៉ឺននាក់ សុទ្ធតែតែងខ្លួនពាក់អាវពាក់ក្រោះជិះសេះកាន់ដាវលំពែងមានធ្នូ ស្នាំតាមក្បួន ចូលប្រយុទ្ធហាត់ដៃគ្នាជាពន្លឹកសន្ធឹកសន្ធាប់ ។

ចូចូឃើញទៀវស៊ុងងាកមុខមើលទាហានទាំងពួង ក៏ឲ្យហៅចូលទៅជិត ហើយសួរថា ទាហានក្នុងស្រុកសៃឈូនដូចទាហានរបស់យើងនេះដែរឬទេ ? ។ ទៀវស៊ុងឆ្លើយតបថា ឯស្រុកសៃឈូននោះ មិនបានបង្ហាត់មនុស្សឲ្យចុះរបៀបជាទាហាន ដើម្បីនឹងលើកទៅសង្កត់សង្កិនយកស្រុកណាក៏ទេ ខ្ញុំបាទមិនធ្លាប់ឃើញ ឯប្រពៃណីស្រុកសៃឈូននោះ បើនឹងប្រាប់ប្រាមសឹកសត្រូវដែលបង្កើតឡើង ជាចំរូងចំរាសនោះ ត្រូវរម្ងាប់ដោយយកពាក្យសត្យសុចរិត ជាគោលចារិកទៅរម្ងាប់ ។

ចូចូឮដូច្នោះក៏ខឹងណាស់ថា ក្នុងខេត្តខណ្ឌសីមានេះ យើងសំឡឹងមើលមិនឃើញមាននរណាមានទាហានច្រើនដូចយើង បណ្ដាអាណា-ខែត្រទាំងពួង ដែលនឹងរឹងទទឹងមិនចំណុះចុះចូលមកគំនាប់ដល់យើងទេក៏ ឧបមាដូចដុំស្មៅ បើយើងនឹងលើកទាហានទៅឯទិសឯណាក៏នឹងជាន់សង្កត់

ឲ្យល្អិតខ្ទេចខ្ទីជាផង់ធូលី នរណាក៏មិនអាចតស៊ូជាមួយយើងបាន បើទឹងរាយយកស្រុកណាក៏បានស្រុកនោះ អ្នកឯងដឹងឬទេ? ។ ទៀវស៊ុងឆ្លើយថា ដែលមហាឧបរាជទឹងលើកកងទ័ពទៅប្រាបប្រាមស្រុកណានៅទិសឯណា ក៏មានល្បីគេនិយាយរឿងឮទាំងផែនដីថា លោកមានវិជ្ជាចំណានក្នុងការសង្គ្រាមណាស់ ដូចកាលគ្រាស្រុកបាក់អៀងចម្បាំងលើទៅ ស្រុកអ៊ួនសៀ ចម្បាំងទៀវស៊ីវ ស្រុកកាំងតាំងចម្បាំងជីវយី ដំបន់គួយ៉ុងប្រទះគ្នាទង់គួនអ៊ូ គយគុងគួន កាត់ពុកមាត់ពុកចង្កា ដោះក្រឹសបោល គ្រាមួយជា ៤ គ្រាមកហើយ ខ្ញុំបាទក៏ដឹងថា ទឹងរកអ្នកឯណាស្មើទឹងលោកគ្មាន ។

ចូឆូឮដូច្នោះក៏ខឹងប្រឡោកខ្លាំងណាស់ ស្រែកដេរថា អាចោរឥតពូជឥតត្រកូល វាហ៊ានមករំលើកចរចាមើលងាយអញដូច្នេះ វាគ្មានកោតក្រែងអញតិចសោះ ហើយបង្គាប់ឲ្យពាហានយកខ្លួនទៀវស៊ុង ទៅសម្លាប់ ។ អៀវស៊ីវតំនាប់ហើយឃាត់ថា ដែលទៀវស៊ុងចរចាជាពាក្យមាក់ងាយប្រមាថដល់មហាឧបរាជ ហើយទឹងឲ្យយកខ្លួនទៅសម្លាប់នោះក៏គួរហើយ តែថាទៀវស៊ុងនោះជាភ្ញៀវមកពីក្រៅ បើលោកមិនអត់ទោសទឹងសម្លាប់ចេញហើយ កិត្តិស័ព្ទនោះក៏នឹងល្បីឮទៅគ្រប់ស្រុក បើមានអ្នកឯណាទឹងចង់មករកលោក ក៏ឲ្យនឹករងៀសខ្លាចពុំអាចមកបាន ។

ចូផ្ទួជូបោះក៏យល់ឃើញផង តែទោសនោះនៅមិនរសាយ ទើប
បង្គាប់ឲ្យទាហានយកជំបង់ដេញកយទៀវសុង់កេ់ចេញទៅ ទៀវសុង់ក៏
រត់ចេញទៅផុត ហើយចាត់ចែងរៀបដំណើរទំនងវិលទៅវិញ ក៏ស្រុក
ចេញទៅជាប្រញាប់ទាំងយប់ថ្ងៃ ហើយគិតថា ខ្ញុំអញប៉ង់នឹងយក
ស្រុកសៃឈួនទៅឲ្យចូផ្ទួ គួរឬរាមកធ្វើអាក្រក់នឹងអញវិញដូច្នេះ កាល
អញនឹងមកនោះបាននិយាយទុកនឹងឡៅជៀងជាខំ គ្រានេះក៏មិនសម
ដូចពាក្យថា នឹងត្រឡប់ទៅវិញទទេមិនបានការ មនុស្សទាំងពួងគេនឹង
គរហានិន្ទាសើចចំអកលេងឲ្យឈឺចិត្ត បើគិតខុសត្រូវត្រូវតែអញ
ចូលទៅរកឡៅពីឯស្រុកកេងជីវចុះ ដើម្បីនឹងស្តាប់មើលឡៃបខាយឡៅ-
ពីតើនឹងជាមនុស្សល្អឬអាក្រក់ប្រការម្តេច នឹងបានគិតប្រែប្រួលតទៅទៀត
ទៀវសុងពិចារណារិះគិតដូច្នេះ ហើយក៏បរសេះនាំទាហានស្រុកតម្រង់
ទៅស្រុកកេងជីវ ទទួលខុនបេងជីងដំណាឹងក៏ប្រើដូឡុង នាំទាហាន ៥០០
ចេញទៅទទួល លុះដូឡុងចេញទៅប្រទះក៏បង្អោនខ្លួនគំនាប់ហើយសួរ
ថា អ្នកនេះឬឈ្មោះទៀវសុងនៅស្រុកសៃឈួន ? ។ ទៀវសុងក៏គំនាប់
គួរសមមកវិញហើយសួរថា អ្នកនេះឈ្មោះដូឡុងនោះឬ ? ។ ដូឡុងក៏
ឆ្លើយទទួលថា ខ្ញុំនេះហើយឈ្មោះដូឡុង ទាំងសងខាងក៏នាំគ្នាចុះពី
លើសេះ ។

ដូឡុងនិយាយថា ឡៅពីជានាយខ្ញុំដឹងដំណាឹងថា អ្នកទស្សាហ៍មក

ពីស្រុកឆ្ងាយ មុខជាអ្នកទាំងអស់គ្នាបានសេចក្ដីនឿយហត់លំបាកណាស់ ទើបប្រើខ្ញុំឲ្យនាំរបស់សម្រាប់បរិភោគយកមកចាំរង់ទទួលអ្នក ហើយសុំឲ្យឈប់ស្នាក់សំរាកកម្លាំងបរិភោគអាហារនេះ ឲ្យរួចដោយស្រួលសប្បាយ ហើយសឹមចូលទៅ ។ ទៀវសុងឮដូច្នោះ ក៏ត្រេកអរណាស់ឈប់សំរាកនៅទីនោះ ។ ជូឡុងក៏ឲ្យទាហានរៀបតុរៀងអាហារតាមប្រពៃណី ។ ទៀវសុងមកគំនិតក្នុងចិត្តថា ឡេវពីនេះជាមនុស្សមានអធ្យាស្រ័យរក់ទាក់ រាប់អានអ្នកមានសតិបញ្ញាពិតដូចពាក្យគេថាមែន ។ លុះបរិភោគរួចហើយ ជូឡុងក៏នាំទៀវសុងចូលទៅដល់ទីសំណាក់សំរាប់ភ្ញៀវ ។ គួនអ៊ូនាំទាហាន ១០០ នាក់មកចាំទទួល លុះឃើញទៀវសុងចូលទៅដល់ក៏ឲ្យវាយគងស្គរនឹងឃោះទទួល ហើយចូលទៅគំនាប់ថា ឡេវពីបង្គាប់ខ្ញុំដឹងថាអ្នកមកពីស្រុកឆ្ងាយ ទើបប្រើខ្ញុំចេញមកចាត់ចែងទីសំណាក់ឲ្យនៅតាមសប្បាយ ទៀវសុងក៏ឈប់នៅទីនោះមួយយប់ ។

លុះព្រឹកឡើង គួនអ៊ូនឹងជូឡុងក៏នាំទៀវសុងទៅតាមផ្លូវចម្ងាយផ្លូវប្រហែល ៥០ សិន (២ គ.ម) ទៀត ក៏ប្រទះនឹងឡេវពីហើយនឹងខុងបេងចាំងថង លើកទាហានចេញមកទទួលគំនាប់ទៀវសុងហើយថា ពីដើមក៏បានឮគេសរសើរដល់អ្នកជារឿយថាមានគម្រិះប្រាជ្ញាច្រើន លុះនឹងទៅសន្ទនាដោយមេត្រីដើម្បីឲ្យស្គាល់រាប់អានក៏ពុំបាន ព្រោះផ្លូវទៅមកឆ្ងាយដាច់អាល័យ អ្នកបានមកដល់ទីនេះ ក៏ជាបុញ្ញលាភរបស់យើងច្រើន

ណាស់ សូមអញ្ជើញអ្នកចូលទៅក្នុងស្រុកគេងដីរសិន ដើម្បីនឹងបាន សន្ទនាជាបដិសណ្ឋារៈព្រោះត្រូវនឹងប្រាជ្ញា ឧបមាដូចអ្នកយកទឹកមកឲ្យ ផឹកនៅវេលាដែលកំពុងស្រេកឲ្យបាត់ក្រវល់ក្រវាយ ក្រៅពីនិយាយហើយ ក៏នាំទៀវស៊ុនចូលទៅក្នុងស្រុកគេងដីរ ហើយតាក់តែងទីដ៏សមគួរឲ្យ ទៀវស៊ុនអង្គុយ រួចរៀបតុលៀងអាហារបរិភោគជាមួយ និយាយលេង តាមប្រក្រតី ។

ទៀវស៊ុនឮក្រៅពីប្រាប់តែអំពីសេចក្ដីដទៃ មិនបាននិយាយដល់ កិច្ចការស្រុកទេស ដូច្នោះក៏ក្លែងសួរថា លោកមកនៅជាធំក្នុងស្រុកគេង-ដីរនេះ មានអាណាខេត្រឡើងជាចំណុះប៉ុន្មានខេត្រ ។ ខុងបេងក៏ថ្លែង ឆ្លើយឡើងថា ស្រុកគេងដីរនេះ នាយយើងខ្ញុំស៊ុនគួនហៅហ្វាយស្រុក កាំងតាំងនៅជាបណ្ដោះអាសន្នទេ មិនមែនជាកម្មសិទ្ធិចំពោះខ្លួនកាល ណា ព្រោះនាយយើងជាប្អូនថ្លៃស៊ុនគួន គេទាល់ហើយក៏ឲ្យនៅទៅ សព្វថ្ងៃនេះក៏បេះតែមកគៀនតារយកវិញ នាំឲ្យរំខានក្នុងចិត្តមិនដឹងដែល នឹងប្រែប្រួលយ៉ាងណាឡើយ ។ ទៀវស៊ុនថា ស្រុកកាំងតាំងនោះមានអា-ណាខេត្រឡើង ខេត្រឯកដល់ ៦ មណ្ឌល ខេត្រត្រីក៏មានដល់ ៨១ ដំបន់ សារពើចំណីអាហារក៏បរិបូណ៌គ្រប់ប្រការ ទាំងមនុស្សចំណុះស្រុកក៏ច្រើន នៅមិនទាន់ពេញចិត្តទៀតឬ តែស្រុកគេងដីរប៉ុណ្ណោះនៅតាមមកគៀនតារ ទៀត ។ បាំងថងថា នាយយើងនេះជាពូជព្រះវង្សព្រះហៅហៀនតេ

ប្រាកដ តែត្រឹមស្រុកមួយក៏រកនៅមិនបានទឹងតាំងខ្លួនក៏មិនបាន ត្រឡប់ទៅខ្ញុំស្រុកគេនៅ ឲ្យសត្រូវបង្គាប់ប្រើដូច្នេះមិនគួរសោះឡើយ ។

ឡៅពីថា អ្នកទាំងពីរកុំនិយាយឡើយ វាសនារបស់ខ្ញុំហើយ តាមតែបុណ្យចុះ តែប៉ុណ្ណោះក៏ល្មមសុខហើយ ខ្ញុំមិនគិតនឹងប្រុងធ្វើធំឲ្យលើសវាសនាទេ ។ ទៀវស៊ុងថា ខ្លួនលោកក៏ជាពូជព្រះវង្សព្រះចៅហៀនគេ មនុស្សទាំងពួងក៏សរសើរ ទាំងមានសេចក្ដីស្រឡាញ់ក៏ច្រើន កុំបាច់តែនឹងដណ្ដើមយកស្រុកកេងជីវប៉ុណ្ណោះឡើយ សូម្បីវាសនាលោកនឹងទទួលតាំងខ្លួនជាជំនួសព្រះចៅហៀនគេផង ក៏គ្មាននរណានឹងតវ៉ានិន្ទាថាម្ដេចបាន ។ ឡៅពីលើកដៃឡើងគំនាប់ហើយហាមឃាត់ថា ចូរឲ្យអ្នកមានសេចក្ដីអាណិតខ្ញុំចុះ កុំថាដូច្នេះទៀតឡើយ លើសវាសនាណាស់មិនសមគួរទេ ឡៅពីក្អែងនាំនិយាយតែពីសេចក្ដីដទៃដល់ ៣ ថ្ងៃ ហើយទៀវស៊ុងគំនាប់លានឹងទៅស្រុកសែឈួនវិញ ឡៅពីក៏នាំទាហានចេញជូនដំណើរទៅដល់ក្រៅស្រុក ហើយក៏ឲ្យរៀបតុលៀងអាហារ ។

ឡៅពីនិយាយថា អ្នកមកដល់ស្រុកកេងជីវនេះ ខ្ញុំបានឃាត់អ្នកឲ្យនៅលេងដល់ ៣ ថ្ងៃ បានសន្ទនាគ្នាក៏បានសេចក្ដីសប្បាយ ឥឡូវអ្នកចរចាលាកលាយើងទៅហើយ កាលណាឡើយនឹងបានជួបឃើញមុខគ្នាទៀត ថាហើយឡៅពីក៏យំខ្សឹកខ្សួល ទៀវស៊ុងឃើញដូច្នោះក៏ឲ្យនឹកអាណិតអនាថឡៅពីពន់ប្រមាណ ទើបនិយាយថា ខ្លួនខ្ញុំសព្វថ្ងៃនេះក៏

គិតថានឹងចងមកនៅជាមួយនឹងលោកឲ្យលោកប្រើប្រាស់ តែថានៅមិនទាន់មានឱកាសត្រូវគេលការ មួយយ៉ាងទៀត បើលោកនឹងតាំងនៅក្នុងស្រុកកេងជីវនេះ ក៏ឃើញថាមិនជាទីមាំមួនបានឡើយ ព្រោះខាងទិសឯកើតនោះស៊ុនគួនក៏ជាសត្រូវម្នាង ខាងទិសឯជើងសោត ចូច្ចក៏ចង់តែនឹងមកញាំញី កាលណាឡើយលោកនឹងបានសេចក្តីសុខក្សេមក្សាន្ត ឧបមាដូចលោកបានមកនៅកណ្តាលភ្នក់ភ្លើង ទៀវពីថា យើងក៏ដឹងខ្លួនថាដែលនៅក្នុងស្រុកកេងជីវនេះអស់មានសេចក្តីសប្បាយហើយ តែថា ចាល់គំនិតហើយមិនដឹងធ្វើម្តេច សព្វថ្ងៃខំសម្លឹងមើលក៏មិនឃើញមានទីកន្លែងឯណា គួរនឹងយកជាទីអាស្រ័យបាន ។ ទៀវស៊ុងថា ឯស្រុកសែឈួននោះ ភូមិឋានក៏ធំទូលាយមនុស្សម្នាក៏ច្រើន ស្រូវអង្ករចំណីត្រីសាច់ក៏បរិបូណ៌ អ្នកដែលមានសតិបញ្ញាខាងតួង ក៏កប់អានស្រឡាញ់លោកដោយព្មថាជាអ្នកមានឥទ្ធស្រ័យមេត្រីកប់អានដោយស្មោះត្រង់ បើនឹងលើកទ័ពទៅវាយយកស្រុកសែឈួននោះ តែបង្អិលដៃមួយទៅក៏គង់បានដោយងាយ មិនព្រួយលំបាកដល់សេនាទាហានទាំងពួង មុខជានឹងតាំងនៅជាសុខក្នុងស្រុកនោះបាន ។

ទៀវពីថា ទៀវជៀងចៅហ្វាយស្រុកសែឈួននោះ ក៏ជាពូជព្រះកជវង្សព្រះចៅហៀនតេដូចខ្លួនខ្ញុំ ហើយក៏បានទំនុកបំរុងអាណាប្រជានុកស្រ្តមកពីដើម អ្នកឯទៃឬនឹងអាចទៅធ្វើអន្តរាយបាន ។ ទៀវស៊ុងថា

លោកមានប្រសាសន៍នោះក៏គួរមែន ខ្ញុំបាទក៏មិនមែនជាមនុស្សលក់ម្ចាស់ទេ តែជាបានមកជួបប្រទះនឹងលោក ហើយក៏មានសេចក្តីអាណិតស្រឡាញ់លោកណាស់ ទើបនាំគតិមាននេះដោយការកក់ជ្រៅឲ្យលោកជ្រាប ព្រោះឡៅជៀងនោះជាមនុស្សលោកឥតខ្មាស សូម្បីជាពូជព្រះរាជវង្សក៏មែន តែមិនមានសតិបញ្ញាសោះ ទាំងមិនចេះចិញ្ចឹមមនុស្សអ្នកមានគម្រិះប្រាជ្ញា មួយទៀតទៀវឡៅនៅខាងជើងក៏ប៉ងតែនឹងមកធ្វើអន្តរាយ មនុស្សទាំងឡាយក៏ជ្រួលជ្រើមប្រុងតែនឹងប្រែចិត្តប្រែគំនិតទៅដោយខ្លួន ៗ បើយ៉ាងដូចលោកដូច្នេះ លើកទ័ពទៅមុខជាអ្នកស្រុកនោះនឹងមានសេចក្តីត្រេកអរ ខូចជា គង់នឹងចូលមកខាងលោកជាច្រើន ដែលខ្ញុំបាទមកគ្រានេះ គឺប្រាថ្នានឹងយកស្រុកសែឈួនទៅឲ្យចូចូ តែឃើញចូចូកាសត្រូវរាជសម្បត្តិនោះ ព្រហើនក្អេងក្អាងកាន់ខ្លួនថា ល្អលើសគេ លុបលាងមនុស្សដែលមានសតិបញ្ញាចេញអស់ នោះខ្ញុំបាទនឹងលើកស្រុកឲ្យទៅក៏មិនជាការមានប្រយោជន៍ បានជាខ្ញុំបាទគេចមករកលោក ប្រាថ្នានឹងជំរាបសេចក្តីទាំងនេះ សុំឲ្យលោករិះគិតតែរមើលតាមយោបល់ចុះ បើបានស្រុកសែឈួនហើយ ក៏នឹងបានគិតរកឧបាយតទៅទៀត មុខជានឹងបានជាធំដូចសេចក្តីប្រាថ្នា បើលោកពេញចិត្តត្រូវការនឹងយកស្រុកសែឈួនជាប្រាកដកាលណា ខ្ញុំបាទនឹងទទួលជាធុរៈចាត់ការខាងក្នុងមិនឲ្យមានពាក់ទាម តែឥឡូវនេះនៅមិនទាន់ដឹងជាចិត្តលោកនឹងបង់គិតការប្រការម្ដេច ៗ

ទៀវពីថា អ្នកនិយាយមកនេះក៏ជាទីពេញចិត្តខ្ញុំណាស់ តែថាខ្ញុំទាល់គំនិតព្រោះដ្បិតទៀវជៀនជាសៃជាមួយគ្នា បើនឹងលើកពលយោ-ធាទៅវាយយកតែម្ដង មនុស្សផងទាំងពួងនឹងមិននាំគ្នាគរហានិន្ទាទេឬ? ។ ទៀវសុនថា ធម្មតាកើតមកជាប្រុស កាលនឹងបង់ប្រាជ្ញាធ្វើធំនោះ លុះក្រឡេកទៅឃើញទីបន្ទោះឱកាសល្អហើយ ក៏ត្រូវតែធ្វើតាមការ ដែលបើចិត្តគិតមិនដាច់ស្រេចព្រោះដូច្នេះដូច្នោះ បើតែខ្លាចគេនិន្ទា យូរទៅបើបានប្រយោជន៍នោះទៅគេឯណា យើងក៏ត្រូវអស់សារសោះទទេ លុះនឹងគិតតែធ្វើជាក្រោយក៏មានតែសេចក្ដីលំបាក ។ ទៀវពីថា អ្នកមានចិត្តមេត្តាពន្យល់យើងសព្វគ្រប់ដូច្នេះជាគុណអនេកណាស់ តែថាស្រុកសៃឈួននេះយើងក៏ដឹងហើយ ជាផ្លូវដាច់ស្រយាលក្ដួងជ្រោះជ្រលងជងស្ទឹងនឹងភ្នំខ្ពស់ទាបជាច្រើនអន្លើ នឹងដើរទៅមកក៏លំបាកណាស់ សេះឬលាជាពាហនៈនឹងទៅមកក៏កម្រ បើនឹងគិតធ្វើការនោះ តើនឹងត្រូវកែប្រែប្រការដូចម្ដេចទើបស្រួល ។

ទៀវសុនក៏លូកតាមបន្ទោះទ្រូងក្នុងអាវ ទាញយកផែនទីស្រុកសៃ-ឈួនជូនទៅទៀវពីហើយថា លោកមិនចូលចិត្តផ្លូវដែលនឹងទៅមកក្នុងដំបន់ស្រុកសៃឈួននោះ ក៏ចូរពិគ្រោះមើលតាមផែនទីនេះចុះ ពោះនឹងមានកំពង់ទឹកឬច្រកភ្នំ ហើយនឹងកន្លែងដែលមានត្រីសាច់សម្រាប់ជាអា-ហារបរិភោគនៅត្រង់អន្លើឯណា នឹងដាច់ស្បៀងអាហារឬមានបរិបូណ៌

ប្រការម្ដេច  ក៏មានស្រេចសព្វគ្រប់នៅក្នុងផែនទីនេះទាំងអស់  ហើយក្នុងស្រុកសៃឈូននោះ ភៀនសំឡាញ់របស់ខ្ញុំបាទមាន ២ នាក់ ម្នាក់ឈ្មោះហួត-ចេង ម្នាក់ឈ្មោះចេងគ័ត ទាំងពីរនាក់នេះក៏ជាទីទុកចិត្តបានខ្ញុំបាទនឹងទៅនិយាយក៏គង់មិនទទឹងទាស់ទែង បើហួត-ចេង ចេងគ័តមកដល់លោកហើយ ក៏ចូលប្រឹក្សាពិគ្រោះគ្នាចុះ កុំគិតសង្ស័យអ្វីឡើយ ។ ឡៅពីលើកដៃឡើងគំនាប់ហើយថា ដែលអ្នកបានប្រាប់ពន្យល់ក្នុងកលកិច្ចការណែនាំឲ្យខ្ញុំបានដឹងដូច្នេះ គុណអ្នកមិនមានទីបំផុត បើសម្រេចកិច្ចការកាលណា ខ្ញុំនឹងសងគុណអ្នកឲ្យដល់ខ្នាត ។ ទៀវស៊ុងថា ខ្លួនខ្ញុំបាទនេះ មានសេចក្ដីប្រាថ្នានឹងរកចៅហ្វាយនាយមានសេចក្ដីល្អ មានចិត្តសុចរិតនឹងអធ្យាស្រ័យក៏បានដូចចិត្តហើយ ទោះបីខ្ញុំបាទនឹងដឹងយល់ការអ្វីជាការកំបាំងក៏មិនគួរនឹងលាក់ទុក ត្រូវតែជំរាបឲ្យអស់ ដែលនឹងតាំងចិត្តឲ្យលោកតបស្នងសងគុណវិញនោះគ្មានសោះឡើយ លុះនិយាយហើយក៏គំនាប់លាចេញទៅ ខុងបេងក៏ប្រើគួនអ៊ូនាំទាហានជូនដំណើរទៅ ចម្ងាយផ្លូវ ១០០ សិន ( ៤ គ.ម. ) ។ ហើយក៏ត្រឡប់វិលមកវិញ ។

លុះទៀវស៊ុងទៅដល់ស្រុកសៃឈូនហើយ ក៏គេចចូលទៅរកហួត-ចេងជាភៀនសំឡាញ់ស្និទ្ធនឹងគ្នាមកពីដើម ហើយក៏ពណ៌នារឿងរ៉ាវឲ្យស្ដាប់តាមសេចក្ដីដែលចូបធ្វើអាក្រក់មកឆ្ងាយគ្រប់ប្រការ ហើយថា ឯ

ចិត្តប្អូននោះ បើយើងពីកល់គ្នាទាំងពីរទៅធ្វើខ្លួនឲ្យបានសេចក្តីសុខសម្រាន្ត នោះគង់តែនឹងមានសេចក្តីទុក្ខទៅវិញ មិនគួរនឹងគិតយកស្រុកសែឈូនទៅឲ្យសោះឡើយ ឥឡូវខ្ញុំលើកស្រុកនេះឲ្យឡៀវពីទៅហើយ ទើបត្រឡប់មកឲ្យដំណឹងអ្នក តើនឹងយល់ឃើញប្រការម្តេច ? ។

ហ្លួងចេងញូវនោះ ក៏មានចិត្តត្រេកអរណាស់ថា ពីដើមខ្ញុំក៏គិតថា នឹងយកខ្លួនទៅចូលជ្រកកោនពឹងបុណ្យឡៀវពីដែរ ព្រោះឃើញថាឡៀជៀននេះជាមនុស្សមិនកើតជាការអ្វីសោះ ឥឡូវអ្នកស្ត្រីទៅនៅនឹងឡៀ-ពី លើកយកស្រុកសែឈូនទៅឲ្យហើយ ក៏ដូចជាគំនិតរបស់ខ្ញុំដែលគិតទុកដែរ យើងនឹងង្គៀសគ្នាថ្វី ទទួលចេងតិតចូលមកដល់ក៏សួរថា អ្នកទាំងពីរនិយាយគ្នានេះ ខ្ញុំស្តាប់យល់ចិត្តអស់ហើយ ប្រហែលជាលើកយកស្រុកសែឈូនទៅឲ្យអ្នកដទៃហើយ ។ ទៀវសុងថា អ្នកថានេះត្រូវណាស់ គឺត្រូវនឹងចិត្តយើងទាំងពីរនាក់ តែថាអ្នកមានប្រាជ្ញាប្ចូរពាយទៅមើលថាយើងនឹងលើកឲ្យអ្នកឯណា ។ ចេងតិតថា ស្រុកសែឈូននេះដែលនឹងលើកឲ្យអ្នកដទៃនោះ យើងសំឡឹងមើលហើយ មិនមានឃើញសមគួរដល់អ្នកឯណាសោះ ឃើញសមគួរតែនឹងលើកឲ្យឡៀវពីមួយទើបត្រូវ ទៀវសុង ហ្លួងចេង ចេងតិត ៣ នាក់នេះ ក៏ទះដៃសើចឡើងព្រមគ្នា ហើយនិយាយគ្នាតទៅទៀត ទៀវសុងថា យើងទាំង ៣ យល់ឃើញ

ដូចគ្នា ហើយកុំបន្ទន់ឡើយ ព្រឹកនេះខ្ញុំនឹងចូលទៅរកឡៅជៀង នឹងនិ-
យាយឲ្យឡៅជៀងប្រើអ្នកតាំងពីរឲ្យទៅរកឡៅពីឯស្រុកកេងជិវ ហួតបេង
បេងតែក៏ទទួលពាក្យទៀវសុង ទៀវសុងក៏ចូលទៅរកឡៅជៀងៗសួរថា
អ្នកទៅស្រុកក្រុងបានខរាជការមកប្រការម្ដេចខ្លះ ? ៗ

ទៀវសុងជំរាបថា ខ្ញុំបាទបានទៅដល់ស្រុកក្រុងនោះ ប្រាជ្ញានឹង
ការពារមិនឲ្យមានភ័យអន្តរាយមកដល់ស្រុកយើង ក៏មិនសមតាមសេចក្ដី
ពិត ព្រោះចូចូជាសត្រូវរាជសម្បត្តិ មានចិត្តនោះអាក្រក់ណាស់ ឯសេចក្ដី
អាក្រក់របស់ចូចូនោះនឹងពណ៌នាមិនអស់ឡើយ ឥឡូវមានចិត្តកំរើបគិត
នឹងបង់ធ្វើអន្តរាយដល់ស្រុកយើងទៀត ឡៅជៀងថា បើដូច្នោះយើងនឹង
គិតប្រការម្ដេចឲ្យបានស្រួល ៗ ទៀវសុងថា ខ្ញុំបាទគិតឃើញថា ឡៅពី
នឹងលោកជាសែជាមួយគ្នា ខណៈកាលជីវយីដុតទ័ពចូចូអស់ពល ៨៣
ម៉ឺននៅមាត់ពាមស្រុកកាំងតាំងនោះ ឡៅពីក៏ជួយធ្វើការទាល់តែសម្រេច
ចូចូខ្លាចប្រាជ្ញានឹងគំនិតឡៅពីជាដរាប តែកាលណាបញ្ចេញឈ្មោះឡៅពី
ក៏ដូចដេញព្រលឹងអស់ពីខ្លួន នឹងញញើតអ៊ីយ៉ាំងទៀវឡូប៉ុណ្ណោះ វាក៏គន់
គោរពខ្លាចឡៅពីណាស់ សុំឲ្យលោករិះគិតចងមេត្រីនឹងឡៅពីតាមប្រពៃ-
ណីទៅចុះ ដើម្បីនឹងបានជួយការពារស្រុកយើង ទៀវឡូនឹងមិនអាចមក
បៀតបៀនបាន ៗ ឡៅជៀងថា ដែលអ្នកនិយាយនេះពេញជាត្រូវចិត្ត
យើងណាស់ ព្រោះយើងបានគិតបំណងទៅចងមេត្រីនឹងឡៅពីជាយូរមក

ហើយ ឥឡូវអ្នកជាមកត្រូវនឹងចិត្តយើង តែលំបាកគិតនឹងប្រើឲ្យអ្នកឯណាទៅជាបំរើបាន ។

ទៀតសុំថា ដែលនឹងឲ្យកាន់សំបុត្រទៅដល់ឡៅពីនោះឃើញមានតែមនុស្ស ២ នាក់ គឺហ្លួតចេននឹងចេនតែត ទើបគួរនឹងប្រើឲ្យបានការពេជការជាប្រាកដ ឡៅជៀនស្តាប់យល់ត្រូវនឹងចិត្ត ទើបប្រើឲ្យទៅហៅហ្លួតចេន ចេនតែត ។ ចូលមកដល់ហើយក៏ប្រាប់សេចក្តីឲ្យដឹងគ្រប់ប្រការ ទើបឲ្យតែងសំបុត្រជាសេចក្តីថា ខ្ញុំបាទឡៅជៀនជាប្អូន សូមគំនាប់មកដល់ឡៅពីជាបង ព្រោះសព្វថ្ងៃនេះ ខ្ញុំបាទមានចិត្តនឹករលឹកដល់បងណាស់ តែថាជាផ្លូវដាច់ស្រយាលឆ្ងាយអាល័យ កម្រដែលនឹងទៅមកបានតាមស្រួល លុះនឹងបាត់ចែងរបស់នាំមកគំនាប់តាមប្រពៃណីក៏មិនបានការ ដែលមិនសមគួរដោយប្រការឯណា ក៏សូមឲ្យបងអត់ទោសប្អូនទៅចុះ ព្រោះឥឡូវនេះឡៅជៀនគិតការធំក្រៃលែង ប៉ង់នឹងមកធ្វើអន្តរាយដល់ខេត្តដែនរបស់ខ្ញុំបាទ ៗ ក៏សម្ងំនឹងរកទីពឹងពុំបាន តាមចិត្តគិតប្រាថ្នានឹងពឹងពាក់ប្រស្រ័យតែបងមួយ ដោយបុរាណនិយាយទុកមកថា ដប់អ្នកដទៃមិនស្មើនឹងសែជាមួយគ្នាតែម្នាក់ ហេតុនេះ សូមឲ្យបងអនុគ្រោះជួយដោះទុក្ខធុរៈខ្ញុំបាទ កុំឲ្យមានសេចក្តីអាប់យសដោយឡៅជៀននោះឡើយ ។ លុះតែងសំបុត្រស្រេចហើយ ក៏ប្រគល់ឲ្យហ្លួតចេនកាន់

ទៅដល់ឡៅពី ឲ្យបេងត័តនាំទាហាន ៥ ពាន់លើកចេញទៅនៅពាក់កណ្ដាលផ្លូវចាំទទួលឡៅពី បើឡៅពីមកដល់កាលណា ក៏ឲ្យអញ្ជើញចូលមកក្នុងស្រុកសៃឈួន ។

ខណៈនោះ អ៊ុយគួនទីប្រឹក្សាទៅស្រុកសៃឡ្យុង ដឹងថាឡៅជៀនទឹងប្រើហ្វូតបេងកាន់សំបុត្រទៅគំនាប់អញ្ជើញឡៅពីដូច្នោះ ទើបតៃលេះរលាំងចូលមកហើយស្រែកថា ហេតុម្ដេចលោកមកជឿពាក្យសំដីទៀវសុង ទឹងប្រុងលើកយកស្រុកសៃឈួនទាំង ១១ មណ្ឌលទៅឲ្យអ្នកដទៃវិញដូច្នោះ ។ ទៀវសុងបានឮក៏ភ័យណាស់ អង្គុយនៅស្ងាំងកាំង ។ ឡៅជៀនឆ្លើយថា ហេតុម្ដេចអ្នកមកថាដូច្នេះ អ្នកឯងមិនដឹងឬ ? ឡៅពីនោះជាសែជាមួយទឹងយើង ដែលទឹងឲ្យទៅអញ្ជើញមកទាំងនេះ ក៏ប្រាថ្នាទឹងឲ្យជួយការពារស្រុក ដើម្បីឲ្យនៅជាសុខតែប៉ុណ្ណោះ អ្នកឯងយល់ថា ខុសឬត្រូវប្រការម្ដេចបានជាថាដូច្នេះ ។

អ៊ុយគួនថា លោកមានប្រសាសន៍នោះត្រូវហើយ ព្រោះឡៅពី ទឹងលោកជាសែជាមួយគ្នា តែថាឡៅពីមានប្រាជ្ញាមានគំនិតល្បិចខាយច្រើនណាស់ ប្រៀបដូចខ្លាកញ្ជាស់ចាំស័លវែតតែធ្វើចិត្តនោះទោរទន់សុភាពរាបទាបប្រកបអធ្យាស្រ័យ ឲ្យមនុស្សដទៃស្រឡាញ់រាប់អានទូទៅឃើញកិរិយាក្រៅក៏សំដៅថាល្អ ឯចិត្តឡៅពីនោះមិនមែនបរិសុទ្ធទេ ប្រការមួយទៀត ឡៅពីនោះក៏មានខុនបេងទិនប៉ាំងថងជាទីប្រឹក្សាម៉ាំណាស់

ទាំងគួនអ៊ី ទៀតហើយ ជូឡុង អ៊ុយអៀន ហងតុង សឹងជាសេនាដៃឯក ចំឡែកខ្លាំងពូកែទៀត ដែលលោកនឹងឲ្យទៅអញ្ជើញឡៅពីយកមកទុកក្នុងស្រុកសែឈួននេះ កាលណាឡៅពីនឹងដាក់ខ្លួនឲ្យតូច ដូចគេយកកពជ-ស័ហ៍មកក្នុងផ្ទះនឹងបានឬ? មួយទៀតស្រុកសែឈួននេះ បើនឹងមានចៅហ្វាយស្រុក២នាក់ ក៏ដូចដាវ៍ញាក់ចុះប្រេងក្នុងពេនជាមួយគ្នានឹងនៅម្ដេចបាន ខ្ញុំស្មានថាប្រហែលទៀវស៊ុងនេះបានវេះចូលទៅស្រុកគេនឹងនិយាយឲ្យគេតិកាសញ្ញានឹងឡៅពី ទើបប្រទៀសមកលួងបញ្ឆោតលោកឲ្យយល់តាម ដើម្បីនឹងបង់បង្ខិចស្រុកលើកទុកឲ្យអ្នកដទៃ សូមឲ្យលោករវៀសរវៃចាប់ខ្លួនទៀវស៊ុងសម្លាប់ចេញទើបគួរសម ឯស្រុកសែឈួននេះប្រៀបបីដូចក្អមដីធំនៅនឹងមាំណាស់ លោកកុំអាលប្រឡូសប្រឡោតដោតតាមសំដីគេញុះញង់នោះឡើយ គ្មាននរណាឯងហើយ នឹងមកធ្វើអន្តរាយបានទេ ត្រូវយើងរិះគិតត្រួតប្រមូលពលរេហ៍ឲ្យបានច្រើន ហើយលើកទៅកំចាត់ឡៅពីចេញទើបបាន ។

ឡៅជៀងឆ្លើយថា អ្នកនិយាយនេះគួរហើយ តែបើបួចនឹងទៀវឡូលើកទ័ពមកធ្វើអន្តរាយយើងវិញ តើអ្នកនឹងត្រូវរិះគិតប្រការម្ដេចទៅវិញ?។ អ៊ុយគួនថា ដែលនឹងការពារបួចនឹងទៀវឡូនោះមិនជាការក្រប៉ុន្មានទេ បើបួចនឹងទៀវឡូលើកមក យើងនឹងរៀបចំទាហានលើកទៅរក្សាតយ

ដើម្បីការពារទុកឲ្យមាំកុំឲ្យចូលមកបាន គង់ទឹងក្រាន់ចិត្តលើកត្រឡប់ទៅឯង ស្រុកសែលឈ្មួនក៏ទឹងនៅជាសុខតទៅ ។

ឡៅជៀនពុធដូច្នោះឆ្លើយថា ធម្មតាសឹកលើកមកដល់ប្រទល់ព្រំស្រុកជិតនឹងលុកយកបានហើយ ទឹងថយត្រឡប់ទៅវិញនោះក៏មិនដែលឮមាន ដូចភ្លើងឆេះរោលជាលដល់កេមចិញ្ចើមហើយ ទឹងមិនក្តៅដល់ភ្នែកទេឬ? បើទឹងលត់ចេញទឹងស្ងៀមនៅ ឲ្យភ្លើងនោះរលត់ឯងទៅវិញបានឬ? ពាក្យនេះយើងមិនយកជាត្រូវទេ អ្នកថយចេញទៅចុះ ។ អង្គលុយឃើញដូច្នោះក៏ឃាត់ថា លោកមកជឿស្តាប់ពាក្យទៀវសុងនោះបីដូចជាយកភ័យមកដាក់ខ្លួន ។

ឡៅជៀនថា ដែលយើងទឹងឲ្យទៅអញ្ជើញឡៅពីមកក្នុងគ្រានេះ ក៏ប្រាថ្នាទឹងឲ្យជួយរក្សាស្រុកទេស ហេតុអ្វីអ្នកមកថាមានភ័យដល់ខ្លួន ។ អង្គលុយថា ទៀវឡូនេះទោះបីជាសត្រូវទឹងលោក ក៏បីដូចជាកមរមាស់ដែលកើតនៅកាយខាងក្រៅ បើទឹងយកក្រចកកេះចេញទៅក៏គង់ជាបាត់ទៅវិញ ឯឡៅពីទឹងចូលមកតាំងខ្លួននៅក្នុងស្រុកនោះ បីដូចកើតបូសជាប់នៅក្នុងថើមកណ្តាលដើមទ្រូង កម្រដែលទឹងយាងផ្ចុំឲ្យជាបាន ព្រោះឡៅពីជាមនុស្សអកតញ្ញូមិនបានដឹងគុណអ្នកឯណា ចូចួយកទៅចិញ្ចឹមរក្សាក៏ត្រឡប់ធ្វើកាចសាចប្រទូសរ៉ាយគេវិញ កាលទៅនៅទឹងស៊ុនគួនសោត ក៏បញ្ឆោតយកស្រុកកេងជីវនៅតាលដែតឡូវ គឺមិនជាមនុស្ស

ទៀតត្រង់ទីអ្នកឯណា ដែលលោកទីងទុកចិត្តឡៅពីទទួលយកមកមុក ក្រោកក្នុងស្រុកនេះ មុខជាទីងកើតអន្តរាយជាប្រាកដ ។

ឡៅជៀតព្រួដូចោះក៏គំហកស្រែកឱ្យអង់លុយថា ឡៅពីជាសែជាមួយទីងយើង កាលណាទីងគិតធ្វើកាចដល់យើងជាបងប្អូន អ្នកឯងនិយាយនេះមិនគួរសោះ ក៏បង្គាប់ឱ្យទាហានចាប់ខ្លួនអង់លុយទីងអ៊ុយគួននាំចេញទៅ ហើយបញ្ជាប់ឱ្យហ្លួតចេងស្រួតកាន់សំបុត្រនោះ លុះហ្លួតចេងទៅដល់ស្រុកកេងដីរហើយ ក៏ចូលទៅគំនាប់ឡៅពីរួចជូនសំបុត្រឱ្យមើល ឡៅពីដឹងក្នុងសេចក្ដីសំបុត្រហើយ ក៏មានអំណរសាទរណាស់ បង្គាប់ឱ្យរៀបតុលៀងអាហារតាមប្រពៃណី ។

ខណៈកាលកំពុងសេពសុរានោះ ឡៅពីក៏និយាយថា ទៀវស៊ុងប្រាប់ខ្ញុំថា ឈ្មោះអ្នកជាមនុស្សមានសតិបញ្ញាទាំងចិត្តក៏ល្អសុចរិត ខ្ញុំក៏មានសេចក្ដីត្រេកអរណាស់ ឥឡូវនេះអ្នកមកដល់ បានឃើញមុខសន្ទនាគ្នាក៏ជាបុញ្ញលាភប្រពៃណាស់ ។ ហ្លួតចេងថា ខ្ញុំបាទនេះជានាហ៊ឺនតូចទាប នរណាក៏គេមិនសូវស្គាល់ពប់គាប់ប៉ុន្មាន តែថាទៀវស៊ុងទៅប្រាប់ចេញនាមដល់លោក ខ្ញុំបាទក៏មានអំណរ ដែលបានមកក្នុងគ្រានេះប្រាថ្នាទីងចង់ដឹងថា ទៀវស៊ុងមកចោទទីងលោកនោះ លោកនៅមានសេចក្ដីវិតក្កនៅឡើយឬម្ដេច? ។

ទៀតថា ខ្ញុំសព្វថ្ងៃនេះគឺជាមនុស្សអភ័ព្វណាស់ ផែនដីតាំងមូលធំណាស់ តែខ្ញុំនឹងរកទីលំនៅឲ្យជាក់ច្បាស់ជារបស់ខ្លួនមិនបាន ត្រូវខ្ចីស្រុកគេនៅជាប្រធានទំពាំគិតអានបានមិនដឹងជាថ្ងៃណា គិតទៅគួរឲ្យឈឺផ្សាក្នុងចិត្តពន់ប្រមាណ សូម្បីតែបក្សីបក្សាវាក៏គង់មានឈើជាទ្រនំខ្ពស់ កើតមកជាមនុស្សមិនមានទីលំនៅហើយ ក៏គួរឲ្យសង្វេគវេទនា ដែលទៀវស្មងមកនិយាយថាឲ្យដឹងនោះ ខ្ញុំក៏អរណាស់ដែរ តែថាពាល់គំនិត ព្រោះដឹងតែឡៅដៀងជាសែជាមួយ មិនដឹងឲ្យទៅធ្វើម្តេច ៗ ហ្លួតចេងថា ស្រុកសែឈ្លួននោះក្លម៉ហ៊ានក៏មាំមួន បរិបូណ៌ដោយស្បៀងអាហារ ជាទីឧត្តមជាងស្រុកដទៃ បើអ្នកឯណាមិនមានប្រាជ្ញាស្មារតីហើយ ទៅតាំងខ្លួននៅជាធំក្នុងស្រុកនោះ ក៏គង់ថ្ងស់ត្រឡប់ទៅជារបស់អ្នកដទៃ ឥឡូវឡៅ-ដៀងឲ្យមានសំបុត្រមកដល់លោក ក៏ជូចលើកស្រុកនោះមកជូនហើយ គឺជាវាសនារបស់លោកប្រាកដ លោកត្រូវកំណត់គិតយកចុះ កុំបីបោះបង់ចោលស្រុកសែឈ្លួននោះឡើយ ដែលលោកនឹងគិតធ្វើការតទៅខាងមុខ ខ្ញុំបាទនឹងជួយទំនុកបំរុងឲ្យបានសម្រេចតាមសេចក្តីប្រាថ្នា ទោះបីជីវិតខ្ញុំបាទនឹងស្លាប់អសារក៏មិនសោកស្តាយ ឡៅតីក៏លើកដៃឡើងគំនាប់ហើយថា ខ្ញុំមានអំណរគុណនឹងអ្នកច្រើនណាស់ ៗ

លុះសេពស្រាហើយ ខុងចេងក៏ពាក់ចែងទីសំណាក់ឲ្យហ្លួតចេងនៅអាស្រ័យតាមសមគួរ ចាំងចង់ឃើញឡៅតីអង្គុយជ្រប់ស្ញប់នៅ

ដូច្នោះ ក៏ចូលមកនិយាយថា ឯធម្មតាអ្នកមានសតិបញ្ញានោះ បើនឹងគិតធ្វើការអ្វី ទោះនឹងពេញចិត្តក្តី មិនពេញចិត្តក្តី ក៏ត្រូវតែនិយាយឲ្យលេចឮច្បាស់ឡើង ដែលនឹងមកសញ្ជប់សញ្ជឹងការគេចិត្ត ក៏ហាក់បីដូចមនុស្សគ្មានតម្រិះប្រាជ្ញា ដូចយ៉ាងលោកជាមនុស្សមានសតិបញ្ញា នឹងមកអង្គុយកើតទុក្ខធុយមុខធុយក្រោយនៅដូច្នេះមិនគួរសោះ ។ ទៀតថា អ្នកនិយាយមកនោះក៏ត្រូវហើយ តែថា ខ្ញុំមកពិគ្រោះមើលឃើញមិនដឹងបើនឹងគិតយ៉ាងណា សតិបញ្ញារបស់អ្នកនឹងយល់ឃើញប្រការម្តេច?។

ប៉ាំងថង់ថា ឯស្រុកកេងជីវនេះ ខាងទិសឯកើត មានស៊ិនគួន ជាពោសសត្រូវនៅខាងនោះ ខាងទិសឯជើង មានចូឆូជាបច្ចាមិត្រ គិតតែនឹងបៀតបៀនកលវៃ សព្វថ្ងៃនេះ ដូចជាគេនៅក្នុងកណ្តាលគំនរភ្លើងដែលនេះពលចូលមក ព្រោះសត្រូវនៅសៀតសឹកជុំវិញខ្ទង់ ឯស្រុកសែ-ឈួននោះមានមនុស្សក៏នៅច្រើនកុះករ ទ្រព្យសម្បត្តិក៏បរិបូណ៌ ព្រមទាំងចំណីត្រីសាច់មិនខ្វះខាត បើសង្កាត់ទៅយកស្រុកនោះបាន ក៏នឹងមានតែសេចក្តីសុខសប្បាយ ឥឡូវទៀវស៊ុងនឹងហួតចេងទាំងពីរនាក់ចូលមកពិភាក្សាដល់លោកថានឹងខំទុកបំរុង ដូចទេព្តាមកចង្អុលកំណប់ទ្រព្យមាសឲ្យហើយ ម្តេចឡើយលោកមកមានវិតក្ក អង្គុយសញ្ជប់សញ្ជឹងដូច្នេះ ។

ទៀតថា ដែលខ្ញុំមានសេចក្តីវិតក្កនេះ ព្រោះឃើញថា ចូឆូនឹង

ខ្ញុំធ្វើការសព្វថ្ងៃនេះដូចទឹកនឹងភ្លើង គឺដូចជាភ្លើងរមែងធ្វើឲ្យអាណាប្រជានុរាស្ត្របានសេចក្ដីក្ដៅក្រហាយ ព្រោះចិត្តរាជាមនុស្សតែងប្រទូស្តគេឲ្យវិនាស ហើយខឹងលើកដំកើងខ្លួន ឲ្យជាធំពេញពាសក្នុងអាណាចក្រមណ្ឌល ឯខ្លួនខ្ញុំដូចទឹកត្រជាក់ជាអ្នកយោគយល់អាណិតគេ បើខឹងធ្វើការអ្វីក៏រមែងតាំងចិត្តគិតតែឲ្យបានចំរើនប្រយោជន៍ស្រុក ខឹងគិតឲ្យបានសុខអាណាប្រជានុរាស្ត្រទាំងឡាយទាំងពួង គេជះផល ដែលចិត្តជាសត្យសុចរិតដូច្នេះ ទើបមកបណ្ដាលឲ្យមានតម្រិះបេះតាំងខ្លួនបានដល់ត្រឹមណោះហើយ បើនឹងលះបង់សេចក្ដីសត្យដែលប្រព្រឹត្តមកជាទំលាប់ ដោយឃើញទ្រព្យហើយនឹងលះបង់សេចក្ដីសត្យកាត់យកតាមចិត្តលោភខុសពីផ្លូវយុត្តិធម៌នោះនឹងធ្វើមិនបាន ។

ចាំងចងថា ដែលលោកបានតាំងនៅក្នុងសេចក្ដីសត្យនោះ ក៏ជាទីទេវតា មនុស្សស្រុះស្រួលពោលសរសើរលោកណាស់ហើយ តែថាផែនដីសព្វថ្ងៃនេះមិនបានជាប្រក្រតីសោះ បេះតែកើតកលិយុគផ្សេងៗ មនុស្សទាំងចាស់ទាំងក្មេងកាន់អាវុធរក្សាខ្លួនមិនមានផុតពីដៃ បើលោកនឹងយកចិត្តល្អទៅកែខៃក៏ឃើញថាមិនបាន ធម្មតាភ័យមកដល់ខ្លួនប្រាណហើយ ត្រូវតែគិតការពារឲ្យរួចខ្លួនសិន ទើបទុកថាជាអ្នកមានប្រាជ្ញា ដូចជាស្រុកសៃឈូននោះ គួរតែត្រូវការខ្ចីគេជាទីអាស្រ័យទំរាំអស់ភ័យអន្ត-រាយ បើផែនដីបានសុខសប្បាយកបតាបវេលាណា សឹមគិតស្នងគុណ

គេវេលានោះតាមសមគួរឲ្យអស់សេចក្ដីតរហាទ៊ន្ទានឹងមិនល្អឬ? បើលោកមិនគិតយកស្រុកសៃឈួនវេលានេះទេ អំណើះតទៅ មុខជាស្រុកនោះក៏នឹងត្រឡប់ទៅជារបស់អ្នកដទៃទៀត បើនឹងចាំធ្វើការជាក្រោយ ក៏មិនឲ្យមានសម្រេចសេចក្ដីប្រាថ្នា នាំតែព្រួយ ការខាតតម្រិះប្រាជ្ញាអ្នកដែលប្រុងនឹងជួយឧបត្ថម្ភក៏ទទេទៅ ។

ឡៅពីពូជូនោះក៏យល់ត្រូវផង ទើបឆ្លើយថា ពាក្យដែលអ្នករំលឹកស្មារតីខ្ញុំនោះ គួរតែនឹងមានបារិកទុកក្នុងផែនមាស ដើម្បីប្រដៅចិត្តព្រឹកល្ងាច ហើយក៏ឲ្យអញ្ជើញខុងបេងចូលមកប្រឹក្សាដែលនឹងតាក់ការកេណ្ឌទាហានលើកកងទ័ពចេញទៅស្រុកសៃឈួន ៗ ខុងបេងថា ស្រុកកេងជីវស៊ីខាន់ណាស់ នឹងលើកទាហានទៅឥឡូវនេះ ហើយនឹងទុកចិត្តការដែលនៅឯក្រោយពុំបាន ត្រូវតែកេណ្ឌមនុស្សទុកឲ្យនៅរក្សាផង ៗ ឡៅពីថា លោកថានេះគួរណាស់ បើដូច្នោះ ខ្ញុនខ្ញុំនឹងបាំងជង អ៊ុយ-អៀន ហងតុង នឹងលើកទាហានទៅស្រុកសៃឈួនចុះ ខ្ញុនលោកនឹងគួនអ៊ូ ទៀវហ៊ុយ ជូឡុងនៅរក្សាស្រុកកេងជីវឯណោះ ខុងបេងក៏ទទួលពាក្យ ហើយឲ្យគួនអ៊ូទៅនៅស្រុកស៊ុងយ៉ុង ទៀវហ៊ុយជាកងក្រវែលរក្សាស្រុកទាំង ៤ អន្ទើដែលវាយបានថ្មី ឲ្យជូឡុងទៅនៅរក្សាស្រុកកាំឡេង ៗ

ឡៅពីតាំងឲ្យហងតុងជានាយទ័ពមុខ តាំងឲ្យអ៊ុយអៀនជានាយកងក្រោយ នាំទាហាន ៥ ម៉ឺនត្រៀមទុកស្រេច ចាំបានថ្ងៃជាឫក្សល្អនឹង

លើកចេញទៅស្រុកសៃឈួន ។ ខណៈនោះ សៀវហ្វូដែលជានាយចោរព្រៃនៅភ្នំខគយស្រុកហ៊ូគោ ក៏លើកពួកកៀនចូលមកនៅនឹងឡៀវពី ។ ក៏ចាត់ឲ្យទៅរក្សាស្រុកសុងយ៉ុងជាមួយនឹងគួនអ៊ូ លុះបានជោគបក្សល្អហើយ ឡៀវពីក៏ឲ្យលើកកងទ័ពចេញទៅតាមផ្លូវចម្ងាយប្រហែល ២០០០ សិន ( ៨០គ.ម. ) ទទួលជួបនឹងបេងតិត នាំទាហានចេញមកគំនាប់ហើយជំរាបថា ឥឡូវឡៀវដៀងនាយខ្ញុំប្របាទឲ្យលើកទាហានចេញមកទទួលលោក ឡៀវពីក៏មានចិត្តត្រេកអរណាស់ ប្រើបំរើកាន់សំបុត្រស្រូតចូលទៅជូនដល់ឡៀវដៀងឲ្យដឹងការជាមុន ។

ឡៀវដៀងដឹងដំណឹងហើយ ក៏ឲ្យមានសំបុត្រទៅដល់សាលាខែត្រទាំងពួងដែលត្រូវឡើង បង្គាប់តាមរយៈផ្លូវថា បើឡៀវពីមកដល់ដំបន់ណាត្រូវទទួលចាត់ការតាមគួរសម កុំឲ្យខ្វះប្រហែលឲ្យអត់ស្បៀងអាហារទំរាំតែកាលណាបានទៅដល់ស្រុកសៃឈួន ហើយក៏ឲ្យចាត់ទាហាន ៣ ហ៊ឺន នឹងរទេះសម្រាប់ដឹកមានសប្បធនបាំងទឹងគ្រឿងហៃហើយនឹងបណ្ណាការគ្រឿងមាសប្រាក់ទាំងពួងជាច្រើន នឹងចេញទៅទទួលឡៀវពីនៅដំបន់ប៉ោយសៀ ។ អ៊ុយគួនឃើញឡៀវដៀងចាត់ចែងទាហាន ខឹងចេញទៅទទួលឡៀវពីដូច្នោះ ក៏ចូលទៅនិយាយថា ខ្លួនខ្ញុំបាទមកធ្វើរាជការ

( នៅមានត )

រឿងព្រេងចិន

លោក ក៉យ-ប៊ុតា ប្រែរៀបរៀង

(តមក)

## ៣– រឿងព្រះបាសីហ្គាល់

ក្នុងពេលនោះ មានអាស្បូតមួយជាអ្នកមានវោហារគ្រាន់បើ បានចូលមកជិតលោកសីហ្គាល់ ហើយពោលថា៖

«តើក្នុងពេលឥឡូវនេះ ពួកសត្វពាននៃពិភពលោករស់នៅដោយសន្តិភាពឬ? ពីមុនមកប្រាកដមែនលោក! តែឥឡូវនេះ គ្មានទេ តាំងពីពស់វែកបែបភាពដូចអារក្សមកស្ថិតនៅក្នុងភ្នំនេះ វាធ្វើឲ្យខូចរបៀបរៀបរយក្នុងពិភពលោក ។

លោកសីហ្គាល់ ក៏តបទៅវិញថា: «ម្តេចក៏ដូច្នោះ» ។

អាស្បូតបក្សាឆ្លើយដំណបទៅវិញថា: មានពស់វែកមួយយ៉ាងធំស្ថិតនៅក្នុងគិរីបព្វតាខាងកើត ។ រស្មីនៃព្រះចន្ទទាំងប្រាំមួយធ្វើឲ្យរូបកាយពស់នោះមានពលភាពដ៏អស្ចារ្យ ចំណាយកំដៅព្រះអាទិត្យទាំងប្រាំពីរបានវេទនាធ្វើឲ្យពស់នោះមានកំឡាំងពលំមានរូបធំធាត់ពន់ពេកណាស់ ពស់មិនចាំបាច់ធ្វើការអ្វីដើម្បីចិញ្ចឹមជីវិតខ្លួនវាសោះឡើយ ។ វាបានកំហែងគំរាមយើង

តាំងអស់គ្នាថា ត្រូវតែយើងក្នុងមួយថ្ងៃយកបក្សីមួយមកឲ្យធ្វើជាចំណីអាហាររបស់វាទៀតទៅទើបបានសុខ ។ បើយើងមិនព្រមឲ្យបក្សានោះទេ វានឹងសម្លាប់បក្សាបក្សីទាំងអស់នៅទីនេះ កុំឲ្យមានសល់ឡើយ ។ ថ្ងៃនេះយើងត្រូវយកសត្វទាទៅឲ្យវាស៊ី យើងត្រូវមកសំដែងនៅទីនេះ នូវសេចក្ដីសោកស្ដាយអាឡោះអាល័យគ្នានឹងគ្នា ។ ព្រោះហេតុដូច្នេះ បានជាយើងមានទឹកមុខស្រងូតស្រងាត់ ។

ក្នុងពេលនោះលោកសីហាល់ មានចិត្តអាណិតអាសូរបក្សាបក្សីទាំងឡាយនោះណាស់ ហើយក៏ស្រែកថា :

" ម្ដេចពួកអ្នកឯងបណ្ដោយឲ្យបងប្អូនអ្នកឯងគេយកទៅសម្លាប់តាមអំពើចិត្តដូច្នេះ ម្ដេចក៏មិនក្រោកឡើងតស៊ូនឹងពស់នោះ? " ។ មានសំឡេងច្បាស់ជាងគេជាតំណាងបក្សីបក្សាទាំងឡាយស្រែកថា :

" ច្បាំងនឹងពស់វែក ! គ្មានអ្នកណាច្បាំងបានទេ បើចង់ច្បាំងនឹងពស់នោះ ត្រូវតែបំផ្លាញព្រះអាទិត្យ នឹងព្រះចន្ទឲ្យខ្ទេចខ្ទីគ្មានសល់សិន ទើបរូបពស់នោះមានកំឡាំងថយមកនៅតាមធម្មតាវិញ ហើយវានឹងស្លាប់ឯងដោយងាយមិនខាន " ។

លោកសីហាល់ ពោលយ៉ាងខ្លាំងថា: " កុំព្រួយថ្វី ខ្ញុំទទួលភារៈតស៊ូនឹងពស់វែកនេះ " ។

លោកសីហ្គាល់ ពោលភ្លាម ក៏កាយបំផាយសេះតម្រង់ទៅចំគិរីបព្តានោះ ។ លុះទៅដល់កំពូលភ្នំ លោកយកធ្នូបាញ់តម្រង់ព្រះអាទិត្យមួយ ។ ព្រះទិត្យនោះ ដោយត្រូវធ្នូក៏ប្រែទៅជាដុំផ្សែងមួយមានពណ៌ខ្មៅ ហើយធ្លាក់មកប្រថពី ។ លោកសីហ្គាល់ បាញ់ព្រះអាទិត្យទីពីរ ទីបី ទីបួន . . . . ។

លុះព្រះអាទិត្យទីប្រាំមួយធ្លាក់ដល់ព្រះធរណី ព្រះអាទិត្យទីប្រាំពីរដែលស្ថិតនៅ ក៏ស្រែកពីលើមហាមេឃមកថា:

" លោកសីហ្គាល់ ! សូមលោកឈប់បាញ់ទៅ បើលោកបាញ់ខ្ញុំ ចំហាយក្តៅលេតលោយពីផែនដី សត្វលោកទាំងអស់នឹងស្លាប់ដោយរងា សូម្បីតែលោកឯងក៏ស្លាប់ដែរ " ។

លោកសីហ្គាល់ ក្រោយដែលបានរិះគិតត្រឹមត្រូវក៏តបទៅវិញថា: " ល្អហើយ ខ្ញុំមិនឲ្យលោកធ្លាក់ទេ តែឲ្យលោកកុំធ្វើឲ្យសត្វអាក្រក់ពាលទុច្ចរិតមានកម្លាំងកំហែងធំធាត់មាំមួនសោះឡើយ ។

ពួកកប្បបក្សីទាំងឡាយ កាលបើបានក្រឡេកមើលទៅឃើញព្រះអាទិត្យទាំងប្រាំមួយធ្លាក់ពីលើមហាមេឃ ក៏មានចិត្តសោមនស្សពន់ពេក ក៏ស្រែកថា:

" យើងបានរស់គង់មានជីវិតហើយ យើងត្រូវទៅមើលអាសត្វកាឡកិណ្ណី ទុច្ចរិតឈ្លានពានដែលកប់ផ្តាញជីវិតគេជាអនេកប្បការ " ។

ពួកបក្សាបក្សីក៏ប្រជុំគ្នាមួយក្រុមៗ ហើយហិចហើរទៅលើនគាល័យ ជាដូរហែ រហូតដល់គោហាដែលជាទីលំនៅសត្វចចៃ្រនោះ ។ ពួកនេះ បានឃើញពស់វែកបក់បែនខ្លួនក៏ជាវន់មូលញ័រចំប្រប់ តែនៅរស់នៅឡើយ ។ ពួកបក្សាបក្សីទាំងឡាយ ក្រោយដែលបានពូរយោបល់គ្នា ក៏ចាត់ឲ្យសត្វចាកមួយយកសារលិខិតមួយទៅជូនលោកសីហាល់ :

" បើលោកមានចិត្តសប្បុរស ធ្វើឲ្យព្រះចន្ទធ្លាក់មកលើប្រថពីទៀត ពស់វែកនោះលែងធ្វើបាបយើងបានហើយ " ។

លោកសីហាល់ ក្រោយដែលបានអានសារលិខិតនោះ ក៏យកធ្នូបាញ់ឆ្ពោះទៅចំព្រះចន្ទម្ដងមួយរហូតដល់ប្រាំ ។ ដល់ព្រះចន្ទទាំងប្រាំធ្លាក់មកលើប្រថពីហើយ ព្រះចន្ទទីប្រាំមួយក៏មានកាតាក់លើមហាមេឃថា:

« ឈប់ លោកសីហាល់ បើលោកបាញ់ខ្ញុំទៀត ផែនប្រថពីនឹងគ្មានរស្មីសោះឡើយ ។ សត្វលោកនឹងទៅជាមានភ្នែកខ្វាក់ ហើយខ្លួនលោកក៏ដូចេះដែរ » ។

លោកសីហាល់ ក៏តបទៅព្រះចន្ទវិញថា: " ល្អហើយ ខ្ញុំលែងបាញ់លោកហើយ តែត្រូវលោកលែងបំភ្លឺសត្វកំណាចអាក្រក់តាំងពីថ្ងៃនេះតទៅ " ។

លោកសីហាល់ នឹងបក្សាចចាកបានចុះពីលើភ្នំមកដល់វាលស្រាប់តែឃើញបក្សាបក្សីទាំងឡាយច្រៀងហោរក្រវ ៗ គ្រប់ៗគ្នាសប្បាយរីក

កយពន់ពេកណាស់ ។ មានសត្វស្លាបគ្រប់បែប-យ៉ាងហើយមានស្លាបគ្រប់ពណ៌មានសត្វទទានិងសត្វអាអូតជាដើម ក្រឡេកឃើញពីចម្ងាយនូវផាវផ្ទុកៗ នៃលោកសីហ្គាល់ ។ ពួកសកុណាទាំងនោះក៏នាំគ្នាដម្រៀបជាជួរហែ មានទទានិងអាអូតជាមេដឹកនាំ ហើយក៏ឱនក្បាលសំដែងការ-វគោរពនិងកតញ្ញូធម៌ជាយ៉ាងជ្រាលជ្រៅចំពោះលោកសីហ្គាល់ ។

ទទានិងអាអូតក៏ពោលពាក្យទៅកាន់លោកសីហ្គាល់ថា: យើងសុំសំដែងនូវកតញ្ញូតាជាយ៉ាងជ្រាលជ្រៅចំពោះលោក ជាបុព្វការីយ៉ាងឆ្នើមរបស់យើង ។ ពស់វែកដ៏កាចសាហាវនោះដែលធ្វើឲ្យខូចសន្តិភាព ឥឡូវស្លាប់ដោយរងាទៅហើយ ។ យើងបានសុខក្សេមក្សាន្តគ្រប់ៗគ្នា ។ ពួកយើងមានចិត្តត្រេកអរសោទរឥតឧបមា ។

លោកសីហ្គាល់ក៏ផៃលលើសេះ ហើយឆ្លើយតបទៅវិញថា:

(នៅមានត)

## តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

> ទំនៀមទម្លាប់ នៃខេមរជាតិ
> ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
> ព្រោះខេមរជាតិ ជាជាតិសោភី
> ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
>
> ប.៣

# រឿងព្រេងត្រពាំងលាក់ឥន្ទ្រិល

### នៅខែត្រកំពង់ឆ្នាំង

នៅឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខែត្រកំពង់ឆ្នាំង មានត្រពាំងមួយហៅថា ត្រពាំងលាក់ឥន្ទ្រិល ។ បានជាមានឈ្មោះដូច្នេះ ព្រោះមានរឿងដំណាលតៗគ្នាមកថា ៖

មានកុមារម្នាក់ជាក្មេងកំព្រាគ្មានមាតាបិតា សាច់ញាតិក៏គ្មាន ឥតញាតិសន្តានគ្រប់គ្រង ។ ចៅកំព្រានោះបាននៅពឹងពាក់សំណាក់អាស្រ័យ នឹងលោកគ្រូមេវត្ត ប៉ាយម៉ាក[១] ។

លោកគ្រូពិនិត្យឃើញចៅកំសត់នោះ ជាក្មេងស្លូតត្រង់ ក៏មានព្រះទ័យអាណិតអាសូរករុណា ទទួលឲ្យកុមារនោះនៅរៀនអក្សរ ។ កុមារនោះរៀនជាយូរឆ្នាំ បានចេះចាំតែអក្សរ ១១ តួ ព្រោះប្រាជ្ញាអាប់ឱន

---

១– ប្រហែលជាពាក្យដើមថាប្រឡាយមាត់ ? ព្រោះពាក្យថាប្រឡាយបានខាងទីមានទឹកហូរ, មាត់ គឺបានខាងផ្លូវ រួមសេចក្ដីទៅ ប្រឡាយមាត់ ប្រែថា ប្រឡាយផ្លូវទឹក ។

កាលលោកគ្រូដាក់ច្បាប់ឲ្យរៀន "នមោ" ចាំហើយ ដល់ដាក់ "ពុទ្ធា" ឲ្យទន្ទេញតទៅទៀត ក្មេង ឯ នមោ ឈឹង ទោះបីលោកគ្រូបង្ខំយ៉ាងណា ក៏ចេះចាំបានតែ នមោ ដល់ ត ឡៃ (១) ប៉ុណ្ណោះ សូម្បីលេខនព្វន្ត គុណហារ អ្វីក៏គ្មានចេះបន្តិចបន្តួចសោះឡើយ ហើយកុមារនោះចេះតែព្យាយាមទន្ទេញអក្សរថា ត ឡៃ ៗ ទាំងយប់ទាំងថ្ងៃឥតឈប់ឈរ ឮសូរក្តែង ៗ ហេតុដូច្នេះ ទើបអ្នកស្រុកអ្នកភូមិតែហៅថា ចៅ ត ឡៃ ៗ គ្រប់គ្នា ។

មានកាលមួយថ្ងៃ លោកគ្រូនឹកក្តុកក្តួលព្រះទ័យថាចៅ ត ឡៃ នេះ មកនៅក្តីយូរឆ្នាំហើយ គ្មានចេះចំណេះអ្វីសោះ តែចេះគោរពប្រណិប័តន៍អាត្មាអញមិនឲ្យមានហ្មង ការិយាមារយាទក៏សុចរិតស្លូតត្រង់ល្អណាស់ ទើបលោកគ្រូហៅចៅ ត ឡៃ មកឲ្យជំនួនទានប្រៀនប្រដៅ អំពីច្បាប់ចូលទៅនៅអាស្រ័យនឹងមន្ត្រី ជាប់បុណ្យសក្តិសព្វគ្រប់ហើយ ក៏មានព្រះពុទ្ធដីកាទៅកាន់ចៅ ត ឡៃ ថា នែកុមារ! ចៅមកនៅក្តីរៀនអក្សរតាំងពីក្មេងតូចរហូតដល់ធំពេញកម្លោះហើយ មិនចេះសោះ បើដូច្នេះអាត-ក្តីនឹងនាំចៅឯងឲ្យទៅនៅបំរើនាហ្មឺនធំ ចូរចៅត្រង់ត្រាប់តាមច្បាប់ដែលអាត្មាជាគ្រូប្រដៅហើយនោះទៅ ក្រែងលោមានកំព្យាសនានឹងបានជាធំ ៗ

កាលចៅ ត ឡៃ ព្រមទទួលតាមពុទ្ធដីកាឥតមានប្រកែកហើយ

---

១– អានថា អ៊ក–អី ៗ

លោកគ្រូនោះក៏នាំចៅ ឥ ឡៅ ទៅជូននាហ៉ឺនធំម្នាក់ សុំផ្ញើឲ្យនៅធ្វើជាកូនក្មួយបំរើ ហើយលោកគ្រូមានពុទ្ធដីកានឹងលោកមន្ត្រីនោះថា "សុំលោកមេត្តាចៅ ឥ ឡៅ នោះផង បើមានទោសខុសឆ្គងយ៉ាងណា សូមលោកអភ័យទោស អនុគ្រោះប្រដៃប្រដៅឲ្យបានចុះ ព្រោះចៅនេះជាមនុស្សកំព្រាឥតមេបាទេ នៅតែនឹងអាចក្តី តាំងពីតូចមក" ។

មន្ត្រីនោះ ក៏ទទួលចៅ ឥ ឡៅ ឲ្យនៅក្នុងផ្ទះបំរើបំពាស់ តាមធម្មតា មន្ត្រីនោះឃើញគំនិតមារយាទសុចរិតពិតត្រង់ល្អមែន ប៉ុន្តែមិនចេះលេខមិនចេះអក្សរសោះ នឹងឲ្យធ្វើជានាហ៉ឺនមានអំណាចសក្តិយ៉ាងណាក៏មិនកើត ។ លុះចំណេរចរកាលទៅ ប្រហែលជាចំនួន ១០ ឆ្នាំបាយ ស្រុកមានកើតចម្បាំង ចៅ ឥ ឡៅ ក៏លាមន្ត្រីវិលទៅសុំលោកគ្រូមេវត្តប៉ាយម៉ាកបួស ។ លោកគ្រូអង្គនោះ ក៏បំបួសជាសាមណេររក្សាសីល ១០ ព្រោះសាមណេរ ឥ ឡៅ នេះល្ងង់ខ្លៅណាស់ នឹងឲ្យបួសជាភិក្ខុមិនកើត ។

លុះបួសបានជាសាមណេរហើយ អ្នកផងហៅថាលោកនេន ឥ ឡៅ ។ កាលនៅយូរទៅ លោកនេន ឥ ឡៅ ជាអ្នកបួសខ្សត់លាភសក្ការៈ ទាំងកូនសិស្សក៏គ្មាន ក៏ទៅបញ្ចុះបញ្ចូលបបួលក្មេងអ្នកស្រុកម្នាក់ឈ្មោះចៅយ៉កមកនៅបំរើ ដើម្បីឲ្យស្រួលក្នុងការចិញ្ចឹមជីវិត ។ នៅវេរបុណ្យភ្ជុំបិណ្ឌ ដែលលោកកុដិជាវេរ ។ គេបាននំចំណីច្រើន វេលាយប់ស្ងាត់ចៅយ៉កដើររើសសំបកអន្សម នំគម ក្រោមកុដិគេមកដាក់ក្រោមកុដិលោកនេន ឥ ឡៅ

ឲ្យឃើញច្រើនជាងគុជដដែល ដើម្បីបង្អួតគេ ថាលោកគ្រូខ្ញុំមានទិំបំណី ច្រើនជាងគេ ។

ថ្ងៃមួយ ចៅយ៉ោកជាកូនសិស្ស បានទៅឃើញអ្នកស្រែម្នាក់ កំ-ពុងភ្ជួរស្រែនៅក្បែរត្រពាំងមួយ ដែលពេលល្ងាចគេដោះគោចេញ ទុកនង្គ័លក្បែរត្រពាំងនោះហើយគេដឹកគោទៅផ្ទះ ។ កាលគេចេញផុតទៅ ចៅយ៉ោកយកនង្គ័លគេទៅលាក់ក្នុងទឹកត្រពាំង ហើយទៅរៀបរាប់ប្រាប់លោកគ្រូ ឥ ត្បៀ ថា "ខ្ញុំករុណាយកនង្គ័លអ្នកស្រែម្នាក់ ដែលភ្ជួរនៅក្បែរត្រពាំងទឹកមួយមានភាពយ៉ាងនេះ មានដើមឈើយ៉ាងនោះ ខ្ញុំករុណាដាក់នង្គ័លនោះបែរយាមទៅខាងនេះ ចុងទៅខាងនោះ . . . សូមលោកគ្រូចាំទាយតាមដំណើរនោះចុះ" ។

ព្រឹកឡើង ម្ចាស់នង្គ័លដឹកគោមកភ្ជួរ មិនឃើញនង្គ័ល ក៏ខំដើររកគ្រប់ច្រកល្ហក បានជួបប្រទះនឹងចៅយ៉ោក ។ សួរថា "លោកពូទៅណាមកណា ក៏រលះរលាំងខ្វាំងម្ល៉េះ ?" ។ ម្ចាស់នង្គ័លប្រាប់ថា "អាក៏អើយ ! ចោរវាលួចនង្គ័លពូបាត់ពីយប់មិញទៅ រកមិនឃើញសោះ" ។

ចៅយ៉ោកប្រាប់ថា "បើដូច្នេះ លោកពូយកទៀនធូបម្លូស្លាទៅសំ-ពះលោកគ្រូខ្ញុំឈ្មោះលោកតា ឥ ត្បៀ នៅវត្តប៉ាយម៉ាក សុំឲ្យលោកទាយឲ្យចុះ លោកគ្រូខ្ញុំទាយធុតណាស់" ។ ម្ចាស់នង្គ័លក៏វិលវិញទៅផ្ទះ យក

ទៀនធូបម្លូស្លា តម្រង់ទៅលោកតា ឥ ក្លៀ សុំឲ្យលោកជួយឲ្យ ។ ឯលោកតាយើង កាលបានទទួលស្លាត្រួយហើយ ក៏រំពឹងគន់គូរមើលហើយសាសព្វថា "នង្គ័លនោះមានចោរនាំទៅលាក់ក្នុងត្រពាំងទឹក ជងកាបែរទៅខាងត្បូង យាមទៅខាងជើង ផ្អៀងផ្អកទៅខាងលិច" ។ ចប់ទំនាយស្រេច ម្ចាស់នង្គ័លក៏ត្រាច់ទៅរកតាមទំនាយនោះ បានឃើញពិតដូចលោកគ្រូ ឥ ក្លៀ ជួយនោះមែន ។ តាំងពីកាលនោះមក ក៏ល្បីខ្ទឹព្វទៅសព្វទិសទីថា លោកតា ឥ ក្លៀ ជួយពូកែណាស់ មនុស្សម្នាទាំងក្មេងទាំងចាស់ តែមានអាសន្នអន់ក្រក៏រត់ទៅរកឲ្យលោកគ្រូ ឥ ក្លៀ ជួយឲ្យគ្រប់គ្នា ។

ព្រោះមាននិទានដូច្នេះ បានជាត្រពាំងនោះមានឈ្មោះថា "ត្រពាំងលាក់នង្គ័ល" រៀងរាបដរាបមករហូតដល់សព្វថ្ងៃ ។

---

ផ្នែកតាំណាត់ជីវប្រវត្តិការណ៍

# ពិធីសម្ពោធវិមានឯករាជ្យ (៩-១១-៦២)

អស់លោកបានជ្រាបស្រាប់ហើយ ថាឯករាជ្យប្រទេសយើងបានកើតមាននៅថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ជាពិតប្រាកដ មិនមែនដូចពាក្យចចាមអារាមថា កើតមានឡើងដោយសារសន្និសីទហ្សឺណែវ (ប្រទេសស្វីស) នៅឆ្នាំ ១៩៥៤ នោះទេ ។ ចាប់តាំងពីនោះមក យើងបានឯករាជ្យមានចំនួន ១០ ឆ្នាំនឹងឆ្នាំនេះ ដោយសារព្រះហស្តដ៏ឆ្នើមនៃព្រះមហាក្សត្រ ជាទីគោរពនឹងជាទីស្នេហាស្មើដោយជីវិតនៃយើងព្រះនាមព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ដោយព្រះអង្គទ្រង់ស៊ូប្តូរព្រះជន្មដ៏ថ្លៃថ្លានៃព្រះអង្គ ដើម្បីប្រជាជាតិខ្មែរ ហើយទ្រង់យាងទៅចាប់អង្រួនពិភពលោកឲ្យភ្ញាក់រលឹក នឹងឲ្យដឹងយល់ច្បាស់នូវការស្រេកឃ្លានសេរីភាពនៃប្រជាជាតិខ្មែរ ដែលប្រទេសបារាំងចេះតែក្តាប់ទុក ពុំព្រមត្រឡប់ថ្វាយចំពោះព្រះអង្គ ៗ ជាអវសាន ដោយទ្រាំនឹងព្រះសកម្មភាពប្រកបដោយព្រះបញ្ញាញាណដ៏ឆ្លាតកងវៃ រកវេជនណាកន្លងពុំបាន ប្រទេសបារាំងក៏ព្រមសុខចិត្តត្រឡប់ផ្ទេរការត្រួតត្រាប្រទេសកម្ពុជា ជំពេញសមត្ថភាព ថ្វាយជាកម្មសិទ្ធិបរិបូណ៌គ្មានខ្វះវិស័យណា ចំពោះព្រះអង្គនៅថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ។

តាំងពីពេលនោះមក ប្រទេសកម្ពុជាយើងមាននាមល្បីល្បាញក្នុងឆាកអន្តរជាតិថា ជាប្រទេសឯករាជ្យប្រកបដោយអធិបតេយ្យ និងសម្បូណ៌ភាព រួចព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះអង្គទ្រង់ប្រារព្ធកសាងប្រទេសជាតិ ដោយយកព្រះទ័យទុកដាក់គ្រប់វិស័យ រហូតដល់ទ្រង់ដាក់រាជ្យថ្វាយចំពោះព្រះវររាជបិតា ព្រះនាមព្រះបាទសម្តេច ព្រះសុរាម្រិត ព្រោះតែព្រះអង្គ កាលបើទ្រង់គង់ជាព្រះមហាក្សត្រនៅទ្រង់ពុំអាចកសាងប្រទេសជាតិឲ្យបានពេញទំហឹង ពេញសមត្ថភាព មានការប្រស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ជាទីស្នេហារបស់ព្រះអង្គជាដើមបាន ។ ក្នុងចំណោមវត្ថុបំណងដើម្បីកសាងប្រទេសជាតិ មានវត្ថុបំណងមួយដែលព្រះអង្គទ្រង់បានតាក់តែងការធ្វើឲ្យមានរូបរាងឡើងខាងក្រោយពេលបានឯករាជ្យ ។ ឯវត្ថុបំណងនោះគឺ វិមានឯករាជ្យនេះឯងឲ្យសមទៅតាមប្រទេសឯករាជ្យនានា ក្នុងសាកលលោកដើម្បីទុកជាអនុស្សាវរីយ៍ជាតិ ។ តែដោយប្រទេសយើងទើបនឹងបានឯករាជ្យថ្មី ហើយថវិកាជាតិក៏អន់ខ្សោយ ការកសាងវិមានឯករាជ្យក៏រសាត់យារមកដល់ឆ្នាំ ១៩៦២ នេះ ទើបបានហើយ ។

ឥឡូវថ្ងៃមហានក្ខត្តឫក្សប្រកបដោយជោគជ័យមកដល់ហើយ ។ វិមានឯករាជ្យដែលកសាងឡើងដោយបេតុងអារម៉េ មានជណ្តើរចូលគ្រប់ទិសទាំងបួន តាក់តែងដោយច្នៃកែរដ៏វិចិត្រ កំពូលប្រដាប់ដោយក្បាច់រចនាដ៏

យ៉ាងស្រស់ឆើតឆាយ និយមយកតាមបែបអង្គរវត្ត តាំងនៅចំកណ្ដាលមហាវិថីឆមុខ ដែលគេអាចក្រឡេកឃើញពីគ្រប់ទិស ដូចជាកំពូលប្រាសាទអង្គរវត្តដែរ ។ នៅជុំវិញ នឹងនៅតាមសួនច្បារដ៏ប្រណីត ពីខាងកើតនឹងខាងលិច មានវិចិត្រភាក់តែងលំអដោយទង់ជាតិ នឹងចង្កៀងអគ្គិសនីគ្រប់ពណ៌ ។ នៅមុខវិជ្ជាស្ថានគរុកោសល្យ (សាលាគរុវិជ្ជា) តាមចំហៀងថ្នល់ខាងលិច មានព្រះពន្លាដ៏ធំវិចិត្រលំអដោយស្លឹករុក្ខជាតិពណ៌បៃតងស្រស់នឹងទង់ជាតិបក់រវិចគួរជាទីគាប់ចិត្តទស្សនា សម្រាប់សម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋគង់ប្រថាប់ នឹងសម្រាប់នាហ្មឺនសព្វមុខមន្ត្រីជាព្រះរាជបរិពារព្រះអង្គ ព្រមទាំងក្រុមអគ្គទូតនានាដែលជាភ្ញៀវកិត្តិយស ។

ពេលម៉ោង ៨ សម្ដេចព្រះប្រមុខរដ្ឋទ្រង់ថ្លែងព្រះសុន្ទរកថាដ៏យ៉ាងពិរោះក្បោះក្បាយ ប្រកបដោយសារប្រយោជន៍ជាអនេក ស្ដីពីឯករាជ្យនៃប្រទេសកម្ពុជា ដើម្បីជាទីសណ្ដាប់ដល់ប្រជាពលរដ្ឋជាទីស្នេហារបស់ព្រះអង្គ ព្រះរាជសុន្ទរកថានេះ យើងនឹងចុះផ្សាយជូនក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខ ១២ ។ លុះចប់ព្រះរាជសុន្ទរកថាដ៏សែនពិរោះនេះហើយ សម្ដេចព្រះបិតាឯករាជ្យជាតិ ទ្រង់ស្ដេចយាងមួយអន្លើដោយនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងអគ្គទូត ទៅកាត់ខ្សែបូរដែលចងសន្ធឹងទ្វារចូលប៉ែកខាងជើង ជានិមិត្តរូបនៃពិធីសម្ពោធវិមានឯករាជ្យ ។ បន្ទាប់ពីនោះមក

មានពិធីដង្ហែក្បួនយោធា ក្រុមយុវជន យុវតី ក្នុងព្រះរាជាណាចក្រទាំងមូលដ៏យ៉ាងអធិកអធមមហិមា ដែលមានក្បាលទ័ពចាប់ពីភ្នំដូនពេញទៅអស់រយៈពេលយ៉ាងយូរ ៗ ខាងលើអាកាសវេហាស៍ អាកាសយានបានហោះហើរពីទូរថ្លែលទីពិធីជាច្រើនដុំ ប្រកបដោយសូរយ៉ាងខ្លាំងស្ទើរបែកមេឃ ដើម្បីបញ្ជាក់នូវលទ្ធផលដ៏ប្រសើរនៃឯករាជ្យ និងសេចក្ដីត្រេកអរសាទរ ព្រមទាំងមានបាញ់កាំភ្លើង ២១ ណាត់ បញ្ជាក់នូវកំឡាំងឯករាជ្យផង ៗ

ចំណែកអ្នកទស្សនាវិញ យើងមិនអាចពិពណ៌នាបានឡើយ គឺមានសភាពច្រើនអនេកជាងសព្វឆ្នាំ និងគណនាត្រាប់ពុំបាន នាំគ្នាឈរកកស្រទាប់ ហាក់អ្នកយកស្និតចេកមកដាក់តម្រៀប តាមដងវិថីព្រះនរោត្តម និងជុំវិញវិមានឯករាជ្យ ៗ

សូមជំរាបបញ្ជាក់ថា ពិធីសម្ពោធវិមានឯករាជ្យបានចប់នៅថ្ងៃទី ១១-១១-៦២ ពេលម៉ោង ១០ ៗ ឱកាសនោះ សម្ដេចព្រះប្រមុខរដ្ឋមួយអន្លើ ដោយព្រះរាជបរិពារដូចធម្មតាតាមដង្ហែផង បានស្ដេចយាងទៅរំលត់ទៀនជ័យ ដែលទ្រង់បានអុជដំកល់ទុកនៅចំកណ្ដាលវិមានឯករាជ្យពីថ្ងៃទី៩-១១-៦២ មក ៗ ក្នុងពេលជាមួយគ្នានេះ មានធ្វើពិធីផ្លាស់ទង់ជ័យ គឺ សម្ដេចទ្រង់ប្រទានទង់ជ័យថ្មីដល់ក្រុមយោធា ហើយទ្រង់សព្វព្រះហឫទ័យឲ្យដង្ហែយកទង់ជ័យចាស់ទៅដំកល់ទុកក្នុងមន្ទីរពិពិធភណ្ឌទាហាន ៗ

មានការណ៍ចម្លែកមួយដែលគួរលើកយកមកជំរាបជូនជាដំណឹង គឺការរាំវង់កំសាន្តនៃអ្នកទស្សនាក្នុងពេលរាត្រី ។ នៅយប់ថ្ងៃទី ១១ វិច្ឆិកា ប្រហែលជាប់ពីម៉ោង ២០ ទៅ នៅជុំវិញវិមានឯករាជ្យ តាមដងមហាវិថីព្រះនរោត្តម និងនៅវត្តភ្នំ មានការរាំវង់កំសាន្ត ។ ខ្មែរនិងបរទេស ប្រុស ស្រី ក្មេង ចាស់ ឥតមានប្រកាន់ពណ៌ នាំគ្នារាំកំសាន្តយ៉ាងរីករាយពពាក់ពពូនសើចលេងសប្បាយជាសញ្ញាថា កម្ពុជាជាកោះសន្តិភាព ក្នុងដែនដីអាស៊ីអាគ្នេយ៍ ។ ការរាំវង់ជាសាធារណៈនេះបានតាំងនៅរហូតដល់ម៉ោង ៣ ភ្លឺទើបចប់ ។ ពិធីនេះពីបុរាណកាលមក មិនដែលកើតមានដល់ម្តងសោះ ទើបតែនឹងកើតមានក្នុងឱកាសនេះ ហើយយើងសន្និដ្ឋានថា ប្រហែលជានឹងមានជាទម្លាប់មិនខានទៅក្នុងអនាគត នៅឱកាសពិធីបុណ្យឯករាជ្យម្តង ៗ ។

នៅទីអវសាន យើងឆ្លៀតឱកាសនេះ សូមជូនយោបល់ដ៏ស្តួចស្តើងមួយ បន្ថែមចំពោះវិមានឯករាជ្យ ដែលជាកេរ្តិ៍យ៉ាងឧត្តមនៃប្រទេសកម្ពុជា ។

ឯកូនយោបល់នោះមានដូចតទៅ : ឯករាជ្យជាស្នាព្រះហស្តដ៏ឆ្នើមនៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ដោយមានកងជីវពល នារីក្លាហាន

ពួកដៃជាមួយកង់យោធា តាមដង្ហែអង្គព្រះមហាក្សត្រ ។ ដូច្នេះ នៅតាម ជញ្ជាំងខឿនក្រោមនៃវិមាន គូររចនាព្រះរូបសម្តេចព្រះបាតឯកកដ្យជាតិ ទ្រង់ស្តេចយាងពីមុខ ហើយរូបកង់ដវពល នាវក្តាហាន នឹងកង់យោធ. ពលខេមរភូមិន្ទហែពីខាងក្រោយ ដោយលំកាំភ្លើងឈើច្រូងច្រាង ។ ឯ ការធ្វើយ៉ាងនេះគ្រាន់ជាទិទស្សនា ហើយបានយល់ភ្លាម ៗ នៃក្រុមទេស. ចរក៍ អំពីឯកកដ្យយើង ដែលបានមកដោយសន្តិវិធី ។

បានជាយើងជូនយោបល់ដូច្នេះ ដោយអនុលោមទៅតាមប្រវត្តិ- សាស្ត្រខ្មែរ ដែលធ្លាប់មានមកនៅប្រាសាទអង្គរ ព្រោះនៅប្រាសាទ ខ្លះ មានរចនាជារឿងផ្សេង ៗ មានរឿងចម្បាំងរវាងខ្មែរនឹងចាមជាដើម ។ ទម្លាប់ប្រវត្តិសាស្ត្រនេះនាំឲ្យអ្នកទស្សនាអាចយល់នឹងហាំបានភ្លាម ។ ជាង ការសិក្សាតាមក្បួនតម្រា ។

ជេង-ជ្រើវ

---

# ពិធីតាំងចៅអធិការ និង គ្រូសូត្រថ្មី ក្នុងឆ្នាំ ១៩៦២
## ចាប់ពីខែមករា មកដល់ខែមេសា

ចាប់ពីខែមករា មកដល់ខែមេសា ១៩៦២ មានការតាំងចៅអធិការ និងគ្រូសូត្រទាំងអស់ ២៣ អង្គក្នុងព្រះរាជាណាចក្រកម្ពុជា ។

១- នៅថ្ងៃទី ១៧ ខែមករា ១៩៦២ បានតាក់តាំងព្រះតេជៈគុណ ពេញ-សង នាមឆាយា សីលសំវរៈ កើតឆ្នាំរក ព្រះជន្ម ៥៤ ឆ្នាំ បួសបាន ៣៣ ព្រះវស្សា ជាចៅអធិការវត្តពេងជីរ ឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្រព្រៃវែង លេខសញ្ញាប័ត្រ ៣២៧៤ ។

២- នៅថ្ងៃទី ១៦ ខែកុម្ភៈ ១៩៦២ បានតាក់តាំងព្រះតេជៈគុណ ទូច-ឃ្លាំង នាមឆាយា ព្រហ្មជាត កើតឆ្នាំជូត ព្រះជន្ម ៤៩ ឆ្នាំ បួសបាន ២៨ ព្រះវស្សា ជាចៅអធិការវត្តព្រែកពោធិមង្គល ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខេត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៧៨ ។

៣- នៅថ្ងៃខែឆ្នាំដដែល បានតាក់តាំងព្រះតេជៈគុណ អ៊ុម-ជា នាមឆាយាជោតត្ថេរ កើតឆ្នាំខាល ព្រះជន្ម ៤៧ ឆ្នាំ បួសបាន ២៣ ព្រះវស្សាជាគ្រូសូត្រស្តាំ នៅវត្តពោធិមង្គល ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខេត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៧៩ ។

៤– នៅថ្ងៃទី ១៩ ខែកុម្ភៈ ១៩៦២ បានតាក់តាំងព្រះតេជៈគុណ ម៉ុ-ឈួន នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំ ១៩០៧ ព្រះជន្ម ៥៥ ឆ្នាំ បួសបាន ៣៥ ព្រះវស្សា ជាចៅអធិការវត្តដំរីក ឃុំដំរីក ស្រុកក្រូចឆ្មារ ខែត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៨០ ។

៥– នៅថ្ងៃខែឆ្នាំដដែល បានតាក់តាំងព្រះតេជៈគុណ ណុប-មួង នាមឆាយា ឥន្ទជោតិបេរ កើតឆ្នាំ ១៩១៩ ព្រះជន្ម ៤៣ ឆ្នាំ បួសបាន ២៣ ព្រះវស្សា ជាគ្រូសូត្រស្តាំ វត្តដំរីក ឃុំ ស្រុក នឹងខែត្រដដែល លេខសញ្ញាប័ត្រ ៣២៨១ ។

៦– នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខែត្រដដែល បានតាក់តាំងព្រះតេជៈគុណ ឆូ-សង កើតឆ្នាំ ១៩៣០ ព្រះជន្ម ៣២ ឆ្នាំ បួសបាន ១១ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣២៨២ ។

៧– នៅថ្ងៃទី ៣១-១-៦២ បានតាក់តាំងព្រះតេជៈគុណ សោម-ក្រាង នាមឆាយា វិនយធម្មគេរ កើតឆ្នាំខាល ព្រះជន្ម ៧១ ឆ្នាំ បួសបាន៥១ព្រះវស្សា ជាគ្រូសូត្រស្តាំ វត្តបាកយណ៍ព្រះដរ ឃុំបាកយណ៍ ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៩១ ។

៨– នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខែត្រដដែល បានតាំងព្រះតេជៈគុណ ប៊ុល-អ៊ុម នាមឆាយាធម្មវិនយគេរ កើតឆ្នាំមមែ ព្រះជន្ម ៦៧ ឆ្នាំ បួសបាន ៤៦ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣២៩២ ។

៩- នៅថ្ងៃទី ៣១-១-៥២ បានតាត់តាំងព្រះតេជៈគុណ ឈុន-ណោ នាមធាយា សុវណ្ណគោ កើតឆ្នាំជូត ព្រះជន្ម ៧៤ ឆ្នាំ បួសបាន ៥២ ព្រះវស្សា ជាចៅអធិការវត្តកោះថែន ឃុំកោះម៉ែត្រ ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣២៩៣ ។

១០-១១- នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខេត្តដដែល បានតាត់តាំងព្រះតេជៈគុណ ព្រំ-អ៊ុច នាមធាយាបញ្ញាសុវណ្ណ កើតឆ្នាំ ១៨៩១ ព្រះជន្ម ៧១ ឆ្នាំ បួសបាន ៥១ ព្រះវស្សា ជាគ្រូសូត្រស្តាំ លេខសញ្ញាប័ត្រ ៣២៩៤ ទីងតាត់តាំងព្រះតេជៈគុណ ក្រូច-ជួង នាមធាយា ធម្មបញ្ញា កើតឆ្នាំ ១៨៩៨ ព្រះជន្ម ៦៦ ឆ្នាំ បួសបាន ៤៣ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣២៩៥ ។

១២-១៣-១៤-១៥-១៦-១៧-១៨- នៅថ្ងៃខែឆ្នាំដូចខាងលើ បានតាត់តាំងព្រះតេជៈគុណ ហង់-ហួន នាមធាយាពុទ្ធប្បញ្ញោ កើតឆ្នាំរកា ព្រះជន្ម ៤១ ឆ្នាំ បួសបាន ១៩ ព្រះវស្សា ជាចៅអធិការវត្តគោកពង ឃុំសំរោងលើ ស្រុកក្តាំពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣២៩៦ បានតាត់តាំងព្រះតេជៈគុណ អ៊ុក-សាង នាមធាយាធម្មកេសរ កើតឆ្នាំ ១៩០៦ ព្រះជន្ម ៦០ ឆ្នាំ បួសបាន ៣៥ ព្រះវស្សា ជាចៅ-អធិការវត្តអរុណរតី ឃុំត្រពាំងក្រសាំង ស្រុកក្តាំពេញ ( កណ្តាល ) លេខ

សញ្ញាប័ត្រ ៣២៩៧ បានចាត់តាំងព្រះតេជៈគុណ កែវ.កង់ នាម-ធាយាគម្ពីរញាណ កើតឆ្នាំរកា ព្រះជន្ម ៣៩ ឆ្នាំ បួសបាន ១៩ ព្រះវស្សា ជាចៅអធិការវត្តយសមេត្រីខាងត្បូង ឃុំលំហាច ស្រុកកំពេញ (កណ្ដាល) លេខសញ្ញាប័ត្រ ៣១៩៨ បានចាត់តាំងព្រះតេជៈគុណ ម៉ា-វៀម នាមធាយាវិសាលវេទ កើតឆ្នាំ ១៩២២ ព្រះជន្ម ៤០ ឆ្នាំ បួសបាន១៨ព្រះវស្សា ជាចៅអធិការវត្តមង្គលសត្ថាវ័ន ឃុំព្រែកតាសេក ស្រុកមុខកំពូល (កណ្ដាល) លេខសញ្ញាប័ត្រ ៣២៩៩ បានចាត់តាំងព្រះតេជៈគុណ ជួង-វិបុល នាមធាយា មុនីថេរ កើតឆ្នាំ ១៩៣៦ ព្រះជន្ម ២៦ ឆ្នាំ បួសបាន ៦ ព្រះវស្សា ជាចៅអធិការវត្តពិជយមុន្គ ឃុំកំពត ស្រុកកំពត (កំពត) លេខសញ្ញាប័ត្រ ៣៣០០ បានចាត់តាំងព្រះតេជ-គុណ ឌុត.ទឹម នាមធាយាបញ្ញាសុវណ្ណ កើតឆ្នាំ ១៩៣៣ ព្រះជន្ម ២៩ ឆ្នាំ បួសបាន ៨ ព្រះវស្សា ជាចៅអធិការវត្តសំពេនពន្ធ ឃុំពន្ធ ស្រុកព្រៃកប្បាស (តាកែវ) លេខសញ្ញាប័ត្រ ៣៣០១ បានចាត់តាំងព្រះ-តេជៈគុណ ប៉ែន.ង៉ាន នាមធាយាសន្ធរក្ខិត កើតឆ្នាំថោះ ព្រះជន្ម ៤៥ ឆ្នាំ បួសបាន ២៤ ព្រះវស្សា ជាគ្រូសូត្រស្តាំវត្តស្រយ៉ូវ ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ (កំពង់ធំ) លេខសញ្ញាប័ត្រ ៣៣០២ ។

១៩– នៅថ្ងៃទី ១០ ខែមិនា ១៩៦២ បានចាត់តាំងព្រះតេជៈគុណ មឿ-ស្វាយ នាមធាយាសច្ចបោកោ កើតឆ្នាំ ១៨៩៣ ព្រះជន្ម ៦៤ ឆ្នាំ

បួសបាន ៩ ព្រះវស្សា ជាចៅអធិការវត្តខណ្ឌសារ ឃុំកំពង់ចិន ស្រុកស្ទោង (កំពង់ធំ) លេខសញ្ញាប័ត្រ ៣៣០៣ ។

២០-២១- នៅថ្ងៃខែឆ្នាំ ឃុំ ស្រុក ខេត្ត ដូចខាងលើ បានតាត់តាំងព្រះតេជៈគុណ ចាង-សុខ នាមធាយាសីវទ្ធោ កើតឆ្នាំ ១៩២០ ព្រះជន្ម ២២ ឆ្នាំ បួសបាន ២ ព្រះវស្សា ជាគ្រូសូត្រស្តាំ លេខសញ្ញាប័ត្រ ៣៣០៤ បានតាត់តាំងព្រះតេជៈគុណ ហួង-ឃង នាមធាយា កល្យាណធម្មោ កើតឆ្នាំ ១៩៣៩ ព្រះជន្ម ២៣ ឆ្នាំ បួសបាន ១ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣៣០៥ ។

២២- នៅថ្ងៃទី ១០-៣-៦២ បានតាត់តាំងព្រះតេជៈគុណ គំ-តាំ នាមធាយា សិរីវណ្ណោ កើតឆ្នាំមមែ ព្រះជន្ម ៤៣ ឆ្នាំ បួសបាន ២០ ព្រះវស្សា ជាគ្រូសូត្រស្តាំ វត្តកំពង់ក្ដុក ឃុំកំពង់ក្ដុក ស្រុកសូត្រនិគម (សៀមរាប) លេខសញ្ញាប័ត្រ ៣៣០៦ ។

២៣- នៅថ្ងៃទី១៦-៣-៦២ បានតាត់តាំងព្រះតេជៈគុណ ខេព-ឌឹម នាមធាយា ចន្ទគោ កើតឆ្នាំ ១៩៣២ ព្រះជន្ម៣០ ឆ្នាំ បួសបាន ៩ ព្រះវស្សា ជាចៅអធិការវត្តវៃវេត ឃុំពប ស្រុកពាក់ង (ព្រៃវែង) លេខសញ្ញាប័ត្រ ៣៣០៩ ។

២៤- នៅថ្ងៃខែឆ្នាំដូចខាងលើ បានតាត់តាំងព្រះតេជៈគុណ ជុំ-ចាន់ត នាមធាយា ពុទ្ធសារ កើតឆ្នាំរក ព្រះជន្ម ៤២ ឆ្នាំ បួសបាន ២១

ព្រះវស្សា ជាចៅអធិការវត្តអរុណរង្សី ឃុំសណ្តែក ស្រុកសៀមរាប (សៀមរាប) លេខសញ្ញាប័ត្រ ៣៣១០ ។

២៥- នៅថ្ងៃទី ១៨-៤-៦២ បានតាំងព្រះតេជៈគុណ ស្រី-ជាម នាមឆាយា សុវណ្ណមេត្រ កើតឆ្នាំ ក្នុង ព្រះជន្ម ៤០ ឆ្នាំ បួសបាន ១៨ ព្រះវស្សា ជាចៅអធិការវត្តធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ (កណ្តាល) លេខសញ្ញាប័ត្រ ៣៣១១ ។

២៦- នៅថ្ងៃទី ២២-៤-៦២ បានតាំងព្រះតេជៈគុណ ឆ្បា ចៈ-បិន នាមឆាយា សុធម្មតេរបញ្ញា កើតឆ្នាំ ១៩២១ ព្រះជន្ម ៤១ ឆ្នាំ បួសបាន ២១ ព្រះវស្សា ជាចៅអធិការ វត្តធ្លាក់ ឃុំត្នោត ស្រុកបាទី (តាកែវ) លេខសញ្ញាប័ត្រ ៣៣១២ ។

២៧-២៨-២៩-៣០-៣១-៣២- នៅថ្ងៃខែឆ្នាំ ដូចខាងលើ បានតាំងព្រះតេជៈគុណ ប៊ុល-ស៊ឹម នាមឆាយាបញ្ញាថេរ កើតឆ្នាំ មមី ព្រះជន្ម ៤៥ ឆ្នាំ បួសបាន ២៤ ព្រះវស្សា ជាចៅអធិការវត្តពលស្បូវ ឃុំមេសប្រចាន់ ស្រុកពាក់ង (ព្រៃវែង) លេខសញ្ញាប័ត្រ ៣៣១៣ បានតាំងព្រះតេជៈគុណ សួន-សៀង នាមឆាយា អគ្គមុនី កើតឆ្នាំ ១៩៣៤ ព្រះជន្ម ២៨ ឆ្នាំ បួសបាន ៦ ព្រះវស្សា ជាចៅអធិការរាជាយត-នារាម ឃុំព្រៃគ្រី ស្រុកកំពង់លែង (កំពង់ឆ្នាំង) លេខសញ្ញាប័ត្រ៣៣១៤ បានតាំងព្រះតេជៈគុណ រស់-ម៉ែង នាមឆាយា សុវណ្ណបញ្ញា

កើតឆ្នាំកុរ ព្រះជន្ម ៦៤ ឆ្នាំ បួសបាន ៨ ព្រះវស្សា ជាចៅអធិការវត្តជោតវ័ន ឃុំត្រពាំងសាប ស្រុកបាទី ( តាកែវ ) លេខសញ្ញាប័ត្រ ៣៣១៥ បានតាត់តាំងព្រះតេជៈគុណ ឈ្ម ឆ-ច្រាង នាមឆាយាមង្គល-ត្កេពេ កើតឆ្នាំរកា ព្រះជន្ម ៣០ ឆ្នាំ បួសបាន ៩ ព្រះវស្សា ជាគ្រូសូត្រស្តាំ វត្ត ឃុំ ស្រុក ខែត្រខាងលើ លេខសញ្ញាប័ត្រ ៣៣១៦ បានតាត់តាំងព្រះតេជៈគុណ កែប-វ៉ា នាមឆាយាធម្មប្បញ្ញា កើតឆ្នាំរោង ព្រះជន្ម ៥៩ ឆ្នាំ បួសបាន ៣៣ ព្រះវស្សា ជាចៅអធិការវត្តមុនីសាគរ ឃុំ-ពង្រ ស្រុកឆ្លូង ( ក្រចេះ ) លេខសញ្ញាប័ត្រ ៣៣១៧ បានតាត់តាំងព្រះតេជៈគុណ ក្អាប-សៀង នាមឆាយាឥន្ទសរ កើតឆ្នាំខាល ព្រះជន្ម ៣២ ឆ្នាំ បួសបាន ១៣ ព្រះវស្សា ជាគ្រូសូត្រស្តាំនៃវត្ត ឃុំ ស្រុក ខែត្រខាងលើ លេខសញ្ញាប័ត្រ ៣៣១៨ ។